សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែប ឆ្នាំ២០២០-២០២៣

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែ សីហា ឆ្នាំ២០២៤

| ស្រាវជ្រាវដោយ | ណែនាំដោយ |
|---|---|
| និស្សិតឈ្មោះ **ក. ធី ម៉ុនថាវី** | សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា** |
| **ញៀត មករា** | |

| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលសិក្សា | ២០២០ |
| ជំនាន់ទី២៩ (អាហារូបករណ៍) | | ឆ្នាំសរសេរសារណា | ២០២៤ |

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែប ឆ្នាំ២០២០-២០២៣

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ធី ប៊ុនថាវរី**
**ញ៉ៀត មករា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៩ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០២០
ឆ្នាំសរសេរសារណា ២០២៤

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំ **ធី ម៉ុនថាវរី** និងខ្ញុំបាទ **ញៀត មករា** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រក្នុងឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៩ (អាហារូបករណ៍) ឆ្នាំសិក្សា ២០២៣-២០២៤។

ជាបឋមនាងខ្ញុំ និងខ្ញុំបាទ សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរពការដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើត ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចក្រូចឆ្មារហូតដល់ធំធាត់ពេញវ័យ ព្រមទាំងផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ ការអប់រំទូន្មានប្រៀនប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជំរុញ និងលើកទឹកចិត្តក្នុង ការបញ្ជូនកូនៗទៅទទួលការសិក្សាអប់រំ។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្តល់នូវការផ្គត់ផ្គង់ទាំងថវិកា និងសិក្ខាបករណ៍ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រធ្វើឱ្យកូនចងចាំជានិច្ច ដោយមិនអាចបំភ្លេចបាន។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន លះបង់ពេលវេលា ព្រមទាំងកម្លាំងកាយកម្លាំងចិត្តដល់នាងខ្ញុំ និងខ្ញុំបាទក្នុងរយៈពេលបួនឆ្នាំកន្លងមក ដើម្បីឱ្យនាងខ្ញុំ និងខ្ញុំបាទ ទទួលបាននូវចំណេះដឹងផ្នែកនីតិសាស្ត្រលើបញ្ហានានាដែលពាក់ព័ន្ធនឹងច្បាប់ជាតិ ព្រមទាំងច្បាប់អន្តរជាតិថែម ទៀតផង។ ជាពិសេស សូមថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលជាសាស្ត្រាចារ្យ ណែនាំ ដើម្បីធ្វើឱ្យមាននូវដំណើរការនៃការតាក់តែងកិច្ចការស្រាវជ្រាវនេះឡើង ប្រកបទៅដោយភាពជោគជ័យ។ ទន្ទឹមនឹងនោះ លោកសាស្ត្រាចារ្យបានចំណាយកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុង ការប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ អនុសាសន៍ល្អៗ ជួយកែលំអចំណុចខ្វះខាត ទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យកិច្ចការស្រាវជ្រាវរបស់នាងខ្ញុំ និងខ្ញុំបាទមួយនេះបានទទួលនូវលទ្ធផលល្អ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណ សូមគោរពប្រសិទ្ធិពរជ័យដល់វត្ថុស័ក្តសិទ្ធិក្នុងលោក សូមជួយ ថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើជួបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ០៤ឆ្នាំរួចមក នាងខ្ញុំ និងខ្ញុំបាទពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយទទួលបានចំណេះដឹងជំនាញនីតិសាស្ត្រលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងផ្នែកនីតិសាធារណៈ ក្រោមការខិតខំប្រឹងប្រែងប្រកបដោយការយកចិត្តទុកដាក់អប់រំ ផ្តល់ដំបូន្មាន ណែនាំ បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យទាំងអស់។

ជាលទ្ធផលដោយសារតែមានការជួយជ្រោមជ្រែង និងការយកចិត្តទុកដាក់ទាំងអស់នេះហើយទើបធ្វើឱ្យនាងខ្ញុំ និងខ្ញុំបាទ មានឱកាសក្នុងការបង្ហាញស្នាដៃតាមរយៈការសិក្សាស្រាវជ្រាវ ដោយបានសរសេរចងក្រងសារណានេះលេចចេញជារូបរាងឡើង ដែលជាចំណងដៃក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ក្រោមប្រធានបទ **ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបឆ្នាំ២០២០-២០២៣** ក្នុងគោលបំណងជួយពង្រឹងនូវចំណេះដឹងលើវិស័យទេសចរណ៍ក្នុងការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ និងព្រមទាំងការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបឱ្យកាន់តែមានការរីកចម្រើន ដែលជាផ្នែកមួយដ៏សំខាន់នៅក្នុងការជួយដល់សិស្ស និស្សិត និងអ្នកស្រាវជ្រាវទាំងឡាយ ដែលកំពុងជួបនឹងការលំបាកក្នុងការស្រាវជ្រាវរកឯកសារបំពេញបន្ថែមក្នុងអំឡុងពេលកំពុងរៀនសូត្រ។

ក្នុងនាមនាងខ្ញុំ និងខ្ញុំបាទជានិស្សិតដែលបានធ្វើការស្រាវជ្រាវរៀបចំចងក្រងសារណានេះឡើង នាងខ្ញុំ និងខ្ញុំបាទសូមទទួលស្គាល់ថា ទោះបីជាសារណានេះបានចងក្រងឡើងដោយការខិតខំព្យាមយាមប្រឹងប្រែងយកចិត្តទុកដាក់ និងផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយក៏អាចនៅតែមានការភ្លេចភ្លាត់ខុសឆ្គងត្រង់ចំណុចណាមួយដោយកំហុសអចេតនាជាមិនខាន។ ហេតុដូចនេះហើយ នាងខ្ញុំ និងខ្ញុំបាទសូមធ្វើការអភ័យទោសពីសំណាក់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ និងមិត្តអ្នកអានទាំងឡាយទុកជាមុននូវរាល់កំហុសឆ្គង ចំណុចដែលខ្វះខាតនៅលើឃ្លាឃ្លោងប្រយោគ ឬមាននូវកំហុសអក្ខរាវិរុទ្ធទាំងឡាយដែលកើតឡើងដោយអចេតនា និងសូមស្វាគមន៍ជានិច្ចរាល់មតិយោបល់រិះគន់ក្នុងន័យស្ថាបនា ដើម្បីធ្វើការកែលំអសារណាមួយនេះឱ្យកាន់តែល្អប្រសើរឡើង។

ជាទីបញ្ចប់ នាងខ្ញុំ និងខ្ញុំបាទសូមគោរពប្រសិទ្ធិពរដល់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ហើយយកចិត្តទុកដាក់ក្នុងការអានទៅលើប្រធានបទនេះ សូមឱ្យជួបប្រទះតែសេចក្តីសុខ សុភមង្គល សំណាងល្អ សុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម**.......................................................................................................១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការរៀបចំតំបន់ទេសចរណ៍ខេត្តកែប**

**១.១. ប្រវត្តិខេត្តកែប** .......................................................................................... ៤

**១.១.១. ទីតាំងភូមិសាស្ត្រ និងតំបន់ទេសចរណ៍ខេត្តកែប**.........................................៤

១.១.១.១. ទីតាំងភូមិសាស្ត្រ.................................................................................. ៤

១.១.១.២. តំបន់ទេសចរណ៍ ................................................................................... ៥

**១.១.២. ដង់ស៊ីតេប្រជាជន** ...............................................................................៥

១.១.២.១. ចំនួនប្រជាជន ....................................................................................... ៥

១.១.២.២. ជីវភាពប្រជាជន .................................................................................... ៦

**១.២. រចនាសម្ព័ន្ធរដ្ឋបាលខេត្តកែប**............................................................................ ៥

**១.២.១. សមាសភាព** ........................................................................................៧

១.២.១.១. ក្រុមប្រឹក្សាខេត្ត ...................................................................................៧

១.២.១.២. គណៈអភិបាលខេត្ត ...............................................................................៧

**១.២.២. តួនាទី និងភារកិច្ច**...............................................................................៨

១.២.២.១. ក្រុមប្រឹក្សាខេត្ត..................................................................................... ៨

១.២.២.២. គណៈអភិបាលខេត្ត................................................................................ ៩

**១.៣. រចនាសម្ព័ន្ធមន្ទីរទេសចរណ៍ខេត្តកែប** ...............................................................១១

**១.៣.១. សមាសភាពមន្ទីរទេសចរណ៍**.................................................................១១

**១.៣.២. តួនាទី និងភារកិច្ចមន្ទីរទេសចរណ៍** ........ ១២

**១.៤. មូលហេតុដែលជំរុញឱ្យមានការរៀបចំតំបន់ទេសចរណ៍ខេត្តកែប** ........ ១៤

**១.៤.១. កំណើនតំបន់ទេសចរណ៍ធម្មជាតិ** ........ ១៤

**១.៤.២. កំណើនតំបន់ទេសចរណ៍កែច្នៃ** ........ ១៤

**១.៤.៣. កំណើនតំបន់ទេសចរណ៍វប្បធម៌** ........ ១៥

**១.៤.៤. កំណើនប្រជាជន** ........ ១៥

**១.៤.៥. កំណើនភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ** ........ ១៦

## ជំពូកទី២

## ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបឆ្នាំ២០២០-២០២៣

**២.១. ផែនការអភិវឌ្ឍន៍តំបន់ទេសចរណ៍ខេត្តកែប** ........ ១៨

**២.១.១. យុទ្ធសាស្ត្រនៃការអភិឌ្ឍតំបន់ទេសចរណ៍ខេត្តកែប** ........ ១៨

២.១.១.១. ចក្ខុវិស័យអភិវឌ្ឍន៍ ........ ១៩

២.១.១.២. គោលបំណងនៃការអភិវឌ្ឍ ........ ២០

២.១.១.៣. គោលដៅនៃការអភិវឌ្ឍ ........ ២០

**២.១.២. ការរៀបចំអភិវឌ្ឍន៍តំបន់ទេសចរណ៍ខេត្តកែប** ........ ២១

២.១.២.១. តំបន់ឆ្នេរសមុទ្រ ........ ២១

២.១.២.២. តំបន់រមណីយដ្ឋាន ........ ២៣

២.១.២.៣. តំបន់សេដ្ឋកិច្ច ........ ២៣

**២.១.៣. ការជំរុញក្នុងការលើកកម្ពស់វិស័យទេសចរណ៍ខេត្តកែប** ........ ២៤

២.១.៣.១. ការផ្សព្វផ្សាយ ........ ២៤

២.១.៣.២. ការវិនិយោគ ........ ២៥

**២.២. ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់តំបន់ទេសចរណ៍ខេត្តកែប** ........ ២៥

**២.២.១. ការរៀបចំសោភ័ណភាព** ........ ២៦
២.២.១.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ ........ ២៦
២.២.១.២. ការរៀបចំសោភ័ណភាពពេលយប់ ........ ២៨
**២.២.២. ការរៀបចំសណ្តាប់ធ្នាប់** ........ ២៨
២.២.២.១. ការរៀបចំសន្តិសុខ ........ ២៨
២.២.២.២. ផាសុកភាពនៃតំបន់ទេសចរណ៍ខេត្តកែប ........ ៣២
២.២.២.៣. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ ........ ៣៩
**២.៣. បញ្ហាប្រឈម យន្តការដោះស្រាយ ព្រមទាំងសមិទ្ធផល** ........ ៤០
**២.៣.១. បញ្ហាប្រឈម** ........ ៤០
**២.៣.២. យន្តការដោះស្រាយ** ........ ៤៣
**២.៣.៣. សមិទ្ធផលសម្រេច** ........ ៤៧
**សេចក្តីសន្និដ្ឋាន** ........ ៥៣
**អនុសាសន៍** ........ ៥៤
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងតែធ្វើការខិតខំប្រឹងប្រែងក្នុងការរៀបចំ និងអភិវឌ្ឍន៍ទៅលើគ្រប់វិស័យទាំងអស់ដើម្បីធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនជឿនលឿនទៅមុខឱ្យដូចប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតនៅលើសកលលោក។ ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ កម្ពុជាបានផ្តោតទៅលើវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យទេសចរណ៍ជាដើម ដែលតែងតែរកចំណូលបានយ៉ាងច្រើនពីវិស័យទាំងអស់នេះផងដែរ។ ចំណែកឯរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់ទៅលើវិស័យនានា ពិសេសទាក់ទងគឺទៅនឹងវិស័យទេសចរណ៍ ព្រោះប្រទេសកម្ពុជាសម្បូរទៅដោយទីកន្លែងទេសចរណ៍ជាច្រើនសម្រាប់ភ្ញៀវទេសចរដើរកម្សាន្ត។ ទន្ទឹមនឹងនេះ សម្រាប់វិស័យទេសចរណ៍នៅកម្ពុជាមានច្រើនប្រភេទ ហើយក្នុងចំណោមទីកន្លែងទេសចរណ៍ជាច្រើនរដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើតំបន់សមុទ្រទាំង ០៤ រួមមាន ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប ដែលស្ថិតនៅទិសនិរតីនៃព្រះរាជាណាចក្រកម្ពុជាដែលបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍប្រទេសជាតិ ពិសេសជាគោលដៅទេសចរណ៍ដែលចាំបាច់ត្រូវតែរៀបចំ និងអភិវឌ្ឍន៍ផងដែរ។

ជាក់ស្តែងក្នុងចំណោមខេត្តសមុទ្រទាំងបួន ខេត្តកែប គឺជាខេត្តមានផ្ទៃដីតូចជាងគេដែលសម្បូរទៅដោយកន្លែងទេសចរណ៍គ្រប់សព្វបែបយ៉ាងដោយយោងទៅលើធនធានធម្មជាតិ តំបន់ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងជាទីតាំងមួយនៅក្នុងគម្រោងព្រែកជីកហ្វូណនតេជោ ដោយមានលក្ខខណ្ឌអំណោយផលនានាដែលនឹងក្លាយជាទីតាំងមួយទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិមកទស្សនា និងសម្រាកកម្សាន្ត។ មូលហេតុទាំងនេះក៏បានធ្វើឱ្យមានការទាក់ទាញនូវវិនិយោគិនឱ្យមកវិនិយោគលើវិស័យទេសចរណ៍នៅក្នុងខេត្តកែប។ តាមរយៈនេះផងដែរ ខេត្តកែបចាំបាច់ត្រូវតែមានការអភិវឌ្ឍ និងការរៀបចំឱ្យមាននូវសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយក្នុងការជួយជំរុញឱ្យតំបន់ទេសចរណ៍មានភាពទាក់ទាញ ពិសេសការទទួលបាននូវចំណូលដើម្បីជួយសម្រួលដល់ជីវភាពប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលបានពីវិស័យទេសចរណ៍ក្នុងខេត្ត និងជួយដល់កំណើនសេដ្ឋកិច្ចជាតិ។

ទន្ទឹមនឹងនេះ ដើម្បីធ្វើឱ្យវិស័យទេសចរណ៍ក្នុងខេត្តកែបទទួលបាននូវការរីកចម្រើនជឿនលឿនទៅមុខចាំបាច់ណាស់ត្រូវតែមានការរៀបចំ និងការអភិវឌ្ឍដោយត្រូវមានផែនការច្បាស់លាស់ និងធ្វើការសិក្សាអំពីបញ្ហាប្រឈមនានាដែលបានកើតឡើងភ្ជាប់ជាមួយនឹងការដឹកនាំដ៏មានប្រសិទ្ធិភាព ក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមទាំងអស់នោះ មូលហេតុទាំងនេះហើយ ទើបធ្វើឱ្យនាងខ្ញុំ និងខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសប្រធានបទដែលនិយាយទាក់ទងទៅនឹងនីតិនគរូបនីយកម្ម និងសំណង់ ស្តីពីការអភិវឌ្ឍតំបន់ទេសចរណ៍ក្នុងខេត្តកែបឆ្នាំ ២០២០-២០២៣ ដើម្បីធ្វើការស្រាវជ្រាវបញ្ចប់ការសិក្សា។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

យើងដឹងហើយថា ការរៀបចំអភិវឌ្ឍន៍ និងការគ្រប់គ្រងលើតំបន់ទេសចរណ៍ខេត្តកែប ត្រូវអនុលោមតាមបទបញ្ញត្តិច្បាប់ ក្របខ័ណ្ឌគតិយុត្ត ផែនការអភិវឌ្ឍន៍ ការគ្រប់គ្រង និងរៀបចំព្រមទាំងយន្តការនៃការដោះស្រាយសម្រាប់បញ្ហាប្រឈមនានាដែលបានកើតឡើងនៅតំបន់ទេសចរណ៍ខេត្តកែប។

ដូច្នេះហើយយើងគួរស្វែងយល់ថា តើសញ្ញាណគតិយុត្តនៃការរៀបចំអភិវឌ្ឍន៍ និងការគ្រប់គ្រងតំបន់ទេសចរណ៍នៅកម្ពុជា ពិសេសនៅខេត្តកែបមានខ្លឹមសារដូចម្តេច? តើមានវិធាន និងលិខិតបទដ្ឋានគតិយុត្តអ្វីខ្លះដែលមានអានុភាពលើការរៀបចំ និងការគ្រប់គ្រងតំបន់ទេសចរណ៍នៅខេត្តកែបមានខ្លឹមសារដូចម្តេច? តើផែនការអភិវឌ្ឍន៍តំបន់ទេសចរណ៍ខេត្តកែប មានខ្លឹមសារ និងយុទ្ធសាស្ត្រដូចម្តេច? តើមានស្ថាប័នណាខ្លះដែលមានសមត្ថកិច្ចចំពោះការរៀបចំ និងការគ្រប់គ្រងតំបន់ទេសចរណ៍នៅខេត្តកែប?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើ នាងខ្ញុំ និងខ្ញុំបាទនឹងធ្វើការបកស្រាយនៅក្នុងសៀវភៅសារណានេះ ដោយនឹងធ្វើការស្វែងយល់ឱ្យកាន់តែច្បាស់លាស់ និងឱ្យស៊ីជម្រៅអំពីសញ្ញាណទូទៅនៃការរៀបចំអភិវឌ្ឍន៍នៅតំបន់ទេសចរណ៍ខេត្តកែប និងការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបសម្រាប់ឆ្នាំ២០២០-២០២៣។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនីមួយៗ គឺសុទ្ធសឹងតែបានបង្កប់នូវគោលបំណង និងខ្លឹមសារសំខាន់ៗនៅក្នុងកិច្ចការស្រាវជ្រាវផ្សេងៗពីគ្នា។ ទន្ទឹមនឹងនេះ ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបឆ្នាំ២០២០-២០២៣ គឺនាងខ្ញុំ និងខ្ញុំបាទចង់បង្ហាញអំពីប្រវត្តិខេត្តកែប ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលខេត្តកែប រចនាសម្ព័ន្ធមន្ទីរទេសចរណ៍ខេត្តកែប និងមូលហេតុជំរុញឱ្យមានការរៀបចំតំបន់ទេសចរណ៍ខេត្តកែប ពិសេសការរៀបចំសណ្តាប់ធ្នាប់ សន្តិសុខ សោភ័ណភាព ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការដោះស្រាយបញ្ហានានាក៏ដូចជាសមិទ្ធផលដែលបានមកពីការអភិវឌ្ឍខេត្តកែបផងដែរ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលបានផ្តល់នូវអត្ថប្រយោជន៍ដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ឱ្យបានយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅអំពីការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ទីក្រុង ផែនការនៃការអភិវឌ្ឍខេត្តកែប ពិសេសការបង្ហាញនូវបញ្ហាប្រឈមនានា និងយន្តការដោះស្រាយជាមួយសមិទ្ធផលខេត្តនេះផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

យោងតាមប្រធានបទខាងលើនេះ ជាប្រភេទប្រធានបទមួយដែលមានសារៈសំខាន់ដែលទាក់ទងទៅនឹងការអភិវឌ្ឍដែលជាមូលហេតុធ្វើឱ្យនាងខ្ញុំ និងខ្ញុំបាទស្វែងរកនូវឯកសារដែលពាក់ព័ន្ធនឹងប្រធានបទសារណាតាមរយៈបណ្ណាល័យនីតិសាស្ត្រនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសតាមរយៈឯកសារបទដ្ឋានគតិយុត្តនានា រួមមានច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីប្រកាសនានារបស់រាជរដ្ឋាភិបាល ព្រមទាំងការស្វែងរកឯកសារផ្សេងៗទៀតនៅលើប្រព័ន្ធអ៊ីនធឺណែតជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំ និងខ្ញុំបាទបានបែងចែកជា ០២ជំពូក ដូចជា៖

- **ជំពូកទី១ "សញ្ញាណទូទៅនៃការរៀបចំតំបន់ទេសចរណ៍ខេត្តកែប"** ក្នុងជំពូកទី១ នាងខ្ញុំ និងខ្ញុំបាទនឹងលើកយកមកបង្ហាញដែលផ្តោតសំខាន់លើ ០៤ចំណុច ទាក់ទងនឹងប្រវត្តិខេត្តកែប រចនាសម្ព័ន្ធរដ្ឋបាលខេត្តកែប រចនាសម្ព័ន្ធមន្ទីរទេសចរណ៍ខេត្តកែប និងមូលហេតុ ដែលជំរុញឱ្យមានការរៀបចំតំបន់ទេសចរណ៍ខេត្តកែប។
- **ជំពូកទី២ "ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបឆ្នាំ២០២០-២០២៣"** ក្នុងជំពូកទី២ នេះផងដែរ នាងខ្ញុំ និងខ្ញុំបាទនឹងផ្តោតទៅលើចំណុចសំខាន់ៗចំនួន ០៤ ដែលទាក់ទង់ទៅនឹងផែនការនៃការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែប ការរៀបចំសោភ័ណភាពសណ្តាប់ធ្នាប់តំបន់ទេសចរណ៍ខេត្ត បញ្ហាប្រឈម យន្តការដោះស្រាយ ព្រមទាំងសមិទ្ធផលខេត្តកែប។

# ជំពូកទី១

# សញ្ញាណទូទៅនៃការរៀបចំ

# តំបន់ទេសចរណ៍ខេត្តកែប

# ជំពូកទី១

# សញ្ញាណទូទៅនៃការរៀបចំតំបន់ទេសចរណ៍ខេត្តកែប

## ១.១. ប្រវត្តិខេត្តកែប

ខេត្តកែប បានបង្កើតឡើងក្នុងអំឡុងឆ្នាំ១៩០៨ នាសម័យអាណានិគមនិយមបារាំង ដែលសម័យនោះ ខេត្តកែបគ្រាន់តែជាក្រុងប៉ុណ្ណោះ ដោយបានធ្វើការកែលំអឱ្យក្លាយជាទីក្រុងទេសចរណ៍ឆ្នេរសមុទ្រដ៏ប្រណិតមួយ ក្នុងទសវត្សរ៍ទី៦០ នាសម័យសង្គមរាស្ត្រនិយម។ ពាក្យ "**កែប**" ប្រែថា "ជ្រោយដែលមានន័យថាដីដុះលយទៅ សមុទ្រដែលមានភាពទាក់ទាញពីធម្មជាតិ" ដែលជាតំបន់មួយសម្បូរដោយទីផ្សារនៃគ្រឿងសមុទ្រស្រស់ ពិសេស នៅតំបន់ឆ្នេរសមុទ្រខេត្តកែបមានប្រភេទខ្យាច់សមុទ្រពណ៌ខ្មៅ។[១] ទន្ទឹមនឹងនោះ ខេត្តកែបត្រូវបានបង្កើតឡើង តាមព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ដែលត្រូវ បានបំបែកចេញពីខេត្តកំពតស្របតាមការសម្របសម្រួលព្រំសីមាខេត្តជាច្រើន ដោយបញ្ជាក់ថាក្រុងកែបប្តូរមក ជាខេត្តកែបវិញម្តង។[២]

### ១.១.១. ទីតាំងភូមិសាស្ត្រ និងតំបន់ទេសចរណ៍ខេត្តកែប

#### ១.១.១.១. ទីតាំងភូមិសាស្ត្រ

ខេត្តកែប គឺជាខេត្តមួយដែលមានផ្ទៃដីតូចជាងគេក្នុងប្រទេសកម្ពុជា ហើយជាខេត្តមួយក្នុងចំណោមខេត្ត ថ្មីៗជាច្រើនដែលមានការផ្តាច់ចេញពីខេត្តដទៃផ្សេងៗទៀត។ ចំពោះខេត្តកែបនេះ ជាខេត្តដែលមានតំបន់ ទេសចរណ៍ជាច្រើនបែបរួមមានតំបន់ទេសចរណ៍បែបធម្មជាតិដែលមានផ្ទៃដីគោកទំហំ ១៨៧,២៤គីឡូម៉ែត្រការ៉េ មានតំបន់ឆ្នេរសមុទ្រប្រវែង ២៦,៥០គីឡូម៉ែត្រ ហើយមានចម្ងាយប្រមាណ ១៧៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានផ្លូវជាតិឆ្លងកាត់ចំនួន ០២ខ្សែ(ផ្លូវជាតិលេខ៣ និង៣៣A) ផ្លូវរថភ្លើងចំនួន ០១ខ្សែ និងមានស្ថានីយរថភ្លើង ០១កន្លែង។ ចំណែកឯស្ថានភាពនៃផ្ទៃដីខេត្តនេះចែកចេញជាតំបន់ភ្នំ ជំរាលភ្នំ តំបន់មាត់សមុទ្រ និងមានតំបន់ កោះចំនួន១៣ រួមមានកោះទន្សាយ កោះពោធិ៍ កោះស្វាយ កោះម្ទេស កោះកុក កោះត្បាល់ កោះហាលត្រី កោះអាចម៍សេះ កោះអង្រុង កោះម៉ាក់ប្រាង កោះសារ៉ាង កោះស្វាយព្រៃ និងកោះស្ងួត។ រីឯព្រំប្រទល់ខេត្តកែប គឺខាងជើងទល់នឹងស្រុកដងទង់ និងស្រុកទឹកឈូ ខាងកើតទល់នឹងស្រុកកំពង់ត្រាច ខាងលិចទល់នឹងស្រុកទឹក ឈូនៃខេត្តកំពត ខាងត្បូងទល់នឹងដែនទឹកប្រវត្តិសាស្ត្រកម្ពុជា-វៀតណាម។

---

[១] គេហទំព័រ ប្រវត្តិខេត្តកែប - រដ្ឋបាលខេត្តកែប (kep.gov.kh) ដកស្រង់នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៤

[២] ព្រះរាជក្រឹត្យ ស្តីពីការប្តូរក្រុងកែបទៅជាខេត្តកែប, លេខ នស/រកត/១២០៨/១៣៨៣, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨

ចំពោះរដ្ឋបាលដែនដីវិញ បានចែកចេញជាក្រុង០១ និងស្រុក០១ គឺក្រុងកែបមានចំនួន ០៣សង្កាត់ (សង្កាត់អូរក្រសារ, សង្កាត់កែប, សង្កាត់ព្រៃធំ) ស្មើនឹង០៧ភូមិដែលជាចំណុះ (ភូមិអូរក្រសារ, ភូមិដំណាក់ចំបក់ , ភូមិកែវក្រសាំង, ភូមិព្រៃធំ, ភូមិដំណាក់ចង្អើរ, ភូមិកំពង់ត្រឡាច, ភូមិថ្មី) និងស្រុកដំណាក់ចង្អើរចំនួន ០២ឃុំ (ឃុំអង្កោល, ឃុំពងទឹក) ស្មើនឹង ១១ភូមិជាចំណុះ (ភូមិអំពេង, ភូមិកោះសោម, ភូមិអង្កោល, ភូមិទួលក្រសាំង, ភូមិចំការចេក, ភូមិអន្ទង់ស, ភូមិចំការបី, ភូមិរនេស, ភូមិអូរដូង, ភូមិព្រៃតាកុយ, ភូមិភ្នំលាវ)។[៣]

### ១.១.១.២. តំបន់ទេសចរណ៍

តំបន់ទេសចរណ៍ខេត្តកែប គឺជាតំបន់មួយដែលមានភាពទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ យ៉ាងគួរឱ្យកត់សម្គាល់ដោយសារខេត្តនេះពោរពេញទៅដោយធនធានធម្មជាតិដូចជាព្រៃកោងកាងមានផ្ទៃដីទំហំ ១,០០៥ហិកតា ស្មៅកោងកាងមានផ្ទៃដីទំហំ ៣,០៩៥ហិកតា ផ្កាថ្មមានផ្ទៃដីទំហំ ៥២,៥ហិកតា សត្វសមុទ្រ កម្រ(ជ្រូកទឹក អណ្ដើកសមុទ្រ ផ្សោត) ជ្រូកទឹកចំនួនពី ៥-១០ក្បាល អណ្ដើកសមុទ្ររាប់រយក្បាល ផ្សោតជាង ១០០ក្បាល សារមន្ទីរមានចំនួន ០១កន្លែង រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រចំនួន ០៧កន្លែង រមណីយដ្ឋាន ធម្មជាតិចំនួន ២៤កន្លែងដែលរួមមាន ឆ្នេរលេងទឹក កោះទន្សាយ កោះពោធិ៍ កោះអាចម៍សេះ ផ្សារក្ដាម ឆ្នេរថ្មី ព្រៃកោងកាង វាលលំហែរជ្រោយដូង ឧទ្យានជាតិ សួនមេអំបៅ រមណីយដ្ឋានភ្នំវល្លិ៍ ឆ្នេរអង្កោល និងរមណីយដ្ឋាន កែថ្មមានចំនួន ០៧កន្លែង។ ជាងនេះទៅទៀត នៅតាមតំបន់ទេសចរណ៍ខេត្តកែបក៏មានកន្លែងសម្រាកកម្សាន្ត និងការផ្តល់សេវាកម្មនានាជូនភ្ញៀវទេសចររួមមានដូចជា បឹងហ្គាឡូ-វីឡ៉ាមានចំនួន ២១កន្លែង ភោជនីយដ្ឋាន អាហារដ្ឋានមានចំនួន ៣៤កន្លែង សណ្ឋាគារចំនួន ១៧កន្លែង ផ្ទះសំណាក់ចំនួន ៥៨កន្លែង ស្ប៉ាហ្សូណាចំនួន ០៣កន្លែង ខារ៉ាអូខេមានចំនួន ០៨កន្លែង ទូកនេសាទចំនួន ១៦គ្រឿង និងមណ្ឌលព័ត៌មានចំនួន ០៣កន្លែង។[៤]

## ១.១.២. ដង់ស៊ីតេប្រជាជន

### ១.១.២.១. ចំនួនប្រជាជន

នៅក្នុងខេត្តកែប ចំពោះចំនួនប្រជាជនដែលរស់នៅខេត្តនេះមានដង់ស៊ីតេប្រជាជនក្នុង ០១គីឡូម៉ែត្រការ៉េ មានចំនួនប្រមាណ ២៣៨នាក់ក្នុង ០១គីឡូម៉ែត្រការ៉េនៃផ្ទៃដីគោក។ បើយោងតាមទិន្នន័យ CDB ឆ្នាំ២០២២ សម្រាប់ប្រើប្រាស់ឆ្នាំ២០២៣ មានចំនួនគ្រួសារសរុបក្នុងឆ្នាំ២០២២ ចំនួនប្រមាណ ១០,៤៨៤គ្រួសារ ក្នុងនោះ ប្រជាជនសរុបមានចំនួនប្រមាណ ៤៤,៥២៣នាក់ (ស្រី២២,៨២២នាក់ ប្រុស២១,៧០១នាក់) និងមានទំហំ

---

[៣] គេហទំព័រ https://visitcambodia.travel/kh/province/view/64b4a484d4t2848413s2 ដកស្រង់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៤

[៤] សៀវភៅ ព័ត៌មានរាជធានីខេត្ត, បោះពុម្ពថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤, ទំព័រទី២២៤-២២៥

គ្រួសារជាមធ្យមប្រមាណ ៤,២៤នាក់ ដោយមានការចែកជាក្រុមដូចជាក្រុមអាយុចាប់ពី ០-១៤ឆ្នាំមានចំនួនប្រមាណ ១៣,២៧២នាក់ (ស្មើនឹង៣០%) ក្រុមអាយុចាប់ពី ១៥-១៧ឆ្នាំមានចំនួនប្រមាណ ៣,៣៩១នាក់ (ស្មើនឹង៨%) ក្រុមអាយុចាប់ពី ១៨-៦០ឆ្នាំឡើងមានចំនួនប្រមាណ ២៣,៧៦១នាក់ (ស្មើនឹង៥៣.៣%) និងក្រុមអាយុចាប់ពី ៦១ឆ្នាំឡើងទៅមានចំនួនប្រមាណ ៤,០៩៩នាក់(ស្មើនឹង ៩.២០%)។[៥]

### ១.១.២.២. ជីវភាពប្រជាជន

យោងតាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ពាក្យថាជីវភាព សំដៅដល់ភាពនៃការរស់នៅ និងការចិញ្ចឹមជីវិត។ ដូចនេះជីវភាពប្រជាជន គឺបានសំដៅទៅលើការរស់នៅ បែបបទរបៀបនៃការចិញ្ចឹមជីវិតរបស់ប្រជាជននៅតាមតំបន់ ភូមិសាស្ត្រ និងសង្គមជាដើម។ ទន្ទឹមនឹងនោះដែរការរស់នៅ និងការចិញ្ចឹមជីវិតរបស់ប្រជាជននៅក្នុងខេត្តកែប មានការទាក់ទងទៅនឹងវិស័យកសិកម្ម ការនេសាទមានលក្ខណៈអំណោយផលពីធម្មជាតិដោយមានប្រជាជនប្រមាណ ៧៦,៦% ប្រកបរបរកសិកម្មដោយប្រជាជនភាគច្រើន គឺបានធ្វើស្រែ ធ្វើចំការ ដាំដុះដំណាំ ការចិញ្ចឹមសត្វ នេសាទ វារីវប្បកម្ម ការអភិរក្សធនធានជលផល ការពារធនធានព្រៃឈើ និងសត្វព្រៃ ដោយមានការពាក់ព័ន្ធជាមួយនឹងគ្នានេះ ខេត្តកែបក៏សម្បូរទៅដោយសកម្មភាពសិប្បកម្មចំណីអាហារដែលជាខ្សែច្រវាក់ផលិតកម្មបន្តពីវិស័យកសិកម្ម និងនេសាទដូចជាសិប្បកម្មកែច្នៃផលិតផលសមុទ្រ សិប្បកម្មផលិតទឹកត្រី សិប្បកម្មផ្សេងៗជាច្រើនទៀត ពិសេសផលិតកម្មអំបិលសម្រាប់ផ្គត់ផ្គង់ដល់អាជីវកម្មក្នុងមូលដ្ឋានរបស់ប្រជាជន អាជីវករ និងភ្ញៀវទេសចរជាដើម។ សកម្មភាពទាំងនេះ គឺមានសក្ដានុពលយ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យកសិទេសចរណ៍ដើម្បីបើកឱ្យមានប្រភពចំណូលបន្ថែមសម្រាប់កសិករ សិប្បករ និងការលើកកម្ពស់ពង្រឹងនូវមូលដ្ឋាននៃវិស័យទេសចរណ៍ក្នុងខេត្តកែបផងដែរ។[៦]

## ១.២. រចនាសម្ព័ន្ធរដ្ឋបាលខេត្តកែប

ក្នុងការដឹកនាំខេត្តកែប ពិតជាចាំបាច់ណាស់ក្នុងការរៀបចំឱ្យបាននូវរចនាសម្ព័ន្ធដឹកនាំ និងការគ្រប់គ្រងខេត្តមួយនេះដោយទទួលបាននូវការយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់ជាទីបំផុត។ ជាទូទៅដោយយោងតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រចនាសម្ព័ន្ធរដ្ឋបាលខេត្តកែបត្រូវបានបែងចែកជាពីរផ្សេងៗពីគ្នាដែលក្នុងនោះរួមមានក្រុមប្រឹក្សាខេត្តកែប និងគណៈអភិបាលខេត្តកែប។ ចំណែកឯស្ថានប័នទាំងពីរនេះមានដែនសមត្ថកិច្ច និងតួនាទីខុសៗគ្នា ព្រមទាំងមានទំនាក់ទំនងគ្នាដោយផ្អែកតាមច្បាប់។

[៥] សៀវភៅ ព័ត៌មានរាជធានីខេត្ត, បោះពុម្ពថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤, ទំព័រទី២២១-២២២

[៦] ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣, ទំព័រទី៦

### ១.២.១. សមាសភាព

#### ១.២.១.១. ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តកែប ត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតជាអសកលដែលមានអាណត្តិ ០៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងត្រូវផុតកំណត់នៅ០៥ឆ្នាំបន្ទាប់នៃការបោះឆ្នោត។ នៅក្នុងអំឡុងពេលចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាចាស់ដែលចប់អាណត្តិមានសិទ្ធិអនុវត្តន៍តែទៅលើកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ។ ក្រុមប្រឹក្សាខេត្តមានប្រធាន ០១រូប ហើយជាបេក្ខជនដែលឈរនៅលំដាប់លេខរៀងលើគេនៃបញ្ជីឈ្មោះបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។ រីឯចំនួនក្រុមប្រឹក្សាត្រូវបានកំណត់ផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ។ ជាពិសេសក្រុមប្រឹក្សា គឺជាតំណាងនឹងជាអ្នកបម្រើឱ្យផលប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[៧]

#### ១.២.១.២. គណៈអភិបាលខេត្ត

គណៈអភិបាលខេត្តរួមមាន អភិបាលខេត្ត ០១រូប និងអភិបាលរងខេត្តចំនួន ១០រូប ដែលអភិបាល និងអភិបាលរងខេត្តមានអាណត្តិការងារមិនលើសពី ០៤ឆ្នាំ ហើយមិនអាចត្រូវបានឈរឈ្មោះសម្រាប់អាណត្តិទី២របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចឡើយ។ ចំពោះការតែងតាំងគណៈអភិបាលខេត្តត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយជ្រើសរើសពីចំណោមមន្ត្រីរាជការទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ឬក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃត្រូវតែមានលក្ខណៈសម្បត្តិដូចជា៖

- មានឋានន្តរសក្តិចាប់ពីវរមន្ត្រីឡើងទៅ
- មានអាយុចាប់ពី៣៥ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- ត្រូវមានបទពិសោធន៍លើការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួន ០៧ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។[៨]

---

[៧] ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨, មាត្រា១៤-១៩

[៨] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨, មាត្រា១៣៩, ១៤២, ១៤៧

### ១.២.២. តួនាទី និងភារកិច្ច

#### ១.២.២.១. ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត ត្រូវមានតួនាទីក្នុងការចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចបាននូវគោលបំណងក្នុងការបង្កើត និងការជំរុញធ្វើឱ្យមានចីរភាពទៅដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ឱ្យ និងបានធ្វើប្រតិភូកម្មតាមច្បាប់ ឬស្របតាមច្បាប់កំណត់។ ក្រុមប្រឹក្សាខេត្តមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ហើយក្រុមប្រឹក្សាត្រូវបំពេញមុខងារ ភារកិច្ចដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួនដែលត្រូវបានធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្តន៍ដោយមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- ការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ដែលត្រូវមានការប្រជុំសាមញ្ញយ៉ាងតិចចំនួន ១២ដងក្នុងមួយឆ្នាំទៅតាមប្រតិទិនដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្ត ក្រៅពីកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាក៏អាចប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់
- ការងាររៀបចំបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់វិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន
- ការងាររៀបចំវិធានការគ្រប់គ្រងផ្ទៃក្នុងត្រូវរៀបចំអនុម័តដីកាស្តីពីវិធានការគ្រប់គ្រងផ្ទៃក្នុង ដើម្បីធានាបាននូវការលើកកម្ពស់ ការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពឱ្យស្របទៅតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ការងារដាក់ចេញដីកា និងសេចក្តីសម្រេចក្រុមប្រឹក្សានឹងអាចដាក់ចេញដីកា ដើម្បីកំណត់ហាមឃាត់ ឬត្រួតពិនិត្យលើសកម្មភាព នីតិវិធី ឬកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពនៃមុខងារព្រមទាំងធនធានរបស់ខ្លួនដោយផ្អែកទៅតាមតម្រូវការនៃច្បាប់ ដែលស្របទៅតាមលិខិតបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន និងតម្រូវការក្នុងមូលដ្ឋាន
- ក្រុមប្រឹក្សាខេត្តត្រូវតែមានគណនេយ្យភាពផ្ទាល់ចំពោះប្រជាពលរដ្ឋ ដើម្បីធ្វើសេចក្តីសម្រេចធានាឱ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការអង្កេតទៅលើករណីទាំងឡាយដែលបានផ្តល់សារៈសំខាន់ដល់ប្រជាពលរដ្ឋក្នុងការផ្សព្វផ្សាយលទ្ធផលអង្កេតការណ៍ ព្រមទាំងផ្តល់ការណែនាំអំពីការអនុវត្តទៅដល់គណៈអភិបាល និងអភិបាលរង

- ការងារផែនការអភិវឌ្ឍន៍ ០៥ឆ្នាំ និងកម្មវិធីវិនិយោគ ០៣ឆ្នាំរំកិល ក្រុមប្រឹក្សាត្រូវតែពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាផ្សេងៗ និងអ្នកពាក់ព័ន្ធដោយត្រូវគោរពទៅតាមគោលការណ៍ តម្លាភាព ការចូលរួមពិគ្រោះយោបល់ឆ្លើយតបទៅនឹងតម្រូវការគណនេយ្យភាព ប្រសិទ្ធភាព និងការធានាសមធម៌
- ការអនុវត្តមុខងារ សំដៅលើការបំពេញការងារប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព
- ការងារគ្រប់គ្រងបុគ្គលិក ការរៀបចំផែនការបុគ្គលិក ការតែងតាំង និងការបញ្ចប់មុខតំណែង នាយករដ្ឋបាល ប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែល និងការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិកជាដើម
- ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល។[៩]

**១.២.២.២. គណៈអភិបាលខេត្ត**

គណៈអភិបាលខេត្ត ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្តអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងសិទ្ធិអំណាចបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាខេត្តដើម្បីឱ្យក្រុមប្រឹក្សាខេត្តធ្វើការពិភាក្សា និងអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ។ អភិបាលខេត្តមានតួនាទីជាតំណាងរាជរដ្ឋាភិបាល និងជាតំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលដោយមានតួនាទីដូចជា៖

- ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងធានាឱ្យមាននូវការអនុវត្តច្បាប់ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋ
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពខេត្តក្នុងការដឹកនាំនឹងសម្របសម្រួលមន្ទីរ អង្គភាពដែលពាក់ព័ន្ធជាមួយរដ្ឋបាលក្រុង ស្រុក ឃុំ និងសង្កាត់ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងខេត្ត
- ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានមន្ទីរ អង្គភាពរបស់ក្រសួងស្ថាប័ននានាតាមគោលការណ៍កំណត់

[៩] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨, មាត្រា២៩-៣០, ៣៤-៣៧, ៥៣-៥៤, ៧១-៧៤

- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្តឱ្យអនុវត្តន៍តួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមវិធានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទីរ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័ន ដែលប្រចាំនៅខេត្តក្នុងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរអង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល វិធានច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួល និងតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការធ្វើសមាហរណកម្មផែនការថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាខេត្ត។

ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុនក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្ត។ ក្នុងករណីដែលមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពណាមួយ អភិបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលដែលមិនគាំទ្រនោះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដើម្បីពិនិត្យពិចារណា និងចាត់វិធានការដូចខាងក្រោម៖

- ក្នុងករណីដែលរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីឯកភាពតាមរបាយការណ៍របស់អភិបាលខេត្ត រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្តូរបេក្ខភាពដែលបានស្នើឡើងឱ្យបានសមស្រប
- ក្នុងករណីដែលរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីស្រាវជ្រាវរកឃើញថា ហេតុផលដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលខេត្តពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលខេត្តដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ
- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងប្រធានមន្ទីរ អង្គភាព ឬអ្នកទទួលខុសត្រូវទីភ្នាក់ងារណាដែលប្រព្រឹត្តខុសហើយមិនអាចធ្វើយុត្តិកម្មបាន

- ករណីដែលមិនមាននូវការឯកភាពរវាងអភិបាលខេត្តជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីលើបេក្ខភាពដែលស្នើតែងតាំងរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារឱ្យធ្វើការកែលំអឡើងវិញជាបន្ទាន់នៅពេលពិនិត្យឃើញមានភាពមិនប្រក្រតីនៅក្នុងមន្ទីរ អង្គភាព និងទីភ្នាក់ងារណាមួយ ឬមានការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយនោះ
- ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីនៃមន្ទីរ អង្គភាព និងទីភ្នាក់ងារសាមីក្នុងករណីដែលប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតី ឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរខ្លាំង។

ពិសេស ដើម្បីធានាឱ្យអភិបាលខេត្តអនុវត្តន៍នូវតួនាទី និងភារកិច្ចខាងលើនេះ ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្តទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវដាក់ជូនអភិបាលខេត្តដើម្បីពិនិត្យផ្តល់យោបល់ជាមុន។ ប្រសិនបើមានការឯកភាព អភិបាលខេត្តតែត្រូវចុះហត្ថលេខាទៅលើរបាយការណ៍នេះជាមួយប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារមួយនោះ។ ចំពោះសេចក្តីរាយការណ៍របស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្ត ត្រូវចម្លងជូនសាលាខេត្ត។[១០]

## ១.៣. រចនាសម្ព័ន្ធមន្ទីរទេសចរណ៍ខេត្តកែប

### ១.៣.១. សមាសភាពមន្ទីរទេសចរណ៍

នៅតាមក្រុង ស្រុក ខណ្ឌនីមួយៗដែលមានសក្តានុពលទេសចរណ៍ត្រូវមានការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ មួយដែលទទួលបន្ទុកអនុវត្តន៍ និងសម្របសម្រួលសកម្មភាពនានារបស់ក្រសួងក្រោមការគ្រប់គ្រងរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត។ មន្ទីរទេសចរណ៍រខេត្តកែបបានដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។ ទន្ទឹមនឹងនេះដែរ ការិយាល័យនីមួយៗ ក៏មានការដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

មន្ទីរទេសចរណ៍ខេត្តកែប មានការិយាល័យចំណុះចំនួន ០៧ ដូចតទៅ៖

[១០] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា២៩-៣៥

- ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ សន្តិសុខ និងសុវត្ថិភាពទេសចរណ៍
- ការិយាល័យផែនការវិនិយោគអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- ការិយាល័យអប់រំបណ្តុះបណ្តាល
- ការិយាល័យព័ត៌មានទេសចរណ៍ និងផ្សព្វផ្សាយ
- ការិយាល័យគ្រប់គ្រងឆ្នេរសមុទ្រ
- ការិយាល័យទីក្រុងស្អាត។

### ១.៣.២. តួនាទី និងភារកិច្ចមន្ទីរទេសចរណ៍

មន្ទីរទេសចរណ៍ខេត្ត គឺជាសេនាធិការឱ្យក្រសួងទេសចរណ៍ដែលទទួលបន្ទុកអនុវត្តន៍ តាមដានការគ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃ រៀបចំផែនការអភិវឌ្ឍន៍ពង្រឹងគុណភាពផលិតផល អាជីវកម្ម និងសេវាកម្មទេសចរណ៍ សំដៅដល់ការធានាគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ដែលប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនោះ មន្ទីរទេសចរណ៍ មានតួនាទី និងភារកិច្ចដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូចជា៖

- ដឹកនាំ គ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍន៍វិស័យទេសចរណ៍នៅថ្នាក់ក្រោមជាតិ
- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស និងផែនការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ទាំងនៅក្នុងរដ្ឋ និងឯកជននៃវិស័យទេសចរណ៍ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច
- គ្រប់គ្រង ត្រួតពិនិត្យព័ត៌មានទេសចរណ៍ និងជំរុញចលនាទេសចរណ៍ក្នុងស្រុក
- គ្រប់គ្រង និងថែរក្សាតំបន់ទេសចរណ៍ មណ្ឌលទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ កសិទេសចរណ៍ និងអេកូទេសចរណ៍ក្នុងរាជធានីខេត្ត
- គ្រប់គ្រង រៀបចំក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់មុខតំណែង គ្រឿងឥស្សរយស និងប្រព័ន្ធលាភការផ្សេងៗទៀតរបស់មន្ត្រីរាជការក្រោមឱវាទ
- គ្រប់គ្រងចំណូលចំណាយហិរញ្ញវត្ថុនៅក្នុងមន្ទីរស្របតាមការកំណត់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សិក្សាស្រាវជ្រាវទីផ្សារ និងផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ដែលមាននៅក្នុងមូលដ្ឋាន

- អនុវត្តន៍គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពដើម្បីលើកកម្ពស់ និងជំរុញចលនាប្រឡងប្រណាំងក្នុងវិស័យទេសចរណ៍ព្រមទាំងស្តង់ដាទេសចរណ៍
- ទាក់ទងជាមួយនឹងវិនិយោគិន ដៃគូអភិវឌ្ឍន៍នានាក្នុងគោលបំណងធ្វើឱ្យមានភាពទាក់ទាញការវិនិយោគ និងការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត
- រួមចំណែកការពារ ថែរក្សាធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងទំនៀមទម្លាប់ប្រពៃណី ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត
- អនុវត្តន៍គោលនយោបាយ គោលការណ៍ ប្រកាស សារាចរ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតរបស់ក្រសួងទេសចរណ៍ ដើម្បីរក្សានិរន្តរភាពនៃវិស័យទេសចរណ៍ និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- ជំរុញការអនុវត្តយន្តការ និងនីតិវិធីនៅថ្នាក់ក្រោមជាតិដើម្បីធ្វើការពិនិត្យ ការវាយតម្លៃលើសំណើសុំដែលអាជ្ញាបណ្ណទេសចរណ៍ តាមលក្ខណៈវិនិច្ឆ័យដែលកំណត់ទាំងការផ្តល់ ការបន្តការលុបចោលការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ ការសុំបិទអាជីវកម្ម សេវាកម្ម និងទេសចរណ៍ផ្សេងៗទៀតស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- លើកសំណើផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងក្នុងការកែលំអ និងការអភិវឌ្ឍលើវិស័យទេសចរណ៍ក្នុងរាជធានីខេត្តដោយមានការគាំទ្រពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន
- មន្ទីរទេសចរណ៍ដែលមានឆ្នេរសមុទ្រ កោះ ត្រូវចូលរួមគ្រប់សកម្មភាពក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ កោះ ស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្ត
- សហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខ័ណ្ឌទាំងថ្នាក់អាស៊ាន តំបន់ និងអន្តរជាតិ
- សហការជាមួយក្រសួងស្ថាប័នរដ្ឋបាលរាជធានីខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធក្នុងការអនុវត្តវិធានការចំពោះប្រតិបត្តិករទេសចរដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់ស្តីពីទេសចរណ៍ និងបទប្បញ្ញត្តិ
- សហការគ្រប់គ្រង ត្រួតពិនិត្យអាជីវកម្ម ផលិតកម្ម សេវាកម្ម និងប្រតិបត្តិករទេសចរ ឱ្យធានាបាននូវប្រសិទ្ធភាព គុណភាព របៀបរៀបរយ អនាម័យ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងការគ្រប់គ្រង និងរៀបចំចងក្រងទិន្នន័យស្ថិតិទេសចរណ៍

- សហការពង្រឹង និងចាត់វិធានការចាំបាច់ទាក់ទងនឹងការរក្សាសន្តិសុខ សុវត្ថិភាពទេសចរណ៍ កិច្ចការសង្គ្រោះបឋមបន្ទាន់នៅតាមតំបន់គោលដៅនានា។[១១]

## ១.៤. មូលហេតុដែលជំរុញឱ្យមានការរៀបចំតំបន់ទេសចរណ៍ខេត្តកែប

ជាការពិតណាស់ ក្នុងការរៀបចំតំបន់ទេសចរណ៍នីមួយៗ សុទ្ធតែត្រូវឆ្លងកាត់នូវការសិក្សាស្រាវជ្រាវជាមុនអំពីមូលហេតុនានាដែលនាំឱ្យមានការរៀបចំ និងកំណត់នូវផែនការសម្រាប់យកមកអភិវឌ្ឍន៍។ ខេត្តកែបគឺជាខេត្តមួយដែលសម្បូរដោយធនធានធម្មជាតិ និងមានភូមិសាស្រ្តល្អ ព្រមទាំងសម្បូរនូវតំបន់ទេសចរណ៍ជាច្រើនកន្លែងដែលមានសក្តានុពលផងដែរ។ ដើម្បីធ្វើការអភិវឌ្ឍបានគេត្រូវសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់លាស់អំពីមូលហេតុចម្បងទាំង ០៤ធំៗដែលទាក់ទងនឹងកំណើនតំបន់ទេសចរណ៍ធម្មជាតិ កំណើនតំបន់ទេសចរណ៍វប្បធម៌ កំណើនតំបន់ទេសចរណ៍កែច្នៃ និងកំណើនភ្ញៀវទេសចរ។

### ១.៤.១. កំណើនតំបន់ទេសចរណ៍ធម្មជាតិ

ខេត្តកែប ជាខេត្តដែលសម្បូរទៅដោយតំបន់ទេសចរណ៍ធម្មជាតិ ដែលមានកន្លែងទេសចរណ៍ធម្មជាតិជាច្រើនសម្រាប់ទទួលភ្ញៀវមកលេងកម្សាន្តមានដូចជាឆ្នេរអង្កាល ឆ្នេរស្រីស វាលលំហែជ្រោយដូង ឧទ្យានជាតិព្រះរាជដំណាក់ ភ្នំវល្លិ៍ ផ្លូវព័ទ្ធភ្នំកែប ភូមិនេសាទ ព្រៃកោងកាង ស្រែអំបិល កំពង់ផែកោះទន្សាយ កោះកុក កោះម្ទេស កោះស្វាយ កោះត្បាល់ កោះហាលត្រី កោះស្វាយព្រៃ កោះសារ៉ាង កោះពោធិ៍ កោះអង្រុង កោះស្ងួត កោះម៉ាកប្រាង និងកោះអាចម៍សេះជាដើម។ ស្របគ្នានេះតំបន់ទេសចរណ៍ធម្មជាតិក៏កំពុងតែធ្វើការអភិវឌ្ឍរៀបចំកែច្នៃ និងជាមូលហេតុដែលនាំឱ្យមានការទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិ មកទស្សនាកម្សាន្តយ៉ាងច្រើនមិនចេះដាច់ និងជាកត្តាមួយដ៏សំខាន់ដែលរដ្ឋាភិបាលតែងតែបានគិតគូរយកមករៀបចំ និងអភិវឌ្ឍន៍។[១២]

### ១.៤.២. កំណើនតំបន់ទេសចរណ៍កែច្នៃ

ទន្ទឹមនឹងការកើនឡើងនៃតំបន់ទេចរណ៍ធម្មជាតិ អ្វីដែលគួរឱ្យកត់សម្គាល់គឺការទទួលបានអ្នកវិនិយោគមកវិនិយោគនៅលើតំបន់ទេសចរណ៍ធម្មជាតិ ដើម្បីធ្វើការកែច្នៃតំបន់ទាំងនោះឱ្យក្លាយជាតំបន់ទេសចរណ៍កែច្នៃវិញម្តង ដោយជាក់ស្តែងតំបន់ទេសចរណ៍កែច្នៃបច្ចុប្បន្នមានចំនួនប្រមាណ ០៧កន្លែង ដោយនៅក្នុងនោះមាន ០៥កន្លែងជាកម្មសិទ្ធិឯកជន (រ៉ក់រ៉ូយ៉ាល់ ផ្សារក្តាម សួនមេអំបៅ ឆ្នេរថ្មី និងថ្ងៃបាំងឆ័ត្រ)។ ទន្ទឹមនឹងនោះផងដែរ

---

[១១] ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត, លេខ ១២៣ ប្រ.ក, ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩, ប្រការ៣-៥

[១២] គេហទំព័រ https://www.kampucheathmey.com/local-news/238355 ដកស្រង់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

គឺមានភ្ញៀវទេសចរភាគច្រើនបានស្គាល់នូវតំបន់ទេសចរណ៍កែច្នៃនៅក្នុងខេត្តនេះ ជាពិសេសការទទួលបាននូវការចាប់អារម្មណ៍ពីសំណាក់ភ្ញៀវទេសចរមកពីទីជិត និងទីឆ្ងាយដែលភាគច្រើនតែងតែមកទស្សនាកម្សាន្តនៅតំបន់ទេសចរណ៍កែច្នៃនេះម្តងហើយម្តងទៀត ដែលជាមូលហេតុធ្វើឱ្យមន្ទីរ អង្គភាព និងស្ថាប័នពាក់ព័ន្ធផ្សេងៗកំពុងតែបន្ថែមនូវការពង្រឹងក្នុងការយកចិត្តទុកដាក់ដើម្បីធ្វើការរៀបចំជាបន្តបន្ទាប់។

### ១.៤.៣. កំណើនតំបន់ទេសចរណ៍វប្បធម៌

ជាក់ស្តែងនៅក្នុងតំបន់ទេសចរណ៍ខេត្តកែប គេបានកត់សម្គាល់ថា ក្នុងខេត្តនេះមានការកើនឡើងនូវទីតាំងតំបន់ទេសចរណ៍វប្បធម៌ដែលតំបន់ទាំងនេះត្រូវបានរៀបចំ និងបានក្លាយជាកន្លែងទេសចរណ៍មួយបែបដែលទទួលបានការទាក់ទាញពីសំណាក់ភ្ញៀវទេសចរពីគ្រប់ទិសទីមកទស្សនា ដោយភ្ញៀវតែងតែចង់ដឹងពីវប្បធម៌ប្រវត្តិសាស្ត្រ អមជាមួយនឹងទេសភាពធម្មជាតិដ៏គួរឱ្យចាប់អារម្មណ៍ដែលកត្តាទាំងនេះហើយជាហេតុជំរុញឱ្យមានការរៀបចំ អភិវឌ្ឍន៍បន្ថែមទៀតនៅតំបន់ទេសចរណ៍ខេត្តកែបផងដែរ។ ដោយយោងតាមការស្រាវជ្រាវបានបង្ហាញថាតំបន់ទេសចរណ៍វប្បធម៌ទាំងអស់នេះ មានឈ្មោះ និងទីតាំងដូចជា៖

- វត្តភ្នំសសៀរ មានទីតាំងនៅភូមិចំបក់ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប
- វត្តវិបស្សនាធុរៈ មានទីតាំងនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
- វត្តភ្នំលាវ មានទីតាំងនៅភូមិភ្នំលាវ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប
- វត្តកំពង់ត្រឡាច មានទីតាំងនៅភូមិកំពង់ត្រឡាច សង្កាត់កែប ក្រុងកែប ខេត្តកែប
- សារៈមន្ទីរជាតិកែប មានទីតាំងនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
- វត្តកែប មានទីតាំងនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប។[១៣]

### ១.៤.៤. កំណើនប្រជាជន

ជាទូទៅសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុងមានមូលហេតុ ០៣សំខាន់ៗ គឺកំណើនប្រជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកតំបន់នេះគឺជាតំបន់នៃទីប្រជុំជនរស់នៅ។ ដូច្នេះហើយកំណើនប្រជាជននៅក្នុងទីក្រុងជាលក្ខណៈធម្មជាតិបានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកឯកំណើនដោយសារចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី

---

[១៣] គេហទំព័រ https://www.kampucheathmey.com/local-news/238355 ដកស្រង់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

ដែលពីមុនមកតំបន់នេះគ្រាន់តែជាទីជនបទដែលជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។[14] សម្រាប់ខេត្តកែបទាំងមូល កំណើនប្រជាជនក្នុងមួយឆ្នាំៗ មានការកើនឡើងឥតឈប់ឈរទៅតាមលក្ខណៈធម្មជាតិក៏ដូចជាការចំណាកស្រុកពីខេត្តដទៃមកកាន់ខេត្តកែបដោយសារខេត្តនេះជាគោលដៅ និងជាតំបន់ទេសចរណ៍ដ៏មានសក្តានុពលដោយភាគច្រើនគឺមកដើម្បីមករកស៊ី ធ្វើការ និងប្រកបអាជីវកម្មជាដើម។ បន្ថែមពីនេះ កំណើនប្រជាជនខេត្តកែបគឺបានកើនឡើងតាមរយៈការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី ដោយសារតំបន់នេះជាទីកន្លែងដែលត្រូវបានរដ្ឋាភិបាលកំណត់ថាជាគោលដៅទេសចរណ៍មួយដែលត្រូវធ្វើការអភិវឌ្ឍឱ្យសមស្របតាមស្ថានភាព តម្រូវការ និងទីផ្សារបច្ចុប្បន្ន។ បើយោងតាមការធ្វើជំរឿនប្រជាជនរបស់ខេត្តកែបបានបង្ហាញថាចំនួនប្រជាជនខេត្តកែបនៅក្នុងឆ្នាំ២០១៩មានការកើនឡើងដល់ ៤២,៦៦៥នាក់ ដោយក្នុងនោះមានគ្រួសារប្រមាណ ៩,៦០៥គ្រួសារ រហូតមកដល់ឆ្នាំ២០២២ផ្អែកតាមទិន្នន័យ CDB សម្រាប់ប្រើប្រាស់ឆ្នាំ២០២៣ បានបញ្ជាក់ថាចំនួនគ្រួសារសរុបក្នុងឆ្នាំ២០២២វិញ គឺមានប្រមាណ ១០,៤៨៤គ្រួសារ និងប្រជាជនសរុបប្រមាណ ៤៤.៥២៣នាក់។[15]

### ១.៤.៥. កំណើនភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ

បើគិតនៅមុនពេលកើតនូវវិបត្តិនៃជំងឺកូវីដ-១៩បន្តិច សង្កេតឃើញថាសកម្មភាពក្នុងវិស័យទេសចរណ៍ខេត្តកែបបានរីកដុះដាលគួរឱ្យកត់សម្គាល់ដោយមានការកើនឡើងនូវសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន សកម្មភាពសេវាកម្មកម្សាន្តជាច្រើនទៀតដែលជាទីទាក់ទាញសម្រាប់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។

បន្ទាប់មកនៅក្នុងអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩ ដោយមានការរីករាលដាលដែលបណ្តាលឱ្យមានការបិទខ្ទប់តាមច្រកព្រំដែន ជើងហោះហើរ ព្រមទាំងតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ដែលបានធ្វើឱ្យសក្តានុពលរបស់ខេត្តកែបទាំងមូលមិនសូវទទួលបាននូវភ្ញៀវទេសចរមកកម្សាន្តនៅតាមតំបន់នៃខេត្តនេះទេ ជាពិសេសការធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិ។ ដោយឡែកនៅក្នុងឆ្នាំ២០២២ ប្រទេសកម្ពុជាបានបើកដំណើរការគ្រប់វិស័យឡើងវិញ ចំណែកឯវិស័យទេសចរណ៍នៅក្នុងខេត្តនៅតាមតំបន់ឆ្នេរ គឺទទួលបានភ្ញៀវទេសចរអន្តរជាតិមកកំសាន្តមានចំនួនប្រមាណ ៤២៤,១៨៩នាក់កើនឡើង៣០០.៦% និងភ្ញៀវទេសចរជាតិមានចំនួន ៧,១១៥,៨៥៦នាក់កើនឡើង២៤៧% បើធៀបនឹងឆ្នាំ២០២១។ ទន្ទឹមនឹងនោះ ខេត្តកែបទទួលបានភ្ញៀវទេសចរអន្តរជាតិមានចំនួនប្រមាណ ១៩,៥៥៧នាក់មានការកើនឡើង ២២៥.៧៨% និងភ្ញៀវទេសចរជាតិមានចំនួន ១,២៩៧,៤៣២នាក់មានការកើនឡើង ១២៣.៥៦% បើធៀបនឹងឆ្នាំ២០២១។[16] បើយោងតាមទិន្នន័យដែលទទួលបានពីការអង្កេត

[14] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ិន សកក្កដា បោះពុម្ពឆ្នាំ២០២៤, ទំព័រទី១៩

[15] សៀវភៅ ព័ត៌មានរាជធានីខេត្ត, បោះពុម្ពថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤, ទំព័រទី២២១

[16] ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣, ទំព័រទី២-៣

តំបន់ដែលទទួលបានការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកកម្សាន្តនៅខេត្តទាំងមូលរួមមានកិត្តិនាម ឆ្នេរលេងទឹកប្រមាណ ៨២.៤០% ធម្មជាតិប្រមាណ ៧៣.៩០% កោះប្រមាណ ៤៩.៣០% ព្រៃភ្នំប្រមាណ ៣៥.៥% ភាពស្ងប់ស្ងាត់ប្រមាណ ២២.៤០% ប្រវត្តិសាស្ត្រប្រមាណ ១៩.៨០% ប្រពៃណីវប្បធម៌ប្រមាណ ១៩.៣០% ចំការម្រេចប្រមាណ ១៧.៧០% ព្រៃកោងកាងប្រមាណ ១៣.៨០% ស្រែអំបិលប្រមាណ ១៣.៧០% ឯកជនភាពប្រមាណ ៨.៨០% សំណង់បេតិកភណ្ឌប្រមាណ ៦.៣០% ទីប្រជុំជនប្រមាណ ៤.៦០% និងផ្សេងៗទៀតប្រមាណ ១.៦០%។ ហើយនាពេលអនាគត ការអភិវឌ្ឍគោលដៅកម្សាន្តទាំងអស់ខាងលើឱ្យកាន់តែមានគុណភាពល្អមានភាពទាក់ទាញ ពិសេសអាចពន្យាពេលនៃការស្នាក់នៅរបស់ភ្ញៀវបានជាច្រើនថ្ងៃបន្ថែមទៀតផង។[១៧]

---

[១៧] ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣, ទំព័រទី៨៦

# ជំពូកទី២
# ការអភិវឌ្ឍតំបន់ទេសចរណ៍
# ខេត្តកែបឆ្នាំ២០២០-២០២៣

# ជំពូកទី២

# ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបឆ្នាំ២០២០-២០២៣

## ២.១. ផែនការអភិវឌ្ឍន៍តំបន់ទេសចរណ៍ខេត្តកែប

ខេត្តកែបមានភូមិសាស្ត្រស្ថិតក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមុទ្រ ឆ្នេរ ព្រៃក ព្រៃកោងកាង ស្រែអំបិល វាលទំនាប ខ្ពង់រាប ភ្នំ គម្របព្រៃ ឧទ្យានជាតិ និងតំបន់ភ្នំវល្លិ៍ដែលមានលក្ខណៈអំណោយផលខ្ពស់សម្រាប់ដំណាំម្រេច និងធូរេន។ ខេត្តកែបជាទីក្រុងអេកូទេសចរណ៍ធម្មជាតិប្រណិតកម្រិតខ្ពស់នៃតំបន់ឆ្នេរសមុទ្រកម្ពុជា និងជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក មានកេរ្តិ៍ឈ្មោះល្បីល្បាញ ហើយក្នុងនោះដែរ ខេត្តកែបក៏ជាគោលដៅទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រដែលមានសក្តានុពលសម្បូរបែប មានភ្ញៀវទេសចរជាតិ និងអន្តរជាតិរាប់លាននាក់ដែលបានមកទស្សនាលំហែកម្សាន្តពីមួយឆ្នាំទៅមួយឆ្នាំ។[១៨] តាមរយៈសក្តានុពល និងភាពសម្បូរបែបនៃធនធានធម្មជាតិដែលមាននៅក្នុងខេត្តកែប ព្រមទាំងផ្អែកតាមតម្រូវការចាំបាច់របស់សង្គមផងដែរនោះ ទើបរាជរដ្ឋាភិបាលបានចាត់ទុកថាខេត្តកែប គឺជាខេត្តទេសចរណ៍មួយដ៏មានសក្តានុពលព្រមទាំងអាចជួយបង្កើនសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចម្រើន។ តាមហេតុផលទាំងអស់នេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតជាផែនការសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងខេត្តកែប គឺ**"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥"** ដែលបានដាក់ចេញនូវចក្ខុវិស័យ គោលបំណង និងទិសដៅនៃការអភិវឌ្ឍទេសចរណ៍ ដែលជាមូលដ្ឋានគ្រឹះនៅក្នុងផែនការសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តកែប ដើម្បីសម្រេចឱ្យបានមូលដ្ឋានគ្រឹះខាងលើ គេបានរៀបចំវិធានការ និងយុទ្ធសាស្ត្រចម្បងៗ ក្នុងការជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងការប្រែក្លាយខេត្តកែប ទៅជាគោលដៅទេសចរណ៍ប្រកបដោយការប្រកួតប្រជែងគុណភាព និងការលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋ។

### ២.១.១. យុទ្ធសាស្ត្រនៃការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែប

ដើម្បីអភិវឌ្ឍន៍នូវតំបន់ទេសចរណ៍ក្នុងខេត្តកែបឱ្យកាន់តែរីកចម្រើន និងទទួលបានលទ្ធផលស្របតាមគម្រោងផែនការដែលគ្រោងទុក រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវពីកត្តាសំខាន់ៗមួយចំនួនដូចជាសក្តានុពល ស្ថានភាពភូមិសាស្ត្រ តម្រូវការទីផ្សារ និងធនធានធម្មជាតិដែលមាននៅក្នុងខេត្តកែប ជាចុងក្រោយក៏បានសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗក្នុងការជួយជំរុញ និងធ្វើឱ្យមានប្រសិទ្ធភាពនៃការអនុវត្ត ដើម្បីធ្វើឱ្យសម្រេចបានជាលទ្ធផលនូវចក្ខុវិស័យ គោលបំណង និងទិសដៅនៃការអភិវឌ្ឍតំបន់ទេសចរណ៍ក្នុងខេត្តកែប។

[១៨] សៀវភៅ ប្លង់គោលប្រើប្រាស់ដីក្រុងកែប ចក្ខុវិស័យឆ្នាំ២០៣០, បោះពុម្ពថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨, ទំព័រទី១-២

**២.១.១.១. ចក្ខុវិស័យអភិវឌ្ឍន៍**

ផ្អែកលើសក្តានុពលនៃធនធានធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ ព្រមទាំងតម្រូវការទីផ្សារនាពេលខាងមុខ តាមរយៈ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥"** បានដាក់ចេញចក្ខុវិស័យ ផ្តោតទៅលើការអភិវឌ្ឍតំបន់ទេសចរណ៍ក្នុងខេត្តកែបឱ្យក្លាយទៅជាគោលដៅទេសចរណ៍ធម្មជាតិ និងសមុទ្រសម្រាកកម្សាន្តបែបប្រណិតកម្រិតខ្ពស់។ ការអនុវត្តផែនការនេះដែរនឹងត្រូវប្រកាន់យកកិច្ចគាំពារទៅលើបរិស្ថានធម្មជាតិជាចម្បង ដែលអាចជួយកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់ទៅលើបរិស្ថាន ធម្មជាតិ ព្រមទាំងធនធានជីវចម្រុះដ៏សំខាន់របស់ខេត្តកែប។ ដើម្បីសម្រេចចក្ខុវិស័យអភិវឌ្ឍន៍តំបន់ទេសចរណ៍ខេត្តកែបក្នុងផែនការមេបានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗចំនួន ០៣ដូចជា៖

**ក. យុទ្ធសាស្ត្រអភិវឌ្ឍន៍ប៉ូលទេសចរណ៍ខេត្តកែប** សំដៅលើយុទ្ធសាស្ត្រអភិវឌ្ឍប៉ូលទេសចរណ៍ក្នុងខេត្តកែបដែលមាន ០៤តំបន់ គឺប៉ូលទេសចរណ៍តំបន់ក្រុងកែបចាស់ត្រូវអភិវឌ្ឍន៍ទៅជាទីក្រុងធម្មជាតិក្នុងឧទ្យានដ៏ប្រណិតកម្រិតពិភពលោក រីឯប៉ូលទេសចរណ៍តំបន់ឆ្នេរអង្កោលត្រូវអភិវឌ្ឍន៍ទៅជាតំបន់ទេសចរណ៍ឆ្នេរសមុទ្រធម្មជាតិបែបទំនើប និងប៉ូលទេសចរណ៍តំបន់ភ្នំវល្លិ៍ គឺអភិវឌ្ឍន៍ទៅជាតំបន់កសិទេសចរណ៍ ទេសចរណ៍ធម្មជាតិ និងប្រវត្តិសាស្ត្រ ចំណែកឯការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់សមុទ្រ និងប្រជុំកោះ ត្រូវធ្វើការអភិវឌ្ឍឱ្យក្លាយទៅជាតំបន់ទេសចរណ៍សមុទ្រកោះប្រណិត។ សម្រាប់ប៉ូលទេសចរណ៍ទាំង០៤នេះនឹងត្រូវអភិវឌ្ឍន៍ឱ្យមានផលិតផលទេសចរណ៍ថ្មីៗ ផ្អែកតាមសក្តានុពលនៃប៉ូលនីមួយៗដែរមាន។

**ខ. យុទ្ធសាស្ត្រលើកកម្ពស់ការវិនិយោគ និងការផ្សព្វផ្សាយ** សំដៅទៅលើយុទ្ធសាស្ត្រក្នុងការលើកម្ពស់ដល់ការវិនិយោគដែលចាំបាច់ត្រូវមានការចូលរួមពីអ្នកវិនិយោគទាំងនៅក្នុងស្រុក និងពីបរទេសនៅគ្រប់មជ្ឈដ្ឋានក្នុងការជួយជំរុញដល់ការរីកលូតលាស់ ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តកែប ទន្ទឹមនឹងនេះ យើងត្រូវរៀបចំឱ្យមានយន្តការនៃការផ្សព្វផ្សាយដ៏មានប្រសិទ្ធភាព ដើម្បីទាក់ទាញដល់អ្នកវិនិយោគ និងលើកកម្ពស់កិត្តិនាមខេត្តកែបឱ្យទៅជាគោលដៅទេសចរណ៍ប្រកបដោយគុណភាពកម្រិតពិភពលោក។

**គ. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគាំទ្រនានា** មានន័យថា ដើម្បីអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងខេត្តកែបបានទៅមុខ ត្រូវតែមានវិស័យផ្សេងៗដែលជួយគាំទ្រទើបផែនការនេះអាចដំណើរការទៅមុខបាន ដោយយោងតាមហេតុផលបែបនេះហើយ រាជរដ្ឋាភិបាលកម្ពុជាបានសិក្សាស្រាវជ្រាវ ស្វែងយល់ពីភាពខ្វះខាត និងបញ្ហាប្រឈមមួយចំនួនដើម្បីស្វែងរកដំណោះស្រាយ វិធានការនានាក្នុងការគ្រប់គ្រង និងការដោះស្រាយ។[១៩]

---

[១៩] ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣, ទំព័រទី៥-៦

### ២.១.១.២. គោលបំណងនៃការអភិវឌ្ឍ

ដើម្បីអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងខេត្តកែបឱ្យមាននូវសោភ័ណភាព សណ្តាប់ធ្នាប់ និងក្លាយជាតំបន់គោលដៅទេសចរណ៍ដែលអាចជួយដល់ការកើនឡើងនូវចំណូលជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ពិសេសជួយទៅដល់ការរីកចម្រើននៃសេដ្ឋកិច្ចរបស់ជាតិតាមរយៈ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥"** បានដាក់ចេញនូវគោលបំណងក្នុងការអភិវឌ្ឍខេត្តកែបដូចជា៖

- ប្រែក្លាយខេត្តកែបទៅជាគោលដៅទេសចរណ៍សម្រាប់ការស្នាក់កម្សាន្តរយៈពេលយូរ និងគ្រប់រដូវកាល
- ប្រែក្លាយខេត្តកែបទៅជាគោលដៅទេសចរណ៍ធម្មជាតិ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្ទះទី២ ប្រកបដោយផាសុកភាព សុវត្ថិភាព និងការប្រកួតប្រជែងខ្ពស់នៅលើឆាកអន្តរជាតិ
- លើកស្ទួយសេដ្ឋកិច្ចជាតិ លើកស្ទួយកម្រិតជីវភាព ជាពិសេសសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានខេត្តកែបប្រកបដោយប្រសិទ្ធភាព និងសមធម៌។

### ២.១.១.៣. គោលដៅនៃការអភិវឌ្ឍ

ការអភិវឌ្ឍតំបន់ទេសចរណ៍នីមួយៗ របស់រាជរដ្ឋាភិបាលសុទ្ធតែត្រូវបានដាក់ចេញ និងបានកំណត់នូវគោលដៅយ៉ាងជាក់លាក់ និងច្បាស់លាស់ ដើម្បីធានាថាការចំណាយលើការអភិឌ្ឍនឹងជួយដល់សេដ្ឋកិច្ចជាតិ។ តួយ៉ាងក្នុង **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥"** សម្រាប់ខេត្តកែបបានសម្រេចដាក់ចេញគោលដៅចំនួន ០៣ គឺគោលដៅអភិវឌ្ឍន៍ទៅលើប៉ូលទេសចរណ៍ខេត្តកែប ការអភិវឌ្ឍដល់វិស័យដែលជួយគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ខេត្តកែប និងការលើកកម្ពស់ការវិនិយោគ និងការផ្សព្វផ្សាយទីផ្សារ។

- ការអភិវឌ្ឍប៉ូលទេសចរណ៍ខេត្តកែបទាំង ០៤តំបន់ ដែលត្រូវបានធ្វើការបែងចែកដោយផ្អែកទៅលើកត្តាសំខាន់ៗ រួមមានភូមិសាស្ត្រ បរិស្ថាន ធនធានធម្មជាតិ សេដ្ឋកិច្ច ការគ្រប់គ្រងរដ្ឋបាល ការផ្គត់ផ្គង់ផលិតផល ហេដ្ឋារចនាសម្ព័ន្ធគោល និងសក្តានុពល។ ផ្អែកលើកត្តាទាំងអស់នេះ ការអភិវឌ្ឍប៉ូលទេសចរណ៍ខេត្តកែបបានកំណត់គោលដៅ និងបង្កើតតំបន់ប៉ូលទេសចរណ៍ទាំង ០៤ ដែលមានដូចជាតំបន់ក្រុងកែបចាស់ តំបន់ភ្នំវល្លិ៍ តំបន់ឆ្នេរអង្កោល និងតំបន់សមុទ្រ-ប្រជុំកោះ
- ការអភិវឌ្ឍវិស័យដែលជួយគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ខេត្តកែប ដោយសារតែស្ថានភាពវិស័យគាំទ្រមួយចំនួន គឺមានភាពល្អប្រសើរ ចំណែកឯវិស័យមួយចំនួនទៀតមានភាពខ្វះខាតជាហេតុទាមទារឱ្យមានការអភិវឌ្ឍបន្ថែមទៅលើវិស័យគាំទ្រទាំងអស់នោះ។ វិស័យគាំទ្រសំខាន់ៗ ដែលត្រូវធ្វើការអភិឌ្ឍន៍មានដូចជា ការគ្រប់គ្រងសន្តិសុខ ការផ្គត់ផ្គង់ទឹកស្អាត សំណល់រឹង-រាវ ការគ្រប់គ្រងគ្រោះមហន្តរាយ

សោភ័ណភាព ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ការផ្គត់ផ្គង់ថាមពលអគ្គិសនី ការអភិវឌ្ឍវិស័យកសិកម្ម និងការធ្វើទំនើបកម្មវិស័យសុខាភិបាល

- លើកកម្ពស់ការវិនិយោគ និងការផ្សព្វផ្សាយទីផ្សារ សំដៅការដាក់គោលដៅអភិវឌ្ឍន៍តំបន់ទេសចរណ៍ឱ្យមាននូវភាពទាក់ទាញដល់អ្នកវិនិយោគទាំងនៅក្នុង និងក្រៅប្រទេសមកដាក់ទុនវិនិយោគនៅតំបន់ទេសចរណ៍ខេត្តកែប តាមរយៈការឃោសនា ការផ្សព្វផ្សាយប្រកបដោយទៅប្រសិទ្ធភាពក្នុងការប្រកួតប្រជែងទីផ្សារជាតិ និងអន្តរជាតិដែលទាក់ទងនឹងផលិតផលទេសចរណ៍ សក្តានុពល និងភាពល្បីល្បាញរបស់ខេត្តកែប។[២០]

## ២.១.២. ការរៀបចំអភិវឌ្ឍន៍តំបន់ទេសចរណ៍ខេត្តកែប

ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ និងកំណើននៃប្រជាជនក្នុងខេត្តកែបក៏ដូចជានៅក្នុងប្រទេសកម្ពុជាទាំងមូលទាមទារឱ្យមាននូវការរៀបចំ ការគ្រប់គ្រង និងការអភិវឌ្ឍទៅតាមតម្រូវការជាក់ស្តែង។ ហេតុនេះហើយការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបត្រូវរៀបចំ និងអភិវឌ្ឍន៍បន្ថែមទៀតទៅលើហេដ្ឋារចនាសម្ព័ន្ធតំបន់ទេសចរណ៍ដោយត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងផែនការដែលបានដាក់ចេញពិសេសត្រូវដាក់ជូនក្រសួងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលតម្រូវ និងកំណត់ដោយច្បាប់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ និងត្រូវគោរពស្របទៅតាមបច្ចេកទេសនៃការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

### ២.១.២.១. តំបន់ឆ្នេរសមុទ្រ

ដើម្បីរៀបចំតំបន់ឆ្នេរសមុទ្រខេត្តកែប ដែលជាផ្នែកមួយនៃវិស័យទេសចរណ៍ដ៏មានសក្តានុពលនៅកម្ពុជាក្នុងការធានា គ្រប់គ្រង និងអភិវឌ្ឍន៍ប្រកបដោយសោភ័ណភាព សណ្តាប់ធ្នាប់ ស្របទៅតាមតម្រូវការចាំបាច់ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវដាក់ចេញវិធានការផ្នែកច្បាប់ ផែនការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រឱ្យបានត្រឹមត្រូវមានប្រសិទ្ធភាព ចីរភាព និងទប់ស្កាត់ផលប៉ះពាល់នានាដល់វិស័យទេសចរណ៍ សេដ្ឋកិច្ច បរិស្ថាន វប្បធម៌ប្រពៃណីនៃតំបន់ឆ្នេរសមុទ្រ។ តាមរយៈការលើកឡើងខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ និងដាក់ចេញសារាចរណែនាំ ស្តីអំពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា លេខ ០១ សរណន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ដោយរាល់ការអភិវឌ្ឍ និងការសាងសង់ក្នុងតំបន់ឆ្នេរត្រូវគោរពតាមគោលការណ៍ដូចជា៖

- ត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសំណល់រឹង-រាវដោយមានអាងចម្រោះ ប្រព័ន្ធលូ និងប្រព័ន្ធគ្រប់គ្រងគុណភាពទឹកស្របតាមបទដ្ឋានបច្ចេកទេសចំពោះរាល់ការអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រ

[២០] ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣, ទំព័រទី១១-១២, ២២

- ➢ រាល់ការអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រ កោះ និងទេសចរណ៍នានាត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថានដោយគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងផែនការអភិវឌ្ឍជាដើម
- ➢ ត្រូវធ្វើការអនុវត្តន៍តាមប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ ព្រមទាំងបទបញ្ញត្តិផ្សេងៗទៀតដែលនៅជាធរមាន
- ➢ ចំពោះទីតាំងដែលនៅពុំទាន់មានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់អនុវត្តន៍
- ➢ ត្រូវធ្វើការសិក្សា និងវាយតម្លៃអំពីផលប៉ះពាល់បរិស្ថានឱ្យបានត្រឹមត្រូវនូវរាល់សំណើសុំធ្វើការអភិវឌ្ឍន៍សំណង់នានាដែលមានកម្រិតបញ្ចេញផ្សែងបំពុលខ្ពស់ទៅក្នុងបរិយាកាស
- ➢ រៀបចំឱ្យមានច្រកចេញចូលនៅតាមបណ្តោយឆ្នេរសមុទ្រដើម្បីបង្កភាពងាយស្រួល។[២១]

ជាក់ស្តែង តាមរយៈការរៀបចំ និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រខេត្តកែបត្រូវបានអភិវឌ្ឍន៍ដោយស្របទៅតាមច្បាប់ និងផែនការដែលដាក់ចេញ ដើម្បីសម្រេចជាសមិទ្ធផលនូវទីតាំងសំខាន់ៗមួយចំនួនដូចជា៖

- ➢ បានអភិវឌ្ឍន៍ កែលំអឆ្នេរភក់ទៅជាឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់ តាមគម្រោងនេះមានទីតាំងស្ថិតនៅប្របមាត់ឆ្នេរសមុទ្រមានប្រវែងបណ្តោយ ២៧០០ម៉ែត្រ ទទឹងប្រវែងស្មើនឹង ៣០ម៉ែត្រ មានទីតាំងពីផ្សារក្តាមរហូតដល់ព្រៃកោងកាងស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ក្នុងនោះគេបានរៀបចំអភិវឌ្ឍន៍សោភ័ណភាពដោយមានការរៀបចំគ្រឹះចាក់ខ្សាច់ធ្វើឆ្នេរ ធ្វើសួនច្បារសាធារណៈ ព្រមទាំងដាំដើមឈើនៅលើដីចំណីឆ្នេរសមុទ្រ។[២២]
- ➢ បានអភិវឌ្ឍន៍ធ្វើផ្លូវប្របមាត់សមុទ្រដែលត្រូវបានភ្ជាប់ពីកោះទន្សាយទៅឆ្នេរអង្កោលប្រវែង ១១គីឡូម៉ែត្រ ដោយត្រូវបានក្រាលកៅស៊ូទាំងពីរស្រទាប់ ចំណែកនៅតាមចិញ្ចើមផ្លូវវិញ ត្រូវបានក្រាលដោយបេតុង និងរៀបចំដាក់បង្គោលភ្លើងសាធារណៈ។[២៣]
- ➢ បានសាងសង់កំពង់ផែទេសចរណ៍កោះទន្សាយ ដែលកំពង់ផែមួយនេះដែរ គឺជាផ្នែកមួយនៃការអភិវឌ្ឍ

[២១] សារាចរណែនាំ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា, លេខ ០១ .សរណន, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២, ចំណុច៩

[២២]សេចក្តីប្រកាសព័ត៌មាន ស្តីពីការអនុញ្ញាតជូន គ.អ.ឆ.ក អនុវត្តន៍គម្រោងកែលំអឆ្នេរភក់ទៅជាឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់, ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១

[២៣] គេហទំព័រ https://www.mpwt.gov.kh/kh/press/36336 ដកស្រង់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤

ប៉ូលទេសចរណ៍តំបន់កោះក្នុងចំណោមប៉ូលទេសចរណ៍ទាំង ០៤ ក្នុងគោលបំណងអភិវឌ្ឍន៍ខេត្តកែប ទៅជាគោលដៅទេសចរណ៍ធម្មជាតិ និងទេសចរណ៍សមុទ្រសម្រាកកម្សាន្តបែបប្រណិតកម្រិតខ្ពស់។[២៤]

### ២.១.២.២. តំបន់រមណីយដ្ឋាន

ចំពោះតំបន់រមណីយដ្ឋានទេសចរណ៍ខេត្តកែបត្រូវបានបែងចែកជា ០៣ រួមមានរមណីយដ្ឋានធម្មជាតិ រមណីយដ្ឋានកែច្នៃ រមណីយដ្ឋានវប្បធម៌ និងប្រវត្តិសាស្ត្រ។ យោងតាមសេចក្ដីសម្រេច ស្ដីពីការដាក់ឱ្យអនុវត្តន៍ គោលការណ៍ណែនាំការអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្របានដាក់ចេញឱ្យអនុវត្តន៍នូវគោលការណ៍នេះ សំដៅចូល រួមអភិវឌ្ឍន៍នូវរមណីយដ្ឋានឆ្នេរសមុទ្រឱ្យក្លាយទៅជាផលិតផលទេសចរណ៍ដែលមានគោលបំណងផ្ដល់ដល់អ្នក អភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រនូវឧបករណ៍ ឯកសារជំនួយដើម្បីធានានូវគុណភាព សេវាកម្ម សុវត្ថិភាព តាមឆ្នេរសមុទ្រដោយផ្ដោតទៅលើការអប់រំ ការផ្ដល់ព័ត៌មាន ការកសាងហេដ្ឋារចនាសម្ព័ន្ធបៃតងព្រមទាំង ជំរុញស្មារតីចូលរួមរបស់ប្រតិបត្តិករក្នុងអភិបាលកិច្ចល្អ ទៅលើបរិស្ថាននៅតំបន់ឆ្នេរសមុទ្រខេត្តកែប។

ក្នុងសេចក្ដីសម្រេចនេះដែរ គម្រោងនៃការអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រត្រូវបានធ្វើការបែងចែកជា ០៥ប្រភេទមានដូចជា គម្រោងនៃការអភិវឌ្ឍរមណីយដ្ឋានឆ្នេរអភិរក្សស្ងួល រមណីយដ្ឋានឆ្នេរអេកូទេសចរណ៍ រមណីយដ្ឋានឆ្នេរសមុទ្រកម្សាន្តបែបប្រណិត រមណីយដ្ឋានឆ្នេរសមុទ្រកម្សាន្តសាធារណៈកម្រិតខ្ពស់ ព្រមទាំង គម្រោងនៃការអភិវឌ្ឍរមណីយដ្ឋានឆ្នេរសាធារណៈកម្រិតមធ្យម។[២៥]

### ២.១.២.៣. តំបន់សេដ្ឋកិច្ច

ខេត្តកែប គឺជាតំបន់ឆ្នេរសមុទ្រដែលត្រូវបានទទួលយកចិត្តទុកដាក់ពីរដ្ឋាភិបាលក្នុងការអភិវឌ្ឍយ៉ាង ខ្លាំងទៅលើវិស័យទេសចរណ៍ ទន្ទឹមនឹងនេះ តាមរយៈគម្រោងព្រែកជីកហ្វូណនតេជោ ខេត្តកែបនឹងក្លាយជា តំបន់សេដ្ឋកិច្ចមួយដ៏មានសក្ដានុពលដោយសារភូមិសាស្ត្រផ្លូវទឹកនៅក្នុងខេត្តកែប មានលក្ខណៈអំណោយផល ដែលជាច្រកចេញចូលនៃពាណិជ្ជកម្មតាមផ្លូវទឹកសម្រាប់នាវា កប៉ាលដឹកជញ្ជូនទំនិញ។ ព្រែកជីកមួយនេះដែរ មានចម្ងាយពីភ្នំពេញទៅខេត្តកែប ១៨០គីឡូម៉ែត្រ ចាប់ពីព្រែកតាកែវនៃទន្លេមេគង្គឆ្លងកាត់តាមព្រែកតាឯកនៃ ទន្លេបាសាក់រួចចូលទៅតាមព្រែកតាហីងនៃទន្លេបាសាក់ ស្រុកកោះធំ និងបន្តរហូតទៅដល់សមុទ្រខេត្តកែបដោយ ឆ្លងកាត់ខេត្តចំនួន ០៤ រួមមាន ខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប។ ផ្លូវទឹកនៃគម្រោងព្រែកជីក នេះ គឺមានទទឹងមុខកាត់ផ្នែកខាងលើប្រវែង ១០០ម៉ែត្រ ហើយមានមុខកាត់ផ្នែកខាងក្រោមប្រវែង ៨០ម៉ែត្រ និង

[២៤] គេហទំព័រ https://www.mpwt.gov.kh/kh/press/37627 ដកស្រង់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤

[២៥] សេចក្ដីសម្រេច ស្ដីពីការដាក់ឱ្យអនុវត្តន៍គោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ, លេខ ១៣១ ស.ស.រ, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦

មានជម្រៅទឹក ៥,៤ម៉ែត្រ ចំពោះគមនាគមន៍ផ្លូវទឹកមានគន្លងសម្រាប់នាវាចរណ៍ចំនួន ០២ ដែលអាចឱ្យនាវាជាដើមអាចចេញ-ចូល និងជៀសគ្នាដោយសុវត្ថិភាព។[២៦] ពេលដែលគម្រោងនេះសម្រេចរួចរាល់ប្រទេសកម្ពុជានឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើន ពិសេសការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែប ការកាត់បន្ថយនូវរយៈចម្ងាយ ការកាត់បន្ថយតម្លៃការដឹកជញ្ជូន ការបង្កើតតំបន់ពាណិជ្ជកម្ម ការអភិវឌ្ឍផែរណបថ្មីៗ ការពង្រីកតំបន់អភិវឌ្ឍន៍កសិកម្ម និងប្រព័ន្ធធារាសាស្ត្រ ព្រមទាំងធ្វើឱ្យការដឹកជញ្ជូនមានភាពរហ័សលឿនជាងមុន។[២៧]

## ២.១.៣. ការជំរុញក្នុងការលើកកម្ពស់វិស័យទេសចរណ៍ខេត្តកែប

ដើម្បីជំរុញការលើកកម្ពស់វិស័យទេសចរណ៍ខេត្តកែបឱ្យមានការអភិវឌ្ឍ និងសម្រេចតាមផែនការដែលបានកំណត់ព្រមទាំងមានកេរ្តិ៍ឈ្មោះល្បីល្បាញ ហើយអាចជួយដល់សេដ្ឋកិច្ចជាតិ គេបានកំណត់ និងដាក់ចេញនូវផែនការក្នុងការលើកកម្ពស់វិស័យទេសចរណ៍ក្នុងខេត្តកែបចំនួន ០២ រួមមាន ការផ្សព្វផ្សាយ និងការវិនិយោគ។

### ២.១.៣.១. ការផ្សព្វផ្សាយ

ដើម្បីជំរុញកំណើននៃការវិនិយោគ និងការទាក់ទាញភ្ញៀវទេសចរមកកម្សាន្តនៅខេត្តកែបឱ្យបានកាន់តែច្រើន ព្រមទាំងស្នាក់កម្សាន្តនៅកាន់តែយូរ ការដាក់ចេញយុទ្ធសាស្ត្រទីផ្សារដែលធ្វើឡើងតាមរយៈការផ្សព្វផ្សាយដូចមានកំណត់នៅក្នុងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥ របស់រដ្ឋាភិបាល ពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែកលើកស្ទួយវិស័យទេសចរណ៍។ ក្នុងស្មារតីមួយនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការសម្រាប់អភិវឌ្ឍន៍ចំនួន ០២ ដូចជា៖

#### ក. ការអភិវឌ្ឍកិត្តិនាម និងម៉ាកគោលដៅទេសចរណ៍ខេត្តកែប

ជំរុញការបង្កើនកិត្តិនាម និងម៉ាកគោលដៅទេសចរណ៍ក្នុងខេត្តកែបទៅជាគោលដៅទេសចរណ៍ធម្មជាតិសុខភាព ប្រណិតតាមរយៈការផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងទីផ្សារទេសចរណ៍ជាតិ និងអន្តរជាតិ ព្រមទាំងជំរុញរៀបចំខេត្តកែបឱ្យក្លាយទៅជាគោលដៅទេសចរណ៍ស្ទូឌីយ៉ូធម្មជាតិសម្រាប់ការថតភាពយន្តល្បែងផ្សងព្រេង និងកម្មវិធីអាពាហ៍ពិពាហ៍ជាដើម។

#### ខ. ការពង្រឹងយន្តការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ខេត្តកែប

ការពង្រឹងយន្តការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ខេត្តកែបក្នុងវិធានការនេះដែរមានដូចជា ការពង្រឹងលើការគ្រប់គ្រង ការរៀបចំឱ្យមានមណ្ឌលព័ត៌មានទេសចរណ៍នៅតាមគោលដៅទេសចរណ៍សំខាន់ៗ ដែលអាច

---

[២៦] គេហទំព័រ https://www.cpp.org.kh/details/368426 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤

[២៧] គេហទំព័រ https://www.information.gov.kh/articles/109268 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤

ផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងគោលដៅកម្សាន្ត ការស្នាក់នៅ ម្ហូបអាហារ និងសេវាកម្មទេសចរណ៍ផ្សេងទៀត។ មួយវិញទៀត គឺការបង្កើតថ្នាលបច្ចេកវិទ្យានានាសម្រាប់បណ្តាញប្រតិបត្តិករទេសចរ ពិសេសអង្គភាពគ្រប់គ្រងលើគោលដៅក្នុងប៉ូលទេសចរណ៍នីមួយៗ ដើម្បីធ្វើជាមូលដ្ឋានក្នុងការផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តកែបឱ្យបានកាន់តែទូលំទូលាយនៅក្នុងទីផ្សារទេសចរណ៍ជាតិ និងអន្តរជាតិ។ បន្ថែមពីនេះ ការជំរុញផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តកែបទៅកាន់ទីផ្សារទេសចរណ៍អន្តរជាតិតាមរយៈយន្តការផ្សព្វផ្សាយមានដូចជា យន្តការផ្សព្វផ្សាយតាមរយៈក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតនៅលើសកលលោក ការបង្កើនការចូលរួមព្រឹត្តិការណ៍ពិពណ៌ទេសចរណ៍អន្តរជាតិសំខាន់ៗ និងការសហការជាមួយអ្នកមានឥទ្ធិពលក្នុងបណ្តាញសង្គមដូចជា YouTube Instagramជាដើម ជាមួយនឹងការបង្កើតឱ្យមាននូវទូតសុឆន្ទៈដែលតំណាងឱ្យខេត្តកែបតាមវិស័យរួមមានដូចជា វិស័យទេសចរណ៍ បរិស្ថាន ធនធានធម្មជាតិ និងអាហារសមុទ្រ ដើម្បីចូលរួមជំរុញការផ្សព្វផ្សាយសក្តានុពលទេសចរណ៍សំខាន់ៗក្នុងខេត្តកែប។

#### ២.១.៣.២. ការវិនិយោគ

ដើម្បីអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឱ្យកាន់តែមានការរីកចម្រើនលូតលាស់ទៅមុខ ហើយក្លាយទៅជាគោលដៅទេសចរណ៍សម្រាកកម្សាន្តប្រណិតកម្រិតខ្ពស់ ចាំបាច់ត្រូវរៀបចំឱ្យមានការអភិវឌ្ឍទៅវិស័យឯកជនទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធសំណង់អាគារ ភោជនីយដ្ឋានជាដើមដែលត្រូវពឹងផ្អែកទៅលើការវិនិយោគជាចម្បង អាស្រ័យលើការជំរុញការវិនិយោគដើម្បីមានផលិតផលទេសចរណ៍ និងសេវាកម្មទេសចរណ៍កាន់តែសម្បូរបែបទៅតាមតម្រូវការរបស់ភ្ញៀវទេសចរ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលដាក់ចេញឱ្យអនុវត្តន៍នូវវិធានការក្នុងការលើកកម្ពស់ការវិនិយោគទេសចរណ៍ដោយរដ្ឋាភិបាលធ្វើការសិក្សា និងធ្វើការកំណត់ទីតាំង ដែលមានសក្តានុពលសម្រាប់គម្រោងវិនិយោគ ពិសេសនៅតាមបណ្តាទីតាំងរបស់រដ្ឋដើម្បីត្រៀមខ្លួនសហការជាមួយនឹងវិស័យឯកជនក្នុងការអភិវឌ្ឍគោលដៅទាំងនោះ។ វិធានការបន្ទាប់ គឺការរៀបចំវេទិកាវិនិយោគទេសចរណ៍ខេត្តកែបជាប្រចាំឆ្នាំ ដើម្បីជំរុញឱ្យមានការទាក់ទាញការវិនិយោគពីក្នុងស្រុក និងអ្នកវិនិយោគផ្ទាល់ពីបរទេស។ ក្នុងនោះដែរ ត្រូវពង្រឹងការអនុវត្តវិធានការសារពើពន្ធដើម្បីជំរុញឱ្យមានការថែទាំ និងប្រើប្រាស់ដី។[២៨]

### ២.២. ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់តំបន់ទេសចរណ៍ខេត្តកែប

ការរៀបចំក្រុងមួយឱ្យមានសោភ័ណភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ មានន័យថា ធ្វើឱ្យក្រុងនោះមានភាពស្រស់ស្អាត មិនមានសកម្មភាពកសិកម្ម មានសន្តិសុខ ភាពស្ងប់ស្ងៀម និងគ្មានការបំពុលទាំងប្រាំ។

[២៨] ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣, ទំព័រទី២១-២២

តួយ៉ាងតំបន់ទេសចរណ៍ក្នុងខេត្តកែប ការរៀបចំ និងការអភិវឌ្ឍឱ្យមាននូវសោភ័ណភាពស្រស់ស្អាតរួមជាមួយនឹងសណ្តាប់ធ្នាប់ របៀបរៀបរយ គឺជាកត្តាចម្បងមិនអាចខ្វះបានក្នុងការជួយជំរុញវិស័យទេសចរណ៍ឱ្យមាននូវភាពល្បីល្បាញ និងក្លាយជាទីកន្លែងសម្រាប់ការមកសម្រាកកម្សាន្ត ព្រមទាំងជំរុញឱ្យក្លាយជាទីកន្លែងប្រកួតប្រជែងទីផ្សារទេសចរណ៍។ ដើម្បីធ្វើឱ្យវិស័យទេសចរណ៍ក្នុងខេត្តកែបក្លាយឱ្យទៅជាគោលដៅទេសចរណ៍មួយដែលមានសក្តានុពល និងមានស្តង់ដារត្រឹមត្រូវតាមបច្ចេកទេសនគរូបនីយកម្ម ការរៀបចំតំបន់ទេសចរណ៍ក្នុងខេត្តកែបត្រូវធ្វើការបែងចែកជា ០២ផ្នែក គឺការរៀបចំសោភ័ណភាព និងការរៀបចំសណ្តាប់ធ្នាប់។

### ២.២.១. ការរៀបចំសោភ័ណភាព

ការរៀបចំសោភ័ណភាពនៃតំបន់ទេសចរណ៍ក្នុងខេត្តកែប គឺជាការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងឯកជនដើម្បីរំលេចឱ្យឃើញសោភ័ណភាពដ៏ស្រស់ស្អាត ដោយត្រូវអនុវត្តន៍ទៅតាមផែនការដែលបានអនុម័ត និងលិខិតបទដ្ឋានគតិយុត្តនានា។ ការរៀបចំសោភ័ណភាពតំបន់ទេសចរណ៍ក្នុងខេត្តកែបបែងចែកជា ០២ប្រភេទ គឺការរៀបចំសោភ័ណភាពពេលថ្ងៃ និងសោភ័ណភាពពេលយប់។

#### ២.២.១.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ

ការរៀបចំសោភ័ណភាពពេលថ្ងៃ សំដៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងឯកជនរួមមាន បណ្តាញផ្លូវសាធារណៈ បរិក្ខារសាធារណៈ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ សំណង់អាគារតូចធំ ស្ពាន ផ្លូវក្រោមដី បណ្តាញទូរគមនាគមន៍ បណ្តាញអគ្គិសនី សួនច្បារសាធារណៈ និងប្រព័ន្ធសុវត្ថិភាពដែលទាក់ទងនឹងចរាចរណ៍ដូចជា ភ្លើងសញ្ញា ផ្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍នៅតាមដងផ្លូវ។[២៩]

#### ក. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

តាមរបាយការណ៍ប្រចាំថ្ងៃក្នុងឆ្នាំ២០២៤ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប បានរៀបចំហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដើម្បីជួយគាំទ្រដល់សោភ័ណភាពតំបន់ទេសចរណ៍ក្នុងខេត្តកែបឱ្យកាន់តែមានភាពទាក់ទាញ និងសុវត្ថិភាព។ សកម្មភាពទាំងនោះរួមមានដូចជា៖

- ការសាងសង់ផ្លូវខេត្តលេខ១៣៣៣ ដោយក្រាលកៅស៊ូ DBST មានទទឹង ៧ម៉ែត្រ
- ការសាងសង់លូមូលបណ្តោយផ្លូវមុខកាត់ ១ម៉ែត្រ ចំនួន ០៣កន្លែង ដាឡូមុខ១ ចំនួន ០២កន្លែង
- ការថែទាំជាប្រចាំលើគម្រោង (1-NR33A) មានការស្រោចទឹកសួន និងចូកសម្អាតតាមចិញ្ចើមផ្លូវ

[២៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៤, ទំព័រទី១

- ការថែទាំលើគម្រោង (2-PR1335) មានការលាបថ្នាំបង្គោលសុវត្ថិភាព និងបិតស្ទីគ័រចំណាំងផ្លាត
- ការធ្វើលូប្រអប់ បរិក្ខារផ្លូវថ្នល់ និងការងារធ្វើគ្រឹះថ្មចម្រុះ
- ការថែទាំសួនច្បារសាធារណៈតាមដងផ្លូវដោយមានការដាំផ្កាចម្រុះគ្រប់ប្រភេទជាប្រចាំ។[៣០]

### ខ. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធឆ្នេរសមុទ្រកែប

ការរៀបចំសោភ័ណភាពឆ្នេរសមុទ្រតំបន់ទេសចរណ៍ខេត្តកែប ត្រូវបានធ្វើការចាក់ខ្សាច់សក្បុសបំពេញបន្ថែមនៅតំបន់ឆ្នេរស្រើស ដោយសារខ្សាច់តាមបណ្តោយឆ្នេរត្រូវបានហូរចូលសមុទ្រនាំឱ្យឆ្នេរកាន់តែមានទទឹងខ្លីទៅៗ ណាមួយដើម្បីរៀបចំឆ្នេរឱ្យមានភាពស្រស់ស្អាតជាងមុន បន្ថែមពីលើនេះ ខេត្តកែបក៏បានធ្វើការពង្រីកចាក់ខ្សាច់ពង្រីកឆ្នេរសមុទ្រឱ្យវែងជាងមុនក្នុងតំបន់មួយចំនួនក្នុងខេត្តកែប ម្យ៉ាងទៀតគេក៏ឃើញមានការសាងសងកញ្ចុះថ្មទល់មុខឆ្នេរស្រើសសម្រាប់ជួលឱ្យអាជីវករធ្វើអាជីវកម្ម។ បន្ថែមពីនេះ រដ្ឋបាលខេត្តកែបបានធ្វើការចាក់ដីចូលសមុទ្រ និងចាក់ខ្សាច់ពង្រីកឆ្នេរនៅតំបន់នានាបន្ថែមទៀត ដើម្បីធ្វើឱ្យខេត្តកែបកាន់តែសម្បូរតំបន់កម្សាន្ត និងជាទីកន្លែងសម្រាប់ភ្ញៀវទេសចរសម្រាកកម្សាន្ត។

### គ. ការគ្រប់គ្រងសំណង់ក្នុងខេត្តកែប

ដើម្បីធានាបាននូវការគ្រប់គ្រងកិច្ចការបច្ចេកទេសនគរូបនីយកម្ម និងសំណង់ និងជាគ្រឹះនៃភាពស្របតាមច្បាប់ ពិសេសដើម្បីធានាសោភ័ណភាព និងសណ្តាប់ធ្នាប់ ការអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទនៅក្នុងតំបន់ទេសចរណ៍ខេត្តកែបត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង/ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច។ ការអភិវឌ្ឍអចលនវត្ថុដែលត្រូវមានលិខិតអនុញ្ញាតរួមមាន៖

- ការសាងសង់សំណង់ថ្មី ការសាងសង់ឡើងវិញ ការពង្រីកអាគារ និងការសាងសង់បន្ថែមពីលើអគារដែលមានស្រាប់ ការប្តូរមុខងារប្រើប្រាស់អាគារដែលមានស្រាប់ ការជួសជុល និងរុះរើ
- ការសាងសង់ ឬប្តូរទ្រង់ទ្រាយអាគារដែលអាចបង្កគ្រោះថ្នាក់អគ្គិភ័យ
- ការអភិវឌ្ឍដីដូចជាការចាក់ដីបំពេញ ការប្តូរមុខងារតំបន់ប្រើប្រាស់ដីជាដើម
- ការដាក់ស្លាកសញ្ញាផ្សាយពាណិជ្ជកម្ម និងទូរគមនាគមន៍ក្នុងគោលបំណងធ្វើពាណិជ្ជកម្មក៏ដូចជាការដាក់រចនាសម្ព័ន្ធនៅលើដី និងអាគារជាដើម។[៣១]

[៣០] របាយការណ៍សកម្មភាពប្រចាំថ្ងៃ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប, ឆ្នាំ២០២៤

[៣១] អនុក្រឹត្យ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, មាត្រា៥៧

**២.២.១.២. ការរៀបចំសោភ័ណភាពពេលយប់**

ការរៀបចំសោភ័ណភាពពេលថ្ងៃតែមួយមុខ គឺមិនទាន់គ្រប់គ្រាន់នោះទេ ពោលចាំបាច់ត្រូវធ្វើការរៀបចំសោភ័ណភាពពេលយប់ទៀត ទើបធ្វើឱ្យតំបន់ទេសចរណ៍ខេត្តកែបកាន់តែពោរពេញដោយសម្រស់ស្រស់ស្អាត និងរំលេចទេសភាពនាពេលរាត្រីថែមមួយកម្រិត។ ជាក់ស្តែង សម្រាប់ការរៀបចំសោភ័ណភាពពេលយប់នៅតំបន់ទេសចរណ៍ខេត្តកែបមានការរៀបចំដាក់អំពូលភ្លើងចម្រុះពណ៌ អំពូលភ្លើងបំភ្លឺផ្លូវ និងនៅតាមសួនច្បារតាមបណ្តោយផ្លូវត្រង់ចំណុចរង្វង់មូលសេះស មកកាន់ក្រុងកែប ដែលវាធ្វើឱ្យសម្រស់ខេត្តកែបកាន់តែរំលេចឡើងនូវនាពេលរាត្រី ចំណែកនៅមុខសាលាខេត្ត តំបន់ឆ្នេរស្រីស ចំណុចរូបសំណាក់ព្រះវិស្ណុ ចុះមកដល់ផ្សារក្តាមព័ទ្ធភ្នំមកដល់ឆ្នេរស្រីស គឺមានការរៀបចំដាក់ភ្លើងបំភ្លឺផ្លូវ ភ្លើងចម្រុះពណ៌ រីឯនៅតាមភោជនីយដ្ឋាន ផ្ទះសំណាក់សណ្ឋាគារ បឹងហ្គាឡូ-រីស៊ត មន្ទីរ អង្គភាពស្ថាប័នរដ្ឋជាដើមដែលមានទីតាំងនៅតំបន់ទេសចរណ៍ខេត្តកែបគឺសុទ្ធតែមានការរៀបចំហេដ្ឋារចនាបថភ្លើងពណ៌ចម្រុះទៅតាមគំនិតច្នៃប្រឌិតរបស់អាជីវកម្ម ដែលអាចជួយឱ្យអាជីវកម្មរបស់ពួកគេមានភាពទាក់ទាញ ជាពិសេសនោះ គឺជួយឱ្យតំបន់ទេសចរណ៍ក្នុងខេត្តកែបកាន់តែមាននូវភាពស្រស់ស្អាតថែមមួយកម្រិតទៀត។

**២.២.២. ការរៀបចំសណ្តាប់ធ្នាប់**

ការរៀបចំសណ្តាប់ធ្នាប់តំបន់ទេសចរណ៍ខេត្តកែបបានបែងចែកជា ០៣ប្រភេទ គឺការរៀបចំសន្តិសុខ (សន្តិសុខ សំដៅលើសុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារ) ការធ្វើឱ្យមានផាសុកភាព និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធសំណង់ក្នុងខេត្តកែប។

**២.២.២.១. ការរៀបចំសន្តិសុខ**

សន្តិសុខតំបន់ទេសចរណ៍ខេត្តកែប គឺកត្តាមួយដ៏សំខាន់ក្នុងការចូលរួមចំណែកជួយឱ្យមាននូវកំណើនភ្ញៀវទេសចរ ព្រោះសន្តិសុខនឹងផ្តល់នូវទំនុកចិត្តដល់ភ្ញៀវទេសចរក្នុងការចំណាយពេលវេលាមានតម្លៃធ្វើដំណើរមកសម្រាកលំហែកម្សាន្តនៅខេត្តកែប។ ជាទូទៅ សន្តិសុខត្រូវបានធ្វើការបែងចែកជា ០៣ គឺសុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារ។[៣២]

**ក. សុវត្ថិភាពបុគ្គល**

សុវត្ថិភាពបុគ្គល គឺជាការរស់នៅដែលមានសេចក្តីសុខ សុភមង្គលរបស់មនុស្សម្នាក់ៗនៅក្នុងសង្គម ហេតុដូច្នេះហើយ រដ្ឋបាលខេត្តកែបត្រូវគិតគូរអំពីសុវត្ថិភាពប្រជាពលរដ្ឋជាចម្បងក្នុងការរៀបចំតំបន់ទេសចរណ៍

[៣២] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៤, ទំព័រទី១-២

ឱ្យក្លាយជាតំបន់ដ៏មានសក្តានុពលក្នុងវិស័យទេសចរណ៍។ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីភូមិ ឃុំ សង្កាត់មានសុវត្ថិភាព រដ្ឋបាលខេត្តកែបត្រូវធ្វើការពង្រឹងលើការអនុវត្តឱ្យបានខ្ជាប់ខ្ជួនទាក់ទងទៅនឹងសុវត្ថិភាពបុគ្គលដូចជា៖

- ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈក្នុងទីប្រជុំជន តំបន់ផ្សារ នៅតាមដងផ្លូវ និងចិញ្ចើមផ្លូវ ដើម្បីសម្រួលទៅដល់ការធ្វើដំណើរទៅមករបស់អ្នកប្រើប្រាស់ផ្លូវ
- គ្មានបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ ព្រមទាំងបទល្មើសគ្រប់ប្រភេទ ដោយត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសយ៉ាងយកចិត្តទុកដាក់ ហើយត្រូវធ្វើការផ្សព្វផ្សាយអប់រំស្តីពីច្បាប់ដែលពាក់ព័ន្ធ និងផលប៉ះពាល់ដែលបង្កឡើង
- ត្រូវជំរុញបំផុសចលនាអប់រំដល់មហាជនឱ្យសហការជាមួយអាជ្ញាធរមូលដ្ឋានជំនាញដែលពាក់ព័ន្ធក្នុងការគ្រប់គ្រង ទប់ស្កាត់កុំឱ្យមានការបង្កបទល្មើសកើតឡើង
- ត្រូវរៀបចំឱ្យមានសណ្តាប់ធ្នាប់សាធារណៈឱ្យមានរបៀបរៀបរយ ពិសេស គ្មានគ្រោះថ្នាក់ចរាចរណ៍ សំដៅលើការជំរុញ និងរឹតបន្តឹងលើការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- អាជ្ញាធរ ស្ថាប័នមានសមត្ថកិច្ចត្រូវចាត់វិធានការ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបដោយអនុវត្តន៍ឱ្យបានហ្មត់ចត់មិនឱ្យមានអំពើអនាចារ ការជួញដូរមនុស្សទៅលើស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើងក្នុងភូមិ ឃុំ សង្កាត់។[៣៣]

តាមការអនុវត្តជាក់ស្តែង រដ្ឋបាលខេត្តកែបតែងតែចេញសេចក្តីប្រកាសព័ត៌មានដល់អាជ្ញាធរ អង្គភាពមានសមត្ថកិច្ច ពិសេសនៅពេលដែលមានពិធីបុណ្យធំជាដើម។ **ឧទាហរណ៍** រដ្ឋបាលខេត្តកែប នាពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២២ ឆ្លងចូលឆ្នាំ២០២៣ ក្នុងការរៀបចំសុវត្ថិភាពនៅតំបន់ទេសចរណ៍ រដ្ឋបាលខេត្តកែបបានចេញនូវសេចក្តីណែនាំដល់គ្រប់មន្ទីរ អង្គភាព អាជ្ញាធរ គ្រឹះស្ថានសាធារណៈដែលមានសមត្ថកិច្ចដូចជា៖

- មន្ទីរសុខាភិបាលខេត្តកែបត្រូវចាត់តាំងក្រុមគ្រូពេទ្យ និងរថយន្តសង្គ្រោះបន្ទាន់ដែលប្រចាំការនៅតាមរមណីយដ្ឋាន ទីប្រជុំជនសម្រាប់ត្រៀមជួយសង្គ្រោះ និងដឹកជញ្ជូនជនរងគ្រោះ
- គ្រប់មន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុកត្រូវរៀបចំកែលំអសោភ័ណភាព សម្អាតអនាម័យ បរិស្ថានតាមមុខសញ្ញានីមួយៗឱ្យមានសោភ័ណភាព ពិសេសការដាក់ភ្លើងបំភ្លឺនៅពេលរាត្រី ដើម្បីធានានូវសន្តិសុខ សុវត្ថិភាពដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរដែលមកពីគ្រប់ទិសទី

[៣៣] គោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព, លេខ ០១ គ.ន.ប, ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

- ចំពោះស្នងការដ្ឋាននគរបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកែបត្រូវបង្កើនលើកិច្ចការការពារ ការថែរក្សាសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់ ចរាចរណ៍ដងផ្លូវ ជូនប្រជាជន និងភ្ញៀវទេសចរ
- អាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវមានវិធានការអប់រំដល់ប្រជាពលរដ្ឋក្នុងការលើកកម្ពស់ការយល់ដឹងអំពីការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងទប់ស្កាត់សកម្មភាពដែលបង្កឱ្យមានអសន្តិសុខសង្គម។[៣៤]

### ខ. សុវត្ថិភាពសម្ភារៈ

សុវត្ថិភាពសម្ភារៈ គឺជាភាពចាំបាច់មួយដ៏សំខាន់ក្នុងការរៀបចំតំបន់ទេសចរណ៍ខេត្តកែប ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ដើម្បីរក្សានូវសណ្តាប់ធ្នាប់ សន្តិសុខ ពិសេសការពារពីការបំពានលើទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរដែលមកលេងសម្រាកកម្សាន្ត។ រដ្ឋបាលខេត្តកែបក៏ដូចជាអាជ្ញាធរពាក់ព័ន្ធត្រូវធ្វើការផ្សព្វផ្សាយ និងពង្រឹងនូវការអនុវត្តឱ្យបានខ្ជាប់ខ្ជួនទាក់ទងនឹងគោលនយោបាល ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។ តាមរយៈនេះ មន្ត្រីនគរបាលខេត្តកែបក៏ធ្លាប់បានសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការចុះផ្សព្វផ្សាយគោលនយោបាយមួយនេះ ទៅដល់មូលដ្ឋានដែលមានប្រជាពលរដ្ឋចូលរួមប្រមាណ ១២៣នាក់ ក្នុងនោះស្រី ៨៧នាក់ នៅភូមិអំពេង ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។[៣៥] ទាក់ទងនឹងសុវត្ថិភាពទ្រព្យសម្បត្តិក្នុងគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាពមានលក្ខណៈដូចជា ភូមិ ឃុំ សង្កាត់ត្រូវរៀបចំឱ្យមាននូវសណ្តាប់ធ្នាប់សាធារណៈល្អ គ្មានគ្រោះថ្នាក់ចរាចរណ៍តាមរយៈការរឹតបន្តឹងផ្នែកច្បាប់ និងជៀសវាងការមាន ឬបង្ការនូវគ្រោះថ្នាក់ចរាចរណ៍ឱ្យមានកម្រិតទាប។ មួយវិញទៀត ត្រូវតែបង្ការ ឬធ្វើឱ្យគ្មាននូវបទល្មើស លួច ឆក់ ប្លន់គ្រឿងញៀនល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទដោយត្រូវធ្វើការចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការអនុវត្តយកចិត្តទុកដាក់លើការផ្សព្វផ្សាយច្បាប់ និងផលប៉ះពាល់នានាបណ្តាលមកពីបទល្មើសគ្រប់ប្រភេទ។[៣៦]

### គ. សុវត្ថិភាពចំណីអាហារ

សុវត្ថិភាពចំណីអាហារ ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់មនុស្សម្នាក់ៗ ព្រោះនៅពេលយើងបរិភោគនូវអាហារណាដែលគ្មានអនាម័យ គ្មានស្តង់ដារ វានឹងបង្កនូវផលប៉ះពាល់នានាដល់សុខភាពជាមិនខាន។ ក្នុងការរៀបចំតំបន់ទេសចរណ៍ខេត្តកែបក៏ដូចជាក្នុងខេត្តកែបទាំងមូល រដ្ឋបាលខេត្តកែបត្រូវតែយកចិត្តទុកដាក់

---

[៣៤] សេចក្តីណែនាំ ស្តីពីការគ្រប់គ្រង ថែរក្សា សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងអនាម័យ បរិស្ថាន ក្នុងពិធីបុណ្យចូលឆ្នាំសកលឆ្នាំ២០២២ ឆ្លងចូលឆ្នាំ២០២៣, លេខ ០០៥ ស.ណ.ន, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

[៣៥] គេហទំព័រ https://www.gdlf-kh.com/ ដកស្រង់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

[៣៦] គោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព, លេខ ០១ គ.ន.ប, ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

ជាចម្បងដោយសារខេត្តកែបជាតំបន់សមុទ្រមួយដែលសម្បូរទៅដោយគ្រឿងសមុទ្រ ម្ហូបអាហារសមុទ្រជាដើម ដែលត្រូវពិនិត្យ និងគ្រប់គ្រងឱ្យបាននូវការធានាដល់សុខភាពរបស់ប្រជាជន និងភ្ញៀវទេសចរណ៍ដែលមកទិញយកទៅបរិភោគ។ ដើម្បីធានានូវសុវត្ថិភាព គុណភាពលើចំណីអាហារ ការរៀបចំតំបន់ទេសចរណ៍ក្នុងខេត្តកែបត្រូវអនុវត្តន៍តាមវិធានការផ្លូវច្បាប់ និងគោលការណ៍សំខាន់ៗដែលមានដូចជា៖

- ម្ហូបអាហារត្រូវមានសុវត្ថិភាព គុណភាព និងសមស្របសម្រាប់បរិភោគ
- ម្ហូបអាហារត្រូវបំពេញតាមលក្ខខណ្ឌអនាម័យ ការវេចខ្ចប់ និងការដាក់ស្លាកសញ្ញា
- ម្ហូបអាហារដែលត្រូវបានចាត់ទុកថាជាប្រភេទមានហានិភ័យខ្ពស់ត្រូវចុះបញ្ជីការ
- ម្ហូបអាហារមិនត្រូវបាននាំចូល ផលិត កែច្នៃ ឬលក់ក្នុងលក្ខណៈក្លែងបន្លំ ឬបំភាន់
- ការស្តុកទុកម្ហូបអាហារត្រូវបំពេញតាមលក្ខខណ្ឌសម្រាប់រក្សាសុវត្ថិភាព និងគុណភាពម្ហូបអាហារ
- អ្នកប្រើប្រាស់បានទទួលព័ត៌មានគ្រប់គ្រាន់ទាក់ទងនឹងម្ហូបអាហារ ដូចជាប្រភពដើម គ្រឿងផ្សំ តម្លៃអាហាររូបត្ថម្ភ ចំនួនកាឡូរី របៀបប្រើប្រាស់ និងការរក្សាទុក
- ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពចំណីអាហារត្រូវចូលរួមផ្សព្វផ្សាយពីព័ត៌មាននេះ។

ទន្ទឹមនឹងនេះ អាជីវករ ប្រតិបត្តិករក៏មានកាតព្វកិច្ចមួយចំនួនដែរក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ដើម្បីធានាថាម្ហូបអាហារគឺមាន សុវត្ថិភាព គុណភាព និងត្រូវដោះស្រាយបញ្ហាម្ហូបអាហារនៅពេលដែលមានការកើតឡើងក្នុងអាជីវកម្មរបស់ខ្លួន។ ជាងនេះទៅទៀត អាជីវករ ប្រតិបត្តិករត្រូវជូនដំណឹងបន្ទាន់ទៅដល់ស្ថាប័នពាក់ព័ន្ធអំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារដែលបង្កឡើងពីអាជីវកម្មអាហាររបស់ខ្លួន។ ចំណែកការធ្វើអធិការកិច្ចទៅលើម្ហូបអាហារត្រូវតែអនុវត្តន៍ដោយមន្ត្រីអធិការកិច្ចម្ហូបអាហាររបស់ក្រសួងពាណិជ្ជកម្ម និង/ឬដោយមន្ត្រីអធិការកិច្ចរបស់ក្រសួងស្ថាប័នពាក់ព័ន្ធទៅតាមដំណាក់កាលខ្សែចង្វាក់ផលិតកម្ម តាមសមត្ថកិច្ចរៀងៗខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលនៅជាធរមាន។ តាមរយៈនេះ ដើម្បីធានាគុណភាព សុវត្ថិភាពម្ហូបអាហារស្ថាប័នពាក់ព័ន្ធត្រូវធ្វើការបង្កើតប្រព័ន្ធអធិការកិច្ចលើម្ហូបអាហារ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃហានិភ័យព្រមទាំងកំណត់ប្រព័ន្ធចំណាត់ថ្នាក់ហានិភ័យ និងប្រភេទអាជីវកម្មជាក់លាក់ផងដែរ។[៣៧] ជាក់ស្តែងទាក់ទងនឹងការចុះត្រួតពិនិត្យចំណីអាហារខេត្តកែបរបស់មន្ត្រីមានសមត្ថកិច្ច តាមរយៈរបាយការណ៍លទ្ធផលការចុះអធិការកិច្ចបានបង្ហាញថា បានចុះត្រួតពិនិត្យគុណភាព និងសុវត្ថិភាពម្ហូបអាហារនៅទីតាំងផ្សារក្តាមជាលទ្ធផល មន្ត្រីជំនាញនៃអគ្គនាយកដ្ឋាន ក.ប.ប. បានធ្វើតេស្តទៅលើសំណាកគំរូចំនួន ៥៤ ដែលពុំរកឃើញនូវវត្ថុមានសារធាតុគីមី

[៣៧] ច្បាប់ ស្តីពីសុវត្ថិភាពចំណីអាហារ, លេខ នស/រកម/០៦២២/០០៦, ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២, មាត្រា៦, ១១,២២

ហាមឃាត់ក្នុងសំណាកគំរូនោះទេ និងបានបន្តចុះត្រួតពិនិត្យផលិតផលទំនិញ ម្ហូបអាហារនៅតាមផ្ទះ និងតូបលក់មួយចំនួន ហើយរកឃើញផលិតផលទំនិញដែលខូចគុណភាពហួសកាលបរិច្ឆេទប្រើប្រាស់ចំនួន ០៧គីឡូក្រាម។ លើសពីនេះទៅទៀត មន្ត្រីជំនាញក៏បានបិទផ្ទាំងរូបភាពអប់រំ និងបានពន្យល់ណែនាំក្រុមអាជីវករអំពីសុវត្ថិភាពម្ហូបអាហារ។[៣៨]

### ២.២.២.២. ផាសុកភាពនៃតំបន់ទេសចរណ៍ខេត្តកែប

ដើម្បីរៀបចំតំបន់ទេសចរណ៍ខេត្តកែបឱ្យក្លាយជាតំបន់ទេសចរណ៍ដែលមានភាពល្បីល្បាញ ព្រមទាំងមានការទាក់ទាញភ្ញៀវទេសចឱ្យមកកម្សាន្ត ការរៀកចំឱ្យ មានតែសោភ័ណភាព សណ្តាប់ធ្នាប់ គឺនៅមិនទាន់គ្រប់គ្រាន់នោះទេតែតំបន់ទេសចរណ៍មួយត្រូវតែមាននូវផាសុកភាព និងជាតំបន់ដែលគ្មាន ឬមានការបំពុលទាំងប្រាំតិចតួច។ ផាសុកភាព គឺជាមូលហេតុដ៏ចម្បងមួយដែលភ្ញៀវទេសចរត្រូវការសម្រាប់ការលំហែកម្សាន្តនៅពេលសម្រាកពីការងារដែលពួកគេចង់បង្កើតបរិយាកាសរីករាយក្នុងដំណើរកម្សាន្តនីមួយៗ។ ផាសុកភាពនៃតំបន់ទេសចរណ៍ខេត្តកែប សំដៅទៅលើតំបន់ដែលគ្មាន ឬមានការបំពុលតិចតួច ដែលរដ្ឋបាលខេត្តកែបត្រូវរៀបចំប្រែក្លាយតំបន់ទេសចរណ៍ឱ្យមានទាំងសោភ័ណភាព សណ្តាប់ធ្នាប់ និងផាសុកភាព។ ដូច្នេះគេត្រូវរកឱ្យឃើញនូវប្រភពនៃការបំពុល ព្រមទាំងដំណោះស្រាយនានាដែលទាក់ទងទៅនឹងការបំពុលទាំងប្រាំមានដូចជាការបំពុលដោយសំឡេង ការបំពុលដោយសំណល់រឹង-រាង ការបំពុលខ្យល់ ការបំពុលទឹក និងការបំពុលដី។

#### ក. ការបំពុលដោយសំឡេង

សំឡេងអាចមានប្រភពចេញមកពី គ្រឿងចក្រ យានយន្ត ការនិយាយ ភ្លេង និងផ្សេងៗទៀតនៅពេលសំឡេងដែលមិនត្រូវការហើយបានប៉ះពាល់ដល់សកម្មភាពធម្មតា គឺជាការបំពុលដោយសំឡេង។ មនុស្សយើងមិនសូវទទួលស្គាល់សំឡេងជាការបំពុលទេ ដោយសារយើងមើលមិនឃើញ ឬធុំក្លិន។ ការបំពុលដោយសំឡេងនឹងធ្វើឱ្យតំបន់ទេសចរណ៍ខេត្តកែបបាត់បង់នូវផាសុកភាពមួយផ្នែកធំ ហេតុដូចនេះ ការដោះស្រាយការបំពុលដោយសំឡេងត្រូវតែរកឱ្យឃើញនូវប្រភព និងកត្តាចម្បងៗដែលជាហេតុនាំឱ្យកើតមានការបំពុល។ ប្រភព និងជាកត្តាដែលនាំឱ្យមានការបំពុលដោយសំឡេងមានដូចជា៖

- ការប្រើប្រាស់នូវម៉ាស៊ីនភ្លើងដែលធ្វើឱ្យមានការរំខានដោយសំឡេង
- ការប្រើប្រាស់យានយន្តជជុះដែលមានសំឡេងលាន់ឮខ្លាំង

[៣៨] គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/319596-2023-12-01-11-14-28.html ដកស្រង់ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២៤

- ការប្រើប្រាស់នូវគ្រឿងចក្រ គ្រឿងយន្តនៅតាមការដ្ឋានសាងសង់ ការសាងសង់សំណង់អាគារ
- សំឡេងចេញពីក្លឹបកម្សាន្ត ខារ៉ាអូខេជាដើមដែលមិនបានបំពាក់នូវឧបករណ៍ទប់សំឡេង
- ការប្រើប្រាស់សំឡេងទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ធុងបាស់លាន់ឮសំឡេងខ្លាំង
- សំឡេងចេញពីការប្រើប្រាស់នូវឧបករណ៍បំពងសំឡេងគ្រប់ប្រភេទជាដើម។[៣៩]

ដើម្បីដោះស្រាយការបំពុលដោយសំឡេងក្នុងការជួយតំបន់ទេសចរណ៍ខេត្តកែបឱ្យមាននូវផាសុកភាពដល់ប្រជាជន ពិសេសភ្ញៀវទេសចរ ការរៀបចំត្រូវមានវិធានការដោះស្រាយ ទប់ស្កាត់ការបំពុល ដូចខាងក្រោម៖

- ត្រូវធ្វើការអប់រំ ផ្សព្វផ្សាយដល់ប្រជាជនឱ្យស្គាល់អំពីការបំពុល និងផលប៉ះពាល់ដោយសំឡេង
- ចំពោះការនាំចូលទោចក្រយានយន្តគួរដាក់លក្ខខណ្ឌចំពោះពន្ធឱ្យខ្ពស់
- ចូលរួមកាត់បន្ថយការប្រើប្រាស់រថយន្តជជុះដែលលាន់ឮសំឡេងខ្លាំង
- បញ្ចូលឧបករណ៍តាមដានសំឡេងដែលនៅក្បែរការិយាល័យ មន្ទីរពេទ្យ គ្រឹះស្ថានសិក្សាអប់រំ
- ត្រូវណែនាំ អប់រំដល់ម្ចាស់ឧស្សាហកម្ម សហគ្រាស ក្រុមហ៊ុន ភោជនីយដ្ឋានឱ្យសាងសង់រោងដែលដាក់ម៉ាស៊ីនត្រូវធ្វើបំពង់ការពារការរំខានដោយសំឡេង
- បង្កើតគណៈកម្មការត្រួតពិនិត្យតាមដានឧស្សាហកម្ម សិប្បកម្ម សហគ្រាស ក្រុមហ៊ុន ខារ៉ាអូខេ ភោជនីយដ្ឋាន និងលំនៅដ្ឋានណាដែលពុំបានអនុវត្តន៍តាមការណែនាំ។[៤០]

### ខ. ការបំពុលដោយសំណល់រឹង-រាវ

យើងបានដឹងហើយថា វិស័យទេសចរណ៍បានបង្កផលប៉ះពាល់ក្នុងការបង្កើតឱ្យមានសំរាមក្នុងមូលដ្ឋាន យោងតាមរបាយការណ៍សិក្សាវិសាលភាព ស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែបបានបង្ហាញថាស្ថានភាពនៃការគ្រប់គ្រងសំណល់រឹង-រាវក្នុងខេត្តកែប គឺទទួលរងឥទ្ធិពលពីវិស័យទេសចរណ៍នៅតាមរដូវកាល។ គម្លាតគ្នាប្រចាំថ្ងៃក្នុងការបង្កើតសំរាម គឺខុសគ្នាប្រមាណ ១០តោន រវាងរដូវមានអ្នកទេសចរច្រើន និងរដូវមានអ្នកទេសចរតិចដោយក្នុងនោះរដូវមានទេសចរតិចត្រូវបានប៉ាន់ប្រមាណថាការបង្កើតនូវសំរាមចន្លោះអាចពី៤៥-៥១តោនក្នុងមួយថ្ងៃ និងរដូវកាលដែលមានទេសចរច្រើន គឺសំរាមមានប្រមាណ ៥៥តោន។[៤១] ក្នុងនោះដែរ ការបំពុលដោយ

[៣៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៤, ទំព័រទី៤៣-៤៤

[៤០] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៤, ទំព័រទី៤៦

[៤១] របាយការណ៍សិក្សាវិសាលភាព ស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែប, ចុះខែសីហា ឆ្នាំ២០២០, ទំព័រទី១

សំណល់រឹង-រាវនឹងបង្កជាបញ្ហាសណ្តាប់ធ្នាប់ គ្មានរបៀបរៀបរយ និងធ្វើឱ្យមានការបាត់បង់នូវសោភ័ណភាព ពិសេស ផាសុកភាពក្នុងតំបន់ទេសចរណ៍ខេត្តកែបនេះតែម្តង ដែលជាហេតុនាំឱ្យភ្ញៀវទេសចរមានការថមថយចុះ និងរងនូវការបំពុលទៅដល់សុខភាពរបស់មនុស្ស។ តាមរបាយការណ៍សិក្សាវិសាលភាព ស្តីពីការគ្រប់គ្រង សំណល់រឹងនៅក្នុងខេត្តកែបក៏ដូចជាតំបន់ទេសចរណ៍ទាំងមូលបានប្រឈមជាមួយនឹងបញ្ហាសំណល់រឹង និងជាប្រភពមួយដ៏សំខាន់ដែលនាំឱ្យមានការបំពុលដូចជា៖

- ការគ្របដណ្តប់មិនបានពេញលេញនៃសេវាប្រមូលសំរាម
- ការបោះចោលសំរាមដោយខុសច្បាប់ និងការដុតសំណល់ពាសវាលពាសកាល
- ទីលានចាក់សំរាមមិនមានប្រតិបត្តិការ និងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ
- ប្រព្រឹត្តិកម្មកាកសំណល់តិចតួចនៅមុនការចោលសំណល់រឹង-រាវ
- ការយល់ដឹងរបស់សាធារណជនមានកម្រិតទាបអំពីបញ្ហា និងការគ្រប់គ្រងសំណល់រឹង-រាវ។[៤២]

ដើម្បីរៀបចំឱ្យខេត្តកែបមាននូវផាសុកភាព មានសណ្តាប់ធ្នាប់ របៀបរៀបរយ ពិសេសគឺសោភ័ណភាព ការដោះស្រាយបញ្ហានេះ ត្រូវតែអនុវត្តទៅតាមវិធានច្បាប់ដែលគ្រប់គ្រងទៅលើការគ្រប់គ្រងលើសំណល់រឹង-រាវ។ មន្ទីរបរិស្ថានទូទាំងប្រទេស និងអាជ្ញាធរពាក់ព័ន្ធ ពិសេសថ្នាក់ដឹកនាំខេត្តកែបត្រូវបំពេញតួនាទី និងភារកិច្ច ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីកាគ្រប់គ្រងសំរាម និងសំណល់រឹង-រាវនៅទីប្រជុំជនដូចជា៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ អំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងផ្សព្វផ្សាយ
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម
- ការផ្សព្វផ្សាយពីការកែច្នៃឡើងវិញ និងការប្រើប្រាស់សេវាគ្រប់គ្រងសំរាមក្នុងទីប្រជុំជន
- ធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយ ការបង្កើត
- ផ្តល់យោបល់បច្ចេកទេស ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម ឬគម្រោងសេវាគ្រប់គ្រងសំណល់ក្នុងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាមក្នុងទីប្រជុំជន

[៤២] របាយការណ៍សិក្សាវិសាលភាព ស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែប, ចុះខែសីហា ឆ្នាំ២០២០, ទំព័រទី៣០

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងសកម្មភាពកែច្នៃសំរាមនៅទីប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងចូលរួមការអនុវត្តន៍វិធានការពិន័យអន្តរកាលលើបទល្មើសពាក់ព័ន្ធនឹងសំរាមនៅទីប្រជុំជន។

តាមរយៈនេះ ការដឹកនាំលើការគ្រប់គ្រងសំរាមនៅទីប្រជុំជន ពិសេសនៅតំបន់ទេសចរណ៍ខេត្តកែបឱ្យមានអនាម័យ និងជាសុកភាព មន្ត្រីបរិស្ថានបានចុះធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋអំពីផលប៉ះពាល់នៃសំណល់ប្លាស្ទិកចំពោះបរិស្ថានសមុទ្រ និងរបៀបទុកដាក់សំរាមឱ្យបានត្រឹមត្រូវដើម្បីលើកកម្ពស់សោភ័ណភាពខេត្តកែបឱ្យកាន់តែប្រសើ។[៤៣] មន្ទីរបរិស្ថានខេត្តកែបក៏ធ្លាប់បានរៀបចំទិវាអនាម័យបរិស្ថាន នៅតំបន់សហគមន៍នេសាទភូមិថ្មី ក្រោមប្រធានបទ "**មាតុភូមិយើង កាតព្វកិច្ចយើង ស្អាត និងបៃតង**" ដើម្បីជាការរួមចំណែកក្នុងការបណ្តុះផ្នត់គំនិត និងឥរិយាបថរបស់ប្រជាជនឱ្យស្រឡាញ់បរិស្ថានកាន់តែខ្លាំង និងមានស្មារតីចូលរួមនៅក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ និងការរស់នៅប្រកបដោយចីរភាព។[៤៤] ដើម្បីកំណត់ទីតាំងមួយសម្រាប់ដាក់សំរាម ខេត្តកែបបានបង្កើតទីលានចាក់សំរាមមួយដ៏ធំ ដែលសាងសង់ឡើងក្នុងភូមិដំណាក់ចង្អើរ ឃុំព្រៃធំ ក្រុងកែប ក្នុងដីទំហំសរុប ១៤ហិកតា ទីលាននេះមាន ០៤រណ្តៅ និងអាចផ្ទុកសំរាមចំនួន ៦សែនម៉ែត្រត្រីគុណក្នុងរយៈពេល២០ឆ្នាំ។[៤៥]

### គ. ការបំពុលខ្យល់

ការបំពុលខ្យល់ត្រូវបានបែងចែកជា ០២ប្រភព គឺប្រភពចល័ត និងប្រភពអចល័ត។ ប្រភពចល័ត គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍មានដូចជា យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្តជាដើម។ ចំណែកប្រភពអចល័ត គឺជាប្រភពដែលស្ថិតនៅទីតាំងជាអចិន្ត្រៃយ៍មួយកន្លែងដូចជា រោងចក្រ សហគ្រាស ឃ្លាំង ស្តុកសម្ភារៈ ការដ្ឋាន សំណង់ ឡដុតសំរាម សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ។ តាមការសិក្សាលើការបំពុលខ្យល់កើតមានឡើង គឺភាគច្រើនបណ្តាលមកពីមូលហេតុដូចជា៖

- រថយន្ត និងទោចក្រយានយន្តចាស់ៗ ហើយពុំមានការថែទាំបានល្អ
- ការប្រើប្រាស់ឥន្ធនៈមិនស្អាត (ដូចជាសាំងដែលមានបន្ថែមជាតិសំណ)
- កំណើននៃការប្រើប្រាស់ថាមពល និងម៉ាស៊ីនភ្លើងដែលគ្មានប្រសិទ្ធភាពសម្រាប់ផលិតអគ្គិសនី

---

[៤៣] គេហទំព័រ https://www.moe.gov.kh/index/43843 ដកស្រង់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤

[៤៤] គេហទំព័រ https://khmercm.com/national/7623 ដកស្រង់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤

[៤៥] គេហទំព័រ https://eacnews.asia/home/details/22899 ដកស្រង់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤

- ការប្រើប្រាស់គ្រឿងចក្រហួសសម័យក្នុងឧស្សាហកម្ម
- ផ្សែងពុលដែលចេញពីរោងចក្រ សហគ្រាស ឧស្សាហកម្ម ភោជនីយដ្ឋាននានា
- ចំហេះឥន្ធនៈផូស៊ីលនៅក្នុងរថយន្ត ទោចក្រយានយន្ត រោងចក្រ
- ការដុតអុស លាមកសត្វ និងសំណល់ពីដំណាំ សម្រាប់ដាំស្ល បំភ្លឺ ឬយកកម្តៅ
- ការដុតព្រៃឈើ និងវាលស្មៅនៅតំបន់ត្រូពិច ដើម្បីបានដីយកដំណាំជាដើម។[៥៦]

តំបន់ទេសចរណ៍ខេត្តកែប ត្រូវបានទទួលរងនូវការបំពុលខ្យល់មានលក្ខណៈបំពុលមិនសូវជាច្រើនប៉ុន្មានទេ តែការបំពុលខ្យល់កើតឡើងច្រើនខ្លាំងសម្រាប់តំបន់ទេសចរណ៍នេះ ពិសេសគឺនៅថ្ងៃពិធីបុណ្យធំៗ ដោយសារកំណើនការធ្វើចរាចរណ៍នៅតាមដងផ្លូវ ហើយគ្រឿងយន្តត្រូវបានបញ្ចេញនូវឥន្ធនៈជាច្រើនចេញមកបរិយាកាស រីឯនៅតាមភោជនីយដ្ឋាន ផ្សារក្តាម សណ្ឋាគារ កន្លែងកម្សាន្ត គឺមានការអាំងគ្រឿងសមុទ្រច្រើនជាហេតុធ្វើឱ្យផ្សែងភាយទៅលើអាកាស និងបង្កើតបានជាការបំពុលខ្យល់ មួយវិញទៀតនៅក្នុងពិធីបុណ្យម្តងៗ គឺតែងតែបង្កើតឱ្យមាននូវសំរាមគ្រប់បែបយ៉ាង បូកផ្សំនឹងការគ្រប់គ្រងសំរាមមិនបានល្អ រួមទាំងភ្ញៀវទេសចរ អាជីវករដែលខ្វះការយល់ដឹងពីផលប៉ះពាល់ដោយសំរាម និងការគ្រប់គ្រង ដែលជាហេតុបង្កជាក្លិនស្អុយខ្លាំងបំពុលទៅលើខ្យល់នាំឱ្យប៉ះពាល់ដល់សុខភាព ពិសេស តំបន់ទេសចរណ៍ខេត្តកែប គឺបាត់បង់សោភ័ណភាព និងគ្មានផាសុកភាពជាខ្លាំង។

- **ការដោះស្រាយការបំពុលខ្យល់**

ដើម្បីធ្វើឱ្យគុណភាពខ្យល់នៅតំបន់ទេសចរណ៍ខេត្តកែបមានភាពបរិសុទ្ធស្រស់ស្រាយ និងផាសុកភាព មន្ទីរបរិស្ថានខេត្តកែបត្រូវអនុវត្តន៍តាមវិធានការមានចែងក្នុងច្បាប់ដូចជា៖

- ត្រូវចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃ និងការដុតសំរាម សំណល់រឹងនៅតាមទីសាធារណៈ
- ត្រូវចាត់វិធានការ និងគ្រប់គ្រងការឆេះនៅតាមទីលានចាក់សំណល់
- ប្រើប្រាស់យានយន្តស្របតាមបច្ចេកទេស
- កាត់បន្ថយការប្រើប្រាស់សារធាតុគីមីពុល
- ការធ្វើសម្អាតអនាម័យនៅតាមដងផ្លូវ និងទីសាធារណៈ

[៥៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៤, ទំព័រទី៤៧-៤៨

- ត្រូវធ្វើការតាមដាន និងពិនិត្យទៅលើរោងចក្រដែលបំពុល
- អប់រំប្រជាពលរដ្ឋអំពីផលប៉ះពាល់ ដែលបណ្តាលមកពីការបំពុលខ្យល់
- ត្រូវរឹតបន្តឹងផ្នែកច្បាប់ និងជំរុញការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន
- ត្រូវមានវិធានការពិនិត្យ តាមដាននៅតាមរោងចក្រ សហគ្រាសដែលអាចបង្កផលប៉ះពាល់
- ត្រូវចាត់វិធានការទប់ស្កាត់ការហុយធូលីពីការដ្ឋានសំណង់ និងតាមដងផ្លូវសាធារណៈ។[៤៧]

### ឃ. ការបំពុលទឹក

ការបំពុលទឹក គឺជាសកម្មភាពមួយដែលធ្វើឱ្យប្រភពទឹកដូចជាសមុទ្រ ទន្លេ បឹងបួ ស្ទឹង ព្រែក ដែលរងនូវការកខ្វក់ និងគ្មានអនាម័យ ហើយភាគច្រើននៃការកខ្វក់ទឹកនេះបង្កឡើងដោយមនុស្សតែម្តងនៅពេលដែលគ្មានការតាមដានត្រួតពិនិត្យបានត្រឹមត្រូវ។ ជាទូទៅ ការបំពុលទឹក គឺជាការធ្វើឱ្យកខ្វក់ដល់ទឹកនៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម។ ប្រភពនៃការបំពុលទឹកចែកចេញជា ០២ប្រភេទ មានប្រភពបំពុលចំណុចដែលជាប្រភពបញ្ចេញកាកសំណល់ចូលទៅក្នុងបរិស្ថានតាមរយៈបំពង់បង្ហូរលូ ឬប្រឡាយពីទីតាំងច្បាស់លាស់មួយដូចជា រោងចក្រឧស្សាហកម្ម អណ្តូងប្រេងកាត ឬរោងចក្រសម្អាតទឹកលូសម្អុយជាដើម។ មួយទៀត ប្រភពបំពុលរាយប៉ាយ ជាប្រភពដែលបង្កឱ្យមានការបំពុលដោយសារសារធាតុបំពុលពីដីដែលហូរធ្លាក់ចូលទៅក្នុងទឹកពីផ្ទៃដីនៃតំបន់ដ៏ធំមួយ។ ប្រភពរាយប៉ាយមានដូចជា លំហូរនៃកសិកម្ម សំណល់ពីតំបន់អាជីវកម្មរ៉ែ សំណល់ទីក្រុង និងកម្ទេចកំណពីការដ្ឋានជាដើម។ ការបំពុលទឹកទាំងនេះភាគច្រើន គឺបណ្តាលមកពីសំណល់រោងចក្រ កសិកម្ម និងនៅតាមគេហដ្ឋាន ដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងទៅដល់សុខភាពមនុស្ស និងសត្វ ព្រមទាំងគុណភាពបរិស្ថាននៃប្រភពទឹកទាំងមូល។[៤៨] ជាក់ស្តែងសម្រាប់តំបន់ទេសចរណ៍ខេត្តកែប ការបំពុលទឹករងនូវការបំពុលភាគច្រើន គឺនៅតំបន់ទេសចរណ៍នេះឯងដោយប្រភពបំពុលចេញពីផ្សារក្តាម សណ្ឋាគារ ផ្ទះសំណាក់ បឹងហ្គាឡូ-រីស៊ត និងទីកន្លែងកម្សាន្តដទៃផ្សេងទៀត ចំណែកការបំពុលទឹកដែលហូរចេញពីរោងចក្រ សហគ្រាស គឺច្បាប់ហាមឃាត់មិនឱ្យមានការសាងសង់នោះទេនៅក្នុងតំបន់ទេសចរណ៍ក្នុងខេត្តកែប ក្រៅពីនេះការបោះចោលសំរាមគ្រប់ប្រភេទរបស់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋនៅមូលដ្ឋានចូលទៅក្នុងទឹកក៏ជាកត្តារួមចំណែកដែលបានធ្វើឱ្យទឹកទទួលរងនូវការបំពុលផងដែរ។

[៤៧] គេហទំព័រ https://freshnewsasia.com/index.php/en/localnews/229877-2022-02-01-06-14-26.html ដកស្រង់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤

[៤៨] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៤, ទំព័រទី៥០-៥១

➢ **ការដោះស្រាយការបំពុលទឹក**

ដើម្បីដោះស្រាយនូវការបំពុលទឹក ការរៀបចំតំបន់ទេសចរណ៍ក្នុងខេត្តកែប ថ្នាក់ដឹកនាំត្រូវអនុវត្តន៍តាមវិធានការ ស្តីពីការត្រួតពិនិត្យប្រភពបំពុលទឹកដែលច្បាប់បានកំណត់មានដូចជា៖

- ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យនូវរាល់ការចាក់ចោល ការបង្ហូរសំណល់រាវពីប្រភពបំពុល
- ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងសំណល់រាវនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល
- ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស
- ការវិភាគគំរូតាងសំណល់រាវដែលបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន
- ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួនទៅតាមចំនួនទឹកប្រាក់ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលអាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួននៅតាមមន្ទីរពិសោធន៍របស់រដ្ឋ ឬឯកជនដទៃទៀតដែលមានការទទួលស្គាល់ហើយដែលមន្ទីរពិសោធន៍នោះត្រូវអនុវត្តន៍វិធីសាស្ត្រវិភាគឱ្យដូចទៅនឹងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។

**ង. ការបំពុលដី**

ការបំពុលដី គឺជារឿងមួយដែលគេចមិនផុតទេសម្រាប់តំបន់ទេសចរណ៍ទាំងអស់ ជាក់ស្តែងសម្រាប់តំបន់ទេសចរណ៍ខេត្តកែបតែងតែរងនូវការបំពុលដី ដែលកើតឡើងដោយការគ្រប់គ្រងមិនបានត្រឹមត្រូវទៅតាមបច្ចេកទេស និងការបោះចោលដោយគ្មានសណ្តាប់ធ្នាប់ ដែលជាហេតុធ្វើឱ្យតំបន់ទេសចរណ៍ខេត្តកែបបាត់បង់សោភ័ណភាព សណ្តាប់ធ្នាប់ ពិសេសគ្មានផាសុកភាព ដូច្នោះយើងត្រូវសិក្សាស្វែងយល់ពីប្រភពនៃការបំពុល និងការស្វែងរកនូវដំណោះស្រាយចំពោះបញ្ហាដែលបានកើតឡើងធ្វើឱ្យមានការបំពុលដី។

➢ **ការបំពុលដីមានប្រភព និងមូលហេតុសំខាន់ៗ ដូចជា៖**

- ភ្ញៀវទេសចរមកលេងកម្សាន្តមានតម្រូវការប្រើប្រាស់ច្រើន និងបន្សល់សំណល់គ្រប់ប្រភេទ
- ការគ្របដណ្តប់មិនពេញលេញនៃសេវាប្រមូលសំណល់
- ការបោះចោលសំរាម និងការដុតសំណល់ពាសវាលពាលកាល

- ការយល់ដឹងរបស់សាធារណជនមានកម្រិតទាបអំពីបញ្ហា និងតួនាទីក្នុងការគ្រប់គ្រងសំណល់
- ដែនសមត្ថកិច្ចមិនច្បាស់លាស់សម្រាប់ការគ្រប់គ្រងសំណល់ក្នុងខេត្តកែប
- ការគាំទ្រ ការពិនិត្យតាមដាន និងវាយតម្លៃនៅមានកម្រិតកំណត់ពីថ្នាក់ជាតិ។

➢ **ការដោះស្រាយការបំពុលដី**

ដើម្បីដោះស្រាយការបំពុលដីនៅតំបន់ទេសចរណ៍ក្នុងខេត្តកែប និងជួយឱ្យខេត្តកែបមានសោភ័ណភាព សណ្តាប់ធ្នាប់ និងជាទីកន្លែងដែលមានផាសុកភាពត្រូវមានវិធានការដោះស្រាយដូចជា៖

- កំណត់ពីធនធានមនុស្ស និងឧបករណ៍ដែលចាំបាច់ដើម្បីពង្រីកសេវាកម្មប្រមូលសំណល់
- បង្កើតផែនទីបង្ហាញផ្លូវសម្រាប់ការពង្រីកសេវាកម្មប្រមូលសំណល់
- រៀបចំ និងអនុវត្តន៍យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់បណ្តាលមកពីសំរាម
- កាត់បន្ថយការប្រើប្រាស់សារធាតុគីមី
- តាមដាន និងចុះត្រួតពិនិត្យទៅលើរោងចក្រ សហគ្រាសដែលអាចធ្វើឱ្យមានការបំពុលដី
- ពង្រឹងការអនុវត្តច្បាប់ស្តីពីការការពារបរិស្ថាន
- បង្កើតកិច្ចសន្ទនាជាមួយអ្នកបង្កើតសំណល់ធំៗ (ទីផ្សារ) ស្តីពីការគ្រប់គ្រងសំណល់សរីរាង្គ
- ផ្តួចផ្តើមភាពជាដៃគូដើម្បីអភិវឌ្ឍន៍ប្រព្រឹត្តិកម្មខ្នាតតូចលើសំណល់សរីរាង្គ
- ជំរុញការញែកសំណល់នៅប្រភពផ្ទាល់ក្នុងគោលបំណងកែច្នៃឡើងវិញ
- ជំរុញកិច្ចខិតខំក្នុងការប្រមូលសំណល់ក្នុងសណ្ឋាគារ ភោជនីយដ្ឋាន។

**២.២.២.៣. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសំណង់**

រដ្ឋបាលខេត្តកែបបានរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ ព្រមទាំងកែលំអសោភ័ណភាពតាមដងផ្លូវ ទីធ្លាសាធារណៈ រមណីយដ្ឋានទេសចរណ៍ ឆ្នេរកម្សាន្ត និងសាងសង់កែលំអនូវសមិទ្ធផលសំខាន់ៗដើម្បីធ្វើឱ្យតំបន់ទេសចរណ៍ក៏ដូចខេត្តកែបមានសណ្តាប់ធ្នាប់ល្អដូចជា ការសាងសង់សួនច្បារ ការដាក់បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ ការដាក់រូបសំណាក់ថ្មីៗ ការបង្កើតទីកន្លែងហាត់ប្រាណ ការស្ថាបនាកែលំអផ្លូវក្រាលកៅស៊ូ AC និងផ្លូវកៅស៊ូ DBST។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ សំណង់ និងការកែលំអសោភ័ណភាពទាំងអស់នោះរួមមាន៖

➢ សាងសង់របងសាលាខេត្ត បញ្ជាព័ត៌មាន និងប៉ុស្តិ៍យាមនៅមុខសាលាខេត្តកែប

- ការរៀបខឿនច្រាំងសមុទ្រអំពីថ្មភ្នំ និងចាក់ខ្សាច់ពង្រីកឆ្នេរសមុទ្រ
- ការសាងសង់ស្តូបតម្កល់រូបសំណាក់ព្រះបាទជ័យវរ្ម័នទី៧ ចំនួន ០២ទីតាំង
- ការដាំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ
- ការសាងសង់អគារការិយាល័យច្រកចេញចូលតែមួយសាលាស្រុកដំណាក់ចង្អើរ
- ការជួសជុលអគារការិយាល័យច្រកចេញចូលតែមួយសាលាខេត្តកែប និងបន្ទប់រង់ចាំ
- ការតបណ្តាញអគ្គិសនី និងដាក់ដងគោមភ្លើង អំពូលភ្លើងបំភ្លឺផ្លូវសាធារណៈ
- ការដាក់បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ ៦៩បង្គោល ដងគោមអំពូលភ្លើងចំនួន ២១៣ដងគោម
- ការសាងសង់ឈាបនដ្ឋាន ០១កន្លែង ទីតាំងស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប
- ការសាងសង់ទីលានទុកសម្រាម ០១កន្លែង ស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប
- គម្រោងដាំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ និងតបណ្តាញអគ្គិសនីចំនួន ២៥០បង្គោល
- ការរៀបចំខឿនច្រាំងសមុទ្រអំពីថ្មភ្នំ កម្ពស់ ៦ម៉ែត្រ មានប្រវែងខឿនសរុប ១៦៥ម៉ែត្រ
- ការជួសជុលផ្លូវក្រាលកៅស៊ូ DBST ប្រវែង ៥០០ម៉ែត្រ ទទឹង ៥ម៉ែត្រ (ផ្លូវវត្តភ្នំព្រួស)
- ការសាងសង់សាលប្រជុំស្តង់ដាមានបណ្តោយ ៣៦,៤០ម៉ែត្រ ទទឹង ២៩,៧០ម៉ែត្រ ផ្ទៃក្រឡាសរុប ១០៨១,០៨ម៉ែត្រការ៉េ។[៩៩]

## ២.៣. បញ្ហាប្រឈម យន្តការដោះស្រាយ ព្រមទាំងសមិទ្ធផល

ដើម្បីរៀបចំតំបន់ទេសចរណ៍ខេត្តកែបឱ្យមានដំណើរការអភិវឌ្ឍន៍ស្របតាមផែនការដែលបានដាក់ចេញ រដ្ឋបាលខេត្តកែបត្រូវដោះស្រាយបញ្ហាប្រឈមមួយចំនួន តាមរយៈការចេញនូវវិធានការចាំបាច់ក្នុងការទប់ស្កាត់ ក៏ដូចជាធ្វើឱ្យមានការសម្រេចចេញនូវសមិទ្ធផលដែលបានកំណត់ផងដែរ។

### ២.៣.១. បញ្ហាប្រឈម

ការអភិវឌ្ឍ និងរៀបចំតំបន់ទេសចរណ៍ខេត្តកែប បានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនដែលជាកត្តាសំខាន់មួយមិនអាចជួយឱ្យខេត្តកែបមានភាពរីកចម្រើនសម្រេចទៅតាមផែនការមេ ដែលបានកំណត់នោះទេ។

---

[៩៩] របាយការណ៍សង្ខេប ស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦នៃរដ្ឋសភាឆ្នាំ២០១៨-២០២២, ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣, ទំព័រទី៥៤៧

ជាក់ស្តែង យើងត្រូវសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់អំពីមូលហេតុដែលជាឫសគល់នៃបញ្ហាប្រឈមនានាសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប។ តាមរយៈ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥"** បានបង្ហាញឱ្យឃើញថា វិស័យមួយចំនួននៅក្នុងខេត្តកែប បានជួបប្រទះនឹងបញ្ហាប្រឈមដែលចាំបាច់ត្រូវមានវិធានការជាចាំបាច់ដើម្បីដោះស្រាយ។ វិស័យដែលបានរកឃើញថា មានបញ្ហាប្រឈម និងចាំបាច់ដោះស្រាយរួមមានដូចជា វិស័យសន្តិសុខ វិស័យសុខាភិបាល វិស័យធនធានទឹក និងការគ្រប់គ្រងទឹកជំនន់ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ការផ្គត់ផ្គង់អគ្គិសនី ការផ្គត់ផ្គង់ទឹកស្អាត ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

- **វិស័យសន្តិសុខ**

វិស័យសន្តិសុខ គឺជាផ្នែកមួយនៃសណ្តាប់ធ្នាប់ខេត្តកែប និងធានាដល់សុវត្ថិភាពភ្ញៀវទេសចរក្នុងការមកសម្រាកកម្សាន្តក្នុងតំបន់ទេសចរណ៍ខេត្តកែប។ បច្ចុប្បន្ននេះ កងកម្លាំងមានសមត្ថកិច្ចបានខិតខំយកចិត្តទុកដាក់បំពេញភារកិច្ចឱ្យបានល្អនៅតាមមូលដ្ឋានសំខាន់ៗ ប៉ុន្តែដើម្បីត្រៀមខ្លួនទទួលស្វាគមន៍នូវភ្ញៀវទេសចរជាលក្ខណៈទ្រង់ទ្រាយធំ ខេត្តកែបត្រូវដោះស្រាយបញ្ហាប្រឈមមួយចំនួនមានដូចជា កង្វះចំនួនកម្លាំងសមត្ថកិច្ច កង្វះមន្ត្រីនគរបាលដែលចេះភាសាបរទេស និងចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើប ព្រមទាំងកង្វះខាតទៅលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា ភ្លើងបំភ្លឺនៅតាមទីសាធារណៈជាដើម។

- **វិស័យសុខាភិបាល**

វិស័យសុខាភិបាល ខេត្តកែបអាចផ្តល់សេវាកម្មល្អបង្គួរដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ប៉ុន្តែនៅពុំទាន់ឆ្លើយតបទៅនឹងតម្រូវការបានពេញលេញនៅឡើយទេ ពិសេសក្នុងករណីមានការកើនឡើងនៃចំនួនភ្ញៀវទេសចរ វិនិយោគិន និងប្រជាពលរដ្ឋមូលដ្ឋាន។ ក្នុងនោះដែរ ខេត្តកែបក៏កំពុងជួបប្រទះបញ្ហាប្រឈមទាក់ទងនឹងវិស័យសុខាភិបាលដូចជា កង្វះគ្រូពេទ្យឯកទេស គិលានុបដ្ឋាយិកា សម្ភារៈបរិក្ខារពេទ្យ និងសមត្ថភាពមន្ទីរពិសោធន៍នៅមានកម្រិត។ ហេតុដូចនេះ ដើម្បីត្រៀមខ្លួនទទួលភ្ញៀវទេសចរជាលក្ខណៈទ្រង់ទ្រាយធំ ពិសេសដើម្បីចូលរួមគាំទ្រដល់ការសម្រាកលំហែបែបប្រណិត ខេត្តកែបចាំបាច់ត្រូវធ្វើទំនើបកម្មវិស័យសុខាភិបាលបន្ថែមទៀត។

- **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តកែបក៏កំពុងយកចិត្តទុកដាក់យ៉ាងសកម្មក្នុងការគ្រប់គ្រង និងទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ទប់ស្កាត់ភាពអនាធិបតេយ្យ ជំរុញអនុលោមភាពសំណង់ ជំរុញការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ រៀបចំប្លង់គោលក្រុង ស្រុក រួមជាមួយនឹង

ការដោះស្រាយបញ្ហាដីធ្លីក្រៅប្រព័ន្ធតុលាការ និងចូលរួមកំណត់ព្រំដីព្រៃកោងកាង។ ទោះបីមានការប្រឹងប្រែងយ៉ាងនេះក្តី ខេត្តកែបក៏នៅជួបប្រទះនឹងបញ្ហាផ្សេងៗទៀតដែលទាមទារឱ្យមាននូវដំណោះស្រាយដូចជា ការទុកដីចោលមិនប្រើប្រាស់ ការមិនទាន់កំណត់អំពីប្រភេទនគរូបនីយកម្ម និងសំណង់ក្នុងខេត្តកែបឱ្យបានច្បាស់លាស់ ការទន្ទ្រាន និងការលួចចាក់ដីលុបព្រែក អូរ ដោយខុសច្បាប់ជាដើម។

- **ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍**

បច្ចុប្បន្ន ខេត្តកែបមានបណ្តាញផ្លូវថ្នល់ដែលជាប្រភេទផ្លូវខេត្ត ផ្លូវក្រុង និងផ្លូវលំជនបទ សរុបប្រវែង ៩១.០៩គីឡូម៉ែត្រ ក្នុងនោះផ្លូវមួយចំនួនមានការខូចខាតដោយទឹកជំនន់ មួយចំនួនទៀតមានព្រៃដុះទ្រុបទ្រុល និងកង្វះប្រព័ន្ធលូបង្ហូរទឹកឱ្យបានត្រឹមត្រូវ។ ទោះបីជាថ្មីៗនេះ ផ្លូវសំខាន់ៗត្រូវបានពង្រីក ហើយចំណតសម្រាប់រថយន្តក្រុង និងរថយន្តទេសចរណ៍ជាច្រើនកន្លែងត្រូវបានសាងសង់រួចហើយក្តី បញ្ហាការកកស្ទះចរាចរណ៍នៅតែបន្តមានក្នុងពេលមានភ្ញៀវទេសចរច្រើន លើសពីនេះ ការរំលោភចំណីផ្លូវ ដូចជាការសាងសង់តូបអាជីវកម្ម ការចាក់ដីលុបប្រព័ន្ធផ្លូវទឹកហូរនៅជាបញ្ហាប្រឈមបង្កការកកស្ទះតាមផ្លូវ និងភាពអនាធិបតេយ្យ។ ក្នុងនេះដែរ តំបន់ឆ្នេរសមុទ្រខេត្តកែបដែលមានបណ្តុំកោះមួយចំនួនជាប៉ូលទេសចរណ៍តំបន់សំខាន់ ខេត្តកែបត្រូវការកំពង់ផែទេសចរណ៍សម្រាប់បម្រើ និងជួយគាំទ្រទៅដល់ទេសចរណ៍ក្នុងខេត្តកែប បច្ចុប្បន្ន ខេត្តកែបមានកំពង់ផែចំនួន ០១ប៉ុណ្ណោះ គឺកំពង់ផែទេសចរណ៍កោះទន្សាយលើដែនគោកខេត្តកែប ខណៈដែលកំពង់ផែមួយទៀតគឺស្ថិតនៅកោះទន្សាយផ្ទាល់ និងកំពុងសាងសង់ ក្រៅពីកំពង់ផែនេះ ខេត្តកែបមិនទាន់មានកំពង់ផែនៅគោលដៅទេសចរណ៍សំខាន់ៗមួយចំនួនទៀតនៅឡើយទេ ដែលជាគោលដៅទេសចរណ៍មានសក្តានុពលខ្ពស់។

- **វិស័យផ្គត់ផ្គង់ទឹកស្អាត**

ខេត្តកែបមានក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតចំនួន ០២ទីតាំង មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចែកចាយដល់ប្រជាពលរដ្ឋទូទាំងខេត្តកែប។ បច្ចុប្បន្ន ការតភ្ជាប់បណ្តាទុយោមេត្រូវបានសម្រេច ៨៥% នៅក្រុងកែប និង ៧០% នៅស្រុកដំណាក់ចង្អើរ។ រាជរដ្ឋាភិបាលមានទិសដៅតបណ្តាញទុយោមេឱ្យបានគ្រប់ផ្លូវទាំងអស់ ទូទាំងក្រុងកែប និងស្រុកដំណាក់ចង្អើរនៅត្រឹមឆ្នាំ២០២៥ ដើម្បីសម្រួលដល់ប្រជាជនទាំងអស់អាចតភ្ជាប់ ព្រមទាំងប្រើប្រាស់ទឹកស្អាតនេះបាន។ ទោះជាយ៉ាងនេះក្តី ខេត្តកែបពុំទាន់មានប្រភពទឹកជាយុទ្ធសាស្ត្រដែលអាចទ្រទ្រង់ដល់ការអភិវឌ្ឍ ការរីកចម្រើនខេត្តកែបនាពេលអនាគតនៅឡើយ និងទៅតាមតម្រូវការដែលចាំបាច់។

- **ការផ្គត់ផ្គង់អគ្គិសនី**

ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តកែបត្រូវបានអភិវឌ្ឍន៍ជាបន្តបន្ទាប់ជាមួយនឹងការតភ្ជាប់បណ្តាញអគ្គិសនីពី

អនុស្ថានីយផ្សេងៗដូចជា អនុស្ថានីយខេត្តកំពត និងឈូក ដែលមានសមត្ថភាពអាចផ្គត់ផ្គង់អគ្គិសនីសរុបប្រមាណ ១០០មេហ្គាវ៉ាត់ និងនាំចូលអគ្គិសនីពីប្រទេសវៀតណាមមានអនុភាព ២០មេហ្គាវ៉ាត់។ ខេត្តកែបមានប្រព័ន្ធចែកចាយអគ្គិសនីដល់គ្រប់មូលដ្ឋានក្នុងខេត្តកែប ប៉ុន្តែក្នុងគោលដៅអភិវឌ្ឍប៉ូលទេសចរណ៍សំខាន់មួយការផ្គត់ផ្គង់ត្រូវពង្រីកបន្ថែមទៀត ដើម្បីធានាលទ្ធភាពក្នុងការទ្រទ្រង់ការកើនឡើងសកម្មភាពទេសចរណ៍ក៏ដូចជាតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខេត្តកែបផងដែរ។

- **វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍**

ខេត្តកែបមានបញ្ហាប្រឈម ការខ្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងប្រៃសណីយ៍ដោយបណ្តាញប្រៃសណីយ៍ និងសេវាប្រៃសណីយ៍ក្នុងខេត្តកែបនៅមានកម្រិត ហើយសេវាទូរស័ព្ទ សេវាអ៊ីនធឺណែតនៅមានភាពខ្វះខាតនៅតំបន់មួយចំនួនដែលនាំឱ្យមានការលំបាកក្នុងការប្រាស្រ័យទាក់ទងគ្នា។ អាស្រ័យហេតុនេះ ខេត្តកែបត្រូវមានការអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ ដើម្បីលើកកម្ពស់បទពិសោធន៍របស់ភ្ញៀវទេសចរ និងការសម្រួលការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋ វិនិយោគិនក្នុងមូលដ្ឋាន។

- **វិស័យធនធានទឹក និងការគ្រប់គ្រងទឹកជំនន់**

ខេត្តកែបមានទំនប់ទឹកសរុបចំនួន ១១កន្លែង ក្នុងនោះទំនប់ទឹកដែលធានាទឹកបាននៅខែប្រាំងគឺមានចំនួន ០៨កន្លែង ដែលអាចផ្គត់ផ្គង់ដំណាំកសិកម្ម និងប្រើប្រាស់ជាប្រចាំថ្ងៃរបស់ប្រជាជនក្នុងតំបន់ ប៉ុន្តែខេត្តកែបគឺនៅមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកជំនន់នៅឡើយទេ ដោយតំបន់អង្គោលមួយផ្នែកធំ និងតំបន់ក្រុងកែបមួយផ្នែកតូចមានបញ្ហាប្រឈមនឹងគ្រោះទឹកជំនន់ដោយសារទឹកភ្លៀងជាប្រចាំ។ ដោយហេតុនេះហើយការស្វែងរកដំណោះស្រាយ ដើម្បីគ្រប់គ្រងទឹកជំនន់ គឺជាកិច្ចការចាំបាច់ដែលធានាការអភិវឌ្ឍតំបន់ទេសចរណ៍សំខាន់ៗក្នុងខេត្តកែប។[៥០]

### ២.៣.២. យន្តការដោះស្រាយ

ដើម្បីដោះស្រាយនូវបញ្ហាប្រឈម និងជំរុញការអភិវឌ្ឍទេសចរណ៍ក្នុងខេត្តកែប តាមរយៈ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥"** បានសម្រេចចេញយន្តការដោះស្រាយ និងយុទ្ធសាស្ត្រដែលទាក់ទងនឹងបញ្ហាដូចដែលបានលើកឡើងខាងលើរួមមាន៖

- **វិស័យសន្តិសុខមានដូចជា៖**

  - ត្រូវធ្វើទំនើបកម្មប្រព័ន្ធសន្តិសុខ ដោយបំពាក់ប្រព័ន្ធបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសន្តិសុខ

[៥០] ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣, ទំព័រទី៦-៩

- ត្រូវបំពាក់បន្ថែមនូវប្រព័ន្ធភ្លើងបំភ្លឺផ្លូវសាធារណៈនៅតាមគោលដៅសំខាន់ៗ
- ត្រូវបង្កើនចំនួន និងពង្រឹងសមត្ថភាពមន្ត្រីនគរបាលក្នុងមូលដ្ឋាន ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងខេត្តកែប ពិសេសនៅតាមតំបន់ប៉ូលទេសចរណ៍ទាំង ០៤តំបន់
- ត្រូវបន្តពង្រឹងការអនុវត្តគោលនយោបាយស្តីពី ភូមិ ឃុំ សង្កាត់មានសុវត្ថិភាពឱ្យបានយ៉ាងម៉ឺងម៉ាត់
- ការរៀបចំឱ្យមានឆ្មាំសមុទ្រ ដែលប្រចាំការនៅគ្រប់គោលដៅនៃរមណីយដ្ឋានឆ្នេរសមុទ្រ លើដីគោក និងនៅតាមកោះក្នុងខេត្តកែប ដើម្បីថែរក្សា ការពារសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។[៥១]

➢ **វិស័យសុខាភិបាលមានដូចជា៖**

- ត្រូវធ្វើទំនើបកម្មមន្ទីរពេទ្យបង្អែកក្នុងខេត្តកែប
- បន្តពង្រឹងការអនុវត្តវិធានការសុខាភិបាល វិធានសុវត្ថិភាពទេសចរណ៍ និងវិធានការនានា ដើម្បីកាត់បន្ថយហានិភ័យការឆ្លងជំងឺរាតត្បាតក្នុងខេត្តកែប ពិសេសនៅតាមគោលដៅទេសចរណ៍
- លើកទឹកចិត្តដល់វិស័យឯកជនក្នុងការសិក្សាលទ្ធភាពវិនិយោគទៅលើការបង្កើតមន្ទីរពេទ្យវេជ្ជសាស្ត្រឯកជន និងគ្លីនិកកម្រិតខ្ពស់ដែលមានមធ្យោបាយដឹកជញ្ជូនសង្គ្រោះបន្ទាន់គ្រប់គ្រាន់។

➢ **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានដូចជា៖**

- ត្រូវសិក្សាកំណត់អត្តសញ្ញាណរចនាបថសំណង់ និងនគរូបនីយកម្មសម្រាប់ប៉ូលអភិវឌ្ឍន៍នីមួយៗរបស់ខេត្តកែប ឱ្យមានស្តង់ដាររួមមួយច្បាស់លាស់ដោយឈរលើទិដ្ឋភាពវប្បធម៌ និងធម្មជាតិ
- ត្រូវបន្តការអនុវត្ត និងប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកែបចក្ខុវិស័យឆ្នាំ២០៣០ តាមសេចក្តីសម្រេចលេខ ០០១ ស.ស.រ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ត្រូវពន្លឿនការរៀបចំ និងអនុម័តប្លង់គោលប្រើប្រាស់ដីស្រុកដំណាក់ចង្អើរដែលនឹងបញ្ជាក់ពីទិសដៅនៃការអភិវឌ្ឍស្រុកទាំងមូល ដែលដើរតួជាផែនទីចង្អុលផ្លូវយ៉ាងសំខាន់គាំទ្រទៅដល់ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់ឆ្នេរអង្កាល និងប៉ូលទេសចរណ៍តំបន់ភ្នំវល្លិ៍ទាំងទិដ្ឋភាពសង្គម ទេសចរណ៍ បរិស្ថាន និងការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- កំណត់តំបន់សម្រាប់សាងសង់ច្រកចូល និងចេញខេត្តកែប ក្រុងកែប និងស្រុកដំណាក់ចង្អើរ

[៥១] សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមឆ្មាំសមុទ្រកម្ពុជា, លេខ ៧៥ សសរ, ចុះថ្ងៃទី៣៦ ខែធ្នូ ឆ្នាំ២០១០

- លើកកម្ពស់នវានុវត្តភាពនៃរចនាបថសំណង់ឱ្យសមស្របតាមអត្តសញ្ញាណនគរូបនីយកម្ម ដែលបានកំណត់នៅតាមតំបន់ប៉ូលទេសចរណ៍នីមួយៗ។

➢ **ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍មានដូចជា៖**

- ស្ថាបនា និងពង្រីកផ្លូវតភ្ជាប់តំបន់ទេសចរណ៍សំខាន់ៗ ពិសេសក្នុងស្រុកដំណាក់ចង្អើរ
- កែលំអ និងអភិវឌ្ឍន៍លូសាធារណៈឱ្យបានត្រឹមត្រូវដោយបែងចែករវាងលូទឹកភ្លៀង និងលូទឹកស្អុយ ដើម្បីធានាដល់ការគ្រប់គ្រងជំនន់ទឹកភ្លៀង និងសំណល់ទឹកកខ្វក់
- ពង្រឹងកិច្ចសហប្រតិបត្តិការឱ្យបានល្អប្រសើរ រវាងក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការស្ថាបនាលើផ្លូវគមនាគមន៍ និងការរៀបចំអភិវឌ្ឍន៍ប្រព័ន្ធលូសាធារណៈ
- ការសិក្សាកំណត់មុខងារផ្លូវឱ្យបានច្បាស់លាស់សម្រាប់រថយន្ត ទោចក្រយានយន្ត និងផ្លូវថ្មើរជើង ដើម្បីកែលំអផ្លូវគមនាគមន៍ ជាផ្លូវទេសចរណ៍ដ៏មានសោភ័ណភាព និងធានាសុវត្ថិភាព
- ការសិក្សា និងពិនិត្យលទ្ធភាពការសាងសង់ចំណតយានយន្តសាធារណៈដូចជានៅតំបន់ផ្សារក្តាម តំបន់ឆ្នេរកែប តំបន់មុខសាលាខេត្តកែប និងតំបន់ឆ្នេរអង្កោល ព្រមទាំងតំបន់ផ្សេងៗទៀត
- ការសិក្សា និងកំណត់តំបន់សម្រាប់សាងសង់កំពង់ផែទេសចរណ៍ ដើម្បីចូលរួមគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍កីឡាលើទឹក ព្រមទាំងជំរុញឱ្យមានការប្រើប្រាស់ទូកកម្សាន្តនៅតាមសមុទ្រ។

➢ **វិស័យផ្គត់ផ្គង់ទឹកស្អាតមានដូចជា៖**

- ពង្រីកប្រព័ន្ធបណ្តាញទុយោមេ និងបណ្តាញសម្រាប់ចែកចាយទឹកស្អាតឱ្យបានដល់ផ្លូវគ្រប់ភូមិ ឃុំ សង្កាត់ទាំងអស់របស់ក្រុងកែប និងស្រុកដំណាក់ចង្អើរ
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត និងផលប៉ះពាល់នៃការប្រើប្រាស់ទឹកស្រះ ត្រពាំង អូរ និងអណ្តូងខួង
- សិក្សាលទ្ធភាពក្នុងការជំរុញការវិនិយោគជាលក្ខណៈទ្រង់ទ្រាយធំនៃវិស័យទឹកស្អាត
- ធ្វើអធិការកិច្ច ត្រួតពិនិត្យ និងតាមដានគុណភាពទឹកស្អាតឱ្យបានជាប្រចាំជាមួយនឹងការពង្រឹងប្រសិទ្ធភាពនៃការចែកចាយទឹកស្អាតឱ្យបានគ្រប់គ្រាន់ក្នុងខេត្តកែប
- លើកកម្ពស់ប្រសិទ្ធភាពការផ្គត់ផ្គង់ទឹកស្អាតទៅដល់គ្រប់លំនៅដ្ឋាន ពិសេសទៅដល់គ្រប់មូលដ្ឋានសំណង់អាគារទាំងអស់។

- **ការផ្គត់ផ្គង់អគ្គិសនីមានដូចជា៖**
    - រៀបចំគោលការណ៍ណែនាំ និងលើកទឹកចិត្តក្នុងការប្រើប្រាស់ថាមពលដែលកកើតឡើងវិញដល់គ្រប់មូលដ្ឋានអាជីវកម្ម ពិសេសមូលដ្ឋានអាជីវកម្មពាក់ព័ន្ធនឹងវិស័យទេសចរណ៍ខេត្តកែប ដែលស្ថិតនៅក្នុងតំបន់ពុំទាន់មានបណ្តាញអគ្គិសនីទៅដល់
    - សិក្សាពីតម្រូវការនៃការប្រើប្រាស់ និងការផ្គត់ផ្គង់អគ្គិសនី។
- **វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍មានដូចជា៖**
    - ពន្លឿន និងពង្រឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញប្រៃសណីយ៍
    - ធ្វើទំនើបកម្មប្រព័ន្ធអេកូឡូស៊ីប្រៃសណីយ៍ និងសេវាកម្មប្រៃសណីយ៍ក្នុងភូមិសាស្ត្រខេត្តកែប
    - ធ្វើការបន្តជំរុញការតភ្ជាប់ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឌីជីថល
    - បង្កើនការសាងសង់បណ្តាញខ្សែកាបអុបទិកដែលចែកចាយអ៊ីនធឺណិតល្បឿនលឿនទៅគ្រប់ទីកន្លែងក្នុងខេត្តកែប
    - ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល តាមរយៈការពន្លឿនកិច្ចដំណើរនៃការបរិវត្តកម្មឌីជីថលនៅក្នុងវិស័យទេសចរណ៍ឌីជីថលព័ត៌មាន។
- **វិស័យធនធានទឹក និងការគ្រប់គ្រងទឹកជំនន់មានដូចជា៖**
    - រៀបចំផែនការគ្រប់គ្រងធនធានទឹក និងទឹកជំនន់នៅក្នុងស្រុកដំណាក់ចង្អើរ និងក្នុងក្រុងកែបដោយផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងស្ទឹង អូរ និងព្រែកនានាតភ្ជាប់ទៅនឹងសមុទ្រ និងតំបន់ផ្ទៃរងទឹកភ្លៀង
    - បង្កើនកិច្ចសហការប្រតិបត្តិការ ផ្សព្វផ្សាយ ផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានស្តីពីអាកាសធាតុ ឧតុនិយម និងការគ្រប់គ្រងធនធានទឹកដល់គ្រប់ភាគីក្នុងវិស័យទេសចរណ៍
    - សិក្សាកំណត់តំបន់សម្រាប់ការសាងសង់អាងភ្លូកទឹកយុទ្ធសាស្ត្រ និងពង្រីកប្រព័ន្ធរំដោះទឹកភ្លៀងដើម្បីស្ទាក់យកទឹកភ្លៀសម្រាប់ការប្រើប្រាស់ និងកាត់បន្ថយហានិភ័យជំនន់។[៥២]

[៥២] ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣, ទំព័រទី២៣-២៦

### ២.៣.៣. សមិទ្ធផលសម្រេច

តាមរយៈការដឹកនាំរបស់រដ្ឋបាលខេត្តកែប ក្នុងរយៈពេល០៥ឆ្នាំ គិតចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ខេត្តកែបបានសម្រេចនូវសមិទ្ធផល និងស្នាដៃការងារសំខាន់ៗទាក់ទងនឹងការរៀបចំខេត្តកែបរួមមាន៖

❖ **វិស័យធនធានធម្មជាតិ និងបរិស្ថាន**

ខេត្តកែបមានព្រៃកោងកាងចំនួន ០៣កន្លែង ក្នុងទំហំ ១,០០៥ហិកតា ស្មៅសមុទ្រមាន ៣,០៩៥ហិកតា ផ្កាថ្មមាន ៥២,៥ហិកតា និងធនធានធម្មជាតិមាន ត្រីផ្សោត ជ្រូកទឹក អណ្តើកសមុទ្រ ត្រីសេះ ក្តាមសេះ ក្តាមថ្ម និងឧទ្យានជាតិកែប ដែលមានទំហំ ១,១៥២ហិកតា។ ធនធានទាំងអស់នេះត្រូវបានអភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាព។ តាមរយៈសមិទ្ធផលដែលមានក្នុងរបាយការណ៍ រដ្ឋបាលខេត្តកែបក៏បានបោះបង្គោលព្រំឧទ្យានជាតិកែបចំនួន ៩២បង្គោល បានដាំផ្កា ធ្វើសួនច្បារមុខសាលាក្រុងកែបដែលមានប្រវែង ៦០០ម៉ែត្រ បានធ្វើអាងប្រព្រឹត្តិកម្មសាធារណៈ ០៥គម្រោង បានបំពាក់ឡដុតសំរាមសំណល់រឹងវេជ្ជសាស្ត្រ និងសំណល់ដែលគ្រោះថ្នាក់មាន ០១គម្រោង ដាំដើមឈើបាន ៥១,០៨៦ដើម រៀបចំទុកដាក់ធុងសំរាមនៅតាមទីសាធារណៈ និងសួនច្បារនានាក្នុងខេត្តកែបចំនួន ៥៣៤ធុង បានដាក់ស្លាកប៉ាណូអប់រំ និងផ្សព្វផ្សាយអំពីបរិស្ថានមានចំនួន ៩៥ស្លាក និងបានធ្វើផ្លូវបេតុងជុំវិញឧទ្យានជាតិកែប ប្រវែង ៦,០០០ម៉ែត្រ។

❖ **វិស័យគមនាគមន៍**

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងទីប្រជុំជនក្នុងវិស័យគមនាគមន៍ រយៈពេល ០៥ឆ្នាំ ដូចជា៖

➢ **ការជួសជុល និងថែទាំ**

- បានជួសជុលផ្លូវ ដោយចាក់អ៊ុតបេតុងកៅស៊ូ A/C ប្រវែង ១៨,៧០៥គីឡូម៉ែត្រ
- បានជួសជុលផ្លូវ ដោយក្រាលកៅស៊ូពីរស្រទាប់ DBST ប្រវែង ១៩,៨៦គីឡូម៉ែត្រ
- បានជួសជុលផ្លូវ ដោយចាក់បេតុងសរសៃដែក RC ប្រវែង ១,៤១គីឡូម៉ែត្រ
- បានជួសជុលផ្លូវ ដោយក្រាលដីល្បាយថ្មភ្នំ ប្រវែង ៨,២៨០ម៉ែត្រ
- បានជួសជុលផ្លូវលំដីស ប្រវែង ៣៥,៤៤០គីឡូម៉ែត្រ
- បានជួសជុល និងថែទាំផ្លូវជាលក្ខណៈខួបដោយក្រាលល្បាយថ្មភ្នំ ប្រវែង ៦៥,៤៨គីឡូម៉ែត្រ
- បានជួសជុល និងថែទាំផ្លូវជាលក្ខណៈប្រចាំដោយក្រាលថ្មភ្នំ ប្រវែង ១៨៦,១៤៤គីឡូម៉ែត្រ។

➢ **ការងារស្ថាបនា និងសាងសង់**

- គម្រោងសាងសង់កំពង់ផែកែប-កោះទន្សាយលើទីតាំងកំពង់ផែចាស់ ចំនួន ០២កន្លែង
- គម្រោងសាងសង់អាងប្រព្រឹត្តិកម្មចម្រោះទឹកកខ្វក់នៅតំបន់ផ្សារក្តាម ចំនួន ០១កន្លែង
- រៀបជញ្ជាំងថ្មទប់ដី ការពារការបាក់ច្រោះជើងភ្នំផ្លូវជាតិលេខ ៣៣A ប្រវែង ៦៤ម៉ែត្រ
- បានស្ថាបនាទំនប់ក្រវាត់ដោយចាក់បំពេញថ្ម ប្រវែង ២០០ម៉ែត្រ
- បានសាងសង់ផ្លូវលំក្រួសក្រហម ប្រវែង ២៣,៤៩៥គីឡូម៉ែត្រ
- បានសាងសង់ផ្លូវលំដីស ប្រវែង ៤,៥២១គីឡូម៉ែត្រ
- ធ្វើផ្លូវបេតុង ប្រវែង ០,៧៨១គីឡូម៉ែត្រ
- សាងសង់លូប្រអប់មុខ២ កាត់ទទឹងផ្លូវ ប្រវែង ៤៨ម៉ែត្រ
- សាងសង់សួនច្បារពុះទ្រូងផ្លូវ ប្រវែង ១,១២០ម៉ែត្រ
- ការរៀបចំផ្លូវថ្មើរជើង(រៀបការ៉ូឡា) ប្រវែង ២,២គីឡូម៉ែត្រ។

➢ **ការងារវិនិយោគនៅខេត្តកែបក្នុងរយៈពេល ០៥ឆ្នាំ**

- ខេត្តកែបទទួលបានរួមមានការផ្តត់ផ្គង់សេវាអគ្គិសនីសម្រាប់វិនិយោគទូទាំងខេត្តកែប
- ការវិនិយោគទៅលើរមណីយដ្ឋានរ៉ូតុង រមណីយដ្ឋានឪសាន់ និងវិយ្យូវីស្សេត
- ការសាងសង់ផ្សាររាត្រី និងផ្សារក្តាម
- ការសាងសង់ចំណតជលយាន(កំពង់ផែសេះស)
- ចំណតរថយន្តទេសចរណ៍ និងអនាម័យឆ្នេរចាក់ខ្សាច់ថ្មី
- ការសាងសង់មណ្ឌលកម្សាន្ត និងអភិវឌ្ឍន៍បរិវេណឆ្នេរ
- គម្រោងខ្សែរ៉ក ZIP LINE។

❖ **វិស័យទេសចរណ៍**

➢ **ចំពោះការងារឧស្សាហកម្មទេសចរណ៍**

- សណ្ឋាគារមាន ១៧កន្លែង និងមានផ្ទះសំណាក់មាន ៥៨កន្លែង

- បឹងហ្គាឡូ-រីសតមាន ២១កន្លែង និងភោជនីយដ្ឋាន អាហារដ្ឋានមានចំនួន ៣៤កន្លែង
- ទូកដឹកភ្ញៀវទេសចរចំនួន ១៦គ្រឿង
- បានផ្តល់អាជ្ញាប័ណ្ណទេសចរណ៍មាន ៤០៦អាជ្ញាប័ណ្ណ
- ខារ៉ាអូខេមាន ០៨កន្លែង។

❖ **ស្ថិតិភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិពីឆ្នាំ២០១៨-២០២២**

យោងតាមរបាយការណ៍របស់ខេត្តកែប ចំនួនភ្ញៀវទេសចរមានប្រមាណ ៦,២៣២,៤៣៧នាក់ ដោយក្នុងផងដែរ ភ្ញៀវជាតិមានប្រមាណ ៦,០៦៧,៩២០នាក់ និងភ្ញៀវអន្តរជាតិមានប្រមាណ ១៦៤,៥១៧នាក់។

❖ **ការងារបណ្តុះបណ្តាលអាជីវកម្ម និងការផ្សព្វផ្សាយទេសចរណ៍ដូចជា៖**

➢ បានបើកវគ្គបណ្តុះបណ្តាល និងការងារផ្សព្វផ្សាយមាន ៥១វគ្គ

➢ បានផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយទេសចរណ៍មាន ៣៤ផ្ទាំងធំ និង ៣៥ផ្ទាំងតូច

➢ បានបោះពុម្ពសៀវភៅដែលទាក់ទង់នឹងការផ្សព្វផ្សាយទេសចរណ៍។

❖ **ការងារអភិវឌ្ឍន៍ និងការកែលំអសោភ័ណភាពរបស់អង្គភាពដូចជា៖**

➢ បានសម្របសម្រួលធ្វើអាងប្រព្រឹត្តិកម្មទឹកកខ្វក់មាន ០១គម្រោង

➢ បានបង្កើតសហគមន៍អេកូទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ភ្នំសរសៀមាន ០១គម្រោង

➢ បានរៀបចំផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥ មាន ០១គម្រោង

➢ បានស្នើសុំរថយន្តអគ្គីភ័យចំនួន ០២គ្រឿង។[៥៣]

សរុបជារួម ខេត្តកែបបានធ្វើការកែលំអ និងអភិវឌ្ឍន៍ទៅលើវិស័យជាច្រើនដែលបានជួយជំរុញ ព្រមទាំងលើកកម្ពស់នូវសោភ័ណភាព ពិសេសបានរៀបចំឱ្យខេត្តកែបមាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ ទៅលើវិស័យគមនាគមន៍ទាំងការសាងសង់ថ្មី និងការជួសជុល ការផ្សព្វផ្សាយទេសចរណ៍ ការបណ្តុះបណ្តាលអាជីវកម្ម ពិសេសបានធ្វើឱ្យមានការកើនឡើងការវិនិយោគ ក៏ដូចជាការកើនឡើងចំនួនភ្ញៀវទេសចរចូលមកសម្រាកលំហែ និងកម្សាន្តផងដែរ។

---

[៥៣] របាយការណ៍សង្ខេប ស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦នៃរដ្ឋសភាឆ្នាំ២០១៨-២០២២, ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣, ទំព័រទី៥៤៧-៥៥៥

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការស្រាវជ្រាវខាងលើរួចមក យើងសង្កេតថា ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបនារយៈពេលចុងក្រោយនេះឃើញថាមានការរីកចម្រើនខ្លាំងក្នុងវិស័យទេសចរណ៍ទាំងសោភ័ណភាព និងសណ្តាប់ធ្នាប់ ព្រមទាំងក្លាយជាតំបន់ទេសចរណ៍ដែលប្រកបដោយផាសុកភាពផងដែរ ដោយបានបន្សល់ទុកនូវសមិទ្ធផលដែលជាស្នាដៃយ៉ាងច្រើនសម្រាប់ខេត្តកែប ការអភិវឌ្ឍទាំងនេះបានធ្វើឱ្យតំបន់ទេសចរណ៍ខេត្តកែប បានទទួលនូវការទាក់ទាញភ្ញៀវទេសចជាច្រើនមកពីគ្រប់ទិសទីទាំងជាតិ និងអន្តរជាតិ ពិសេសនោះគឺ បានជួយទៅដល់ប្រជាពលរដ្ឋឱ្យមានការងារធ្វើ និងបានជួយដល់សេដ្ឋកិច្ចជាតិជាខ្លាំងផងដែរ តាមរយៈនេះ បានបង្ហាញឱ្យឃើញដែរថា រាជរដ្ឋាភិបាលក៏ដូចជាថ្នាក់ដឹកនាំខេត្តកែប គឺពិតជាបានខិតខំប្រឹងប្រែង តស៊ូ ព្រមទាំងយកចិត្តទុកដាក់ក្នុងការរៀបចំខេត្តកែបដោយស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងផែនការនានាសម្រាប់អភិវឌ្ឍន៍ខេត្តកែបដែលបានកំណត់ និងដាក់ចេញសម្រាប់អនុវត្តន៍។

ទន្ទឹមនឹងការរីកចម្រើនទាំងនេះ ការដឹកនាំ រៀបចំ និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ខេត្តកែបក៏បានជួបប្រទះនូវបញ្ហាប្រឈម និងផលវិបាកមួយចំនួនដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ខេត្តកែបដែលចាំបាច់ត្រូវធ្វើការស្វែងរកវិធានការនានាជាយុទ្ធសាស្ត្រក្នុងការដោះស្រាយ ជាពិសេសគឺត្រូវតែមានការចូលរួមពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ជាមួយនឹងប្រជាពលរដ្ឋផងដែរ ទើបធ្វើឱ្យការដោះស្រាយបញ្ហា និងការអភិវឌ្ឍស្របតាមផែនការទាំងអស់នេះ ទទួលបានជាលទ្ធផលសម្រាប់សង្គមជាតិ។ តាមរយៈនេះ វិស័យមួយចំនួនដែលមាននូវបញ្ហាខ្វះខាត និងទាមទារឱ្យមានដំណោះស្រាយព្រមទាំងជាវិស័យដែលជួយគាំទ្រដល់ការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបរួមមាន វិស័យគមនាគមន៍ វិស័យធនធានទឹក សុខាភិបាល បរិស្ថាន ការផ្គត់ផ្គង់អគ្គិសនី ការគ្រប់គ្រងសំណល់រឹង-រាវ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ ហេដ្ឋារចនាសម្ព័ន្ធ សំណង់ និងសេវាសាធារណៈជាដើម ពិសេសជាងនេះ គឺតំបន់ទេសចរណ៍ក្នុងខេត្តកែបត្រូវតែរៀបចំ ទប់ស្កាត់ និងបង្កាកុំឱ្យមានការបំពុលទាំងប្រាំដែលជាធាតុមួយមិនអាចខ្វះបានក្នុងការរៀបចំឱ្យមាននូវផាសុកភាពសម្រាប់តំបន់ទេសចរណ៍នីមួយៗ។

សរុបរួមមកការអភិវឌ្ឍតំបន់ទេសចរណ៍ខេត្តកែបនេះ គឺពិតជាបានធ្វើឱ្យខេត្តកែបមានភាពរីកចម្រើន និងអភិវឌ្ឍន៍ជាខ្លាំងទាំងហេដ្ឋារចនាសម្ព័ន្ធ សោភ័ណភាព និងជាតំបន់ទេសចរណ៍ដែលមានសណ្តាប់ធ្នាប់សន្តិសុខល្អ ហើយបានទាក់ទាញនូវភ្ញៀវទេសចរជាច្រើនមកសម្រាកលំហែរកម្សាន្ត ក៏ដូចជាបានបម្រើនូវផលប្រយោជន៍ និងសេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងខេត្តកែបត្រូវតែធ្វើការអភិវឌ្ឍ និងរៀបចំបន្ថែមនូវចំណុចខ្វះខាតដូចបានបងស្រាយខាងលើ ស្របតាមផែនការជាយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ខេត្តកែបដែលបានសិក្សាស្រាវជ្រាវជាមួយនឹងការដំណោះស្រាយផងដែរ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើ ឃើញថា រដ្ឋបាលខេត្តកែប ដែលមានអភិបាលខេត្ត និងមន្ទីរទេសចរណ៍ខេត្តកែប ក៏ដូចជាស្ថាប័នពាក់ព័ន្ធផ្សេងទៀតបានខិតខំ ប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ក្នុងការរៀបចំគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍បានយ៉ាងឆាប់រហ័ស ព្រមទាំងបានធ្វើឱ្យតំបន់ទេសចរណ៍ខេត្តកែបមាននូវកេរ្តិ៍ឈ្មោះល្បីល្បាញ និងបានជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិជាខ្លាំង ប៉ុន្តែយើងក៏សង្កេតឃើញដែរថាការរៀបចំ និងការអភិវឌ្ឍតំបន់ទេសចរណ៍នៅក្នុងខេត្តកែបនៅមានចំណុចខ្វះខាត និងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា ការវិនិយោគ ការគ្រប់គ្រងបរិស្ថាន ការគ្រប់គ្រងសំរាម ការគ្រប់គ្រងសណ្តាប់ធ្នាប់នៅតំបន់ទេសចរណ៍ខេត្តកែបទាក់ទងនឹងការប្រកបអាជីវកម្មនៅមានចន្លោះខ្វះខាតបន្តិចបន្តួចក្នុងការរៀបចំដែលចាំបាច់ត្រូវមានការពង្រឹងបន្ថែមពីរដ្ឋបាលខេត្តកែបក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងមានការសហការពីសំណាក់ប្រជាពលរដ្ឋផងដែរ។ ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងខាងលើ នាងខ្ញុំ និងខ្ញុំបាទសូមស្នើ និងមានមតិយោបល់ដូចជា

- សូមអភិបាលខេត្តកែប និងមន្ទីរទេសចរណ៍ខេត្តកែបក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធពង្រឹងបន្ថែមលើប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងតំបន់ទេសចរណ៍នៅក្នុងខេត្តកែបអំពីសក្តានុពល ធនធានធម្មជាតិជាដើមក្នុងការទាក់ទាញនូវអ្នកវិនិយោគមកពីក្នុងស្រុក និងបរទេស ដើម្បីវិនិយោគទៅលើវិស័យទេសចរណ៍នៅក្នុងខេត្តកែបដែលជាផ្នែកមួយក្នុងការលើកស្ទួយដល់ប្រជាពលរដ្ឋក្នុងការបង្កើនការងារ និងលើកស្ទួយដល់សេដ្ឋកិច្ចជាតិ។
- សូមអភិបាលខេត្តកែប និងមន្ទីរទេសចរណ៍ខេត្តកែបបន្តពង្រឹងនូវការរៀបចំសណ្តាប់ធ្នាប់ទាក់ទងទៅនឹងការលក់ដូររបស់អាជីវករនៅតំបន់ទេសចរណ៍ខេត្តកែប ដើម្បីកុំឱ្យមានភាពអនាធិបតេយ្យ និងផ្តល់នូវទំនុកចិត្តដល់ភ្ញៀវដែលមកសម្រាកកម្សាន្តនៅខេត្តកែប។
- សូមអភិបាលខេត្តកែប និងមន្ទីរទេសចរណ៍ខេត្តកែបបន្តពង្រឹងនូវការរៀបចំ ការគ្រប់គ្រងសំរាមនៅតាមទីសាធារណៈនៅក្នុងតំបន់ទេសចរណ៍ខេត្តកែបឱ្យកាន់តែមាននូវប្រសិទ្ធភាព ដើម្បីជួយជំរុញឱ្យតំបន់ទេសចរណ៍ក្នុងខេត្តកែបឱ្យមានសោភ័ណភាព ពិសេសក្លាយជាតំបន់ទេសចរណ៍ដែលមានផាសុកភាពសម្រាប់ភ្ញៀវទេសចរណ៍ស្របទៅតាមផែនការដែលបានដាក់ចេញ។
- សូមអាជ្ញាធរគ្រប់ជាន់ថ្នាក់ បន្តការផ្សព្វផ្សាយគ្រប់រូបភាពអំពីប្រភពនៃការបំពុលបរិស្ថាន ផលប៉ះពាល់ព្រមទាំងដំណោះស្រាយក៏ដូចជាវិធានការនានា ដើម្បីចូលរួមក្នុងការជួយកាត់បន្ថយការបំពុលទាំងប្រាំទៅលើបរិស្ថាន។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ច្បាប់ស្តីពីសុវត្ថិភាពចំណីអាហារ, លេខ នស/រកម/០៦២២/០០៦, ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អ.ន.ក្រ.បក, ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩
- ព្រះរាជក្រឹត្យស្តីពីការប្តូរក្រុងកែបទៅជាខេត្តកែប, លេខ នស/រកត/១២០៨/១៣៨៣, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨
- អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩
- សេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តន៍គោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ, លេខ ១៣១ ស.ស.រ, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦
- សេចក្តីសម្រេចស្តីពីការបង្កើតក្រុមឆ្នាំសមុទ្រកម្ពុជា, លេខ ៧៥ សសរ, ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១០
- សេចក្តីប្រកាសព័ត៌មានស្តីពីការអនុញ្ញាតជូន គ.អ.ឆ.ក អនុវត្តន៍គម្រោងកែលំអឆ្នេរភក់ទៅជាឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់, ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១
- សេចក្តីប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត, លេខ ១២៣ ប្រ.ក, ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩
- គោលនយោបាយ ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព, លេខ ០១ គ.ន.ប, ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១
- សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា, លេខ០១ ស.រ.ណ.ន, ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២
- មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប, របាយការណ៍សកម្មភាពប្រចាំថ្ងៃក្នុងឆ្នាំ២០១៤

- សេចក្តីណែនាំ ស្តីពីការគ្រប់គ្រង ថែរក្សា សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងអនាម័យ បរិស្ថានក្នុងពិធីបុណ្យចូលឆ្នាំសកលឆ្នាំ២០២២ ឆ្លងចូលឆ្នាំ២០២៣, រដ្ឋបាលខេត្តកែប លេខ ០០៥ ស.ណ.ន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២
- របាយការណ៍សង្ខេបស្តីពីសមិទ្ធសំខាន់ៗ នៃការអនុវត្តន៍យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា ឆ្នាំ២០១៨-២០២២, ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២២
- របាយការណ៍សិក្សាវិសាលភាពស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងខេត្តកែប, ចុះខែសីហា ឆ្នាំ២០២០
- ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥, រាជរដ្ឋាភិបាល ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០២៣

## ២. ឯកសារយោងជាសៀវភៅតែងនិពន្ធ

- វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួនណាត
- សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៤
- សៀវភៅ ព័ត៌មានរាជធានីខេត្ត បោះពុម្ពថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

## ៣. ឯកសារយោងជាគេហទំព័រ

- គេហទំព័រ ប្រវត្តិខេត្តកែប - រដ្ឋបាលខេត្តកែប (kep.gov.kh)
- គេហទំព័រ https://visitcambodia.travel/kh/province/view/64b4a484d4t2848413s2
- គេហទំព័រ https://www.kampucheathmey.com/local-news/238355
- គេហទំព័រ https://www.mpwt.gov.kh/kh/press/36336
- គេហទំព័រ https://www.mpwt.gov.kh/kh/press/37627
- គេហទំព័រ https://www.cpp.org.kh/details/368426
- គេហទំព័រ https://www.information.gov.kh/articles/109268
- គេហទំព័រ https://www.gdlf-kh.com/

- គេហទំព័រ https://www.moe.gov.kh/index/43843
- គេហទំព័រ https://khmercm.com/national/7623
- គេហទំព័រ https://eacnews.asia/home/details/22899
- គេហទំព័រ https://cnc.com.kh/detail/news/37575
- គេហទំព័រ https://thmeythmey.com/?page=detail&id=126532

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ច្បាប់ ស្តីពីសុវត្ថិភាពម្ហូបអាហារ, លេខ នស/រកម/០៦២២/០០៦, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២

**ឧបសម្ព័ន្ធទី២៖** ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី៣៖** ព្រះរាជក្រឹត្យ ស្តីពីការប្តូរក្រុងកែបទៅជាខេត្តកែប, លេខ នស/រកត/១២០៨/១៣៨៣, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យ ស្តីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អ.ន.ក្រ.បក, ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្តក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាល, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

**ឧបសម្ព័ន្ធទី៦៖** សេចក្តីប្រកាសព័ត៌មាន ស្តីពីការអនុញ្ញាតជូនគ.អ.ឆ.ក អនុវត្តន៍គម្រោងកែលំអឆ្នេរភក់ទៅជាឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់, ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១

**ឧបសម្ព័ន្ធទី៧៖** សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមឆ្នាំសមុទ្រកម្ពុជា, លេខ ៧៥ សសរ, ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១០

**ឧបសម្ព័ន្ធទី៨៖** សារាចរណែនាំ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា, លេខ០១ ស.រ.ណ.ន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីសំខាន់ៗនៃតំបន់ទេសចរណ៍ខេត្តកែប

**ឧបសម្ព័ន្ធទី២៖** ទីតាំងសំខាន់ៗនៅក្នុងខេត្តកែប

**ឧបសម្ព័ន្ធទី៣៖** តំបន់ទេសចរណ៍ខេត្តកែប

# ច្បាប់
# ស្ដីពី
# សុវត្ថិភាពម្ហូបអាហារ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២/១៣

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនិងយន្តការសម្រាប់គ្រប់គ្រង និងធានាសុវត្ថិភាព គុណភាព អនាម័យ និងភាពស្របច្បាប់ នៃម្ហូបអាហារ ក្នុងគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ ដើម្បីផ្តល់ការការពារសុខភាពនិងសុវត្ថិភាពម្ហូបអាហារសម្រាប់អ្នកប្រើប្រាស់ និងធានាឱ្យមានការធ្វើពាណិជ្ជកម្មម្ហូបអាហារប្រកបដោយភាពស្មោះត្រង់។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងគុណភាពនិងសុវត្ថិភាពម្ហូបអាហារ ដែលគ្របដណ្តប់គ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ និងលើអាជីវកម្មម្ហូបអាហារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចដឹកនាំ សម្របសម្រួលការគ្រប់គ្រងគុណភាព សុវត្ថិភាពម្ហូបអាហារ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

## ជំពូកទី៣
## បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ និងគោលការណ៍ត្រួតពិនិត្យ

**មាត្រា៥ .-**

ការរៀបចំបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារត្រូវផ្អែកលើ៖

- ស្តង់ដារកម្ពុជាផ្នែកម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិ
- ស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំអន្តរជាតិ ដែលបានចេញដោយអង្គការសុវត្ថិភាពម្ហូបអាហារអន្តរជាតិនិងថ្នាក់តំបន់ក្នុងករណីស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំកម្ពុជាមិនបានកំណត់
- តម្រូវការជាក់ស្តែង និងត្រូវឆ្លើយតបទៅនឹងស្ថានភាពនៃសុខភាពមនុស្ស ឧស្សាហកម្ម ពាណិជ្ជកម្ម និងស្ថានភាពសេដ្ឋកិច្ចជាតិ។

បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ ត្រូវអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិតាមសំណើរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ក្នុងករណីក្រុមប្រឹក្សាស្តង់ដារជាតិមិនទាន់មានកំណត់បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ ក្រសួងពាណិជ្ជកម្មត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីកំណត់បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ។

**មាត្រា៦ .-**

ការកំណត់លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដោយត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារដូចមានចែងក្នុងមាត្រា៥ខាងលើ។

ការកំណត់លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារត្រូវអនុលោមតាមគោលការណ៍ដូចខាងក្រោម៖

(ក) ម្ហូបអាហារត្រូវមានសុវត្ថិភាព គុណភាព និងភាពសមស្របសម្រាប់មនុស្សបរិភោគ។

(ខ) ម្ហូបអាហារមិនត្រូវបាននាំចូល ផលិត កែច្នៃ ឬលក់ ក្នុងលក្ខណៈក្លែងបន្លំឬបំភាន់។

(គ) អ្នកប្រើប្រាស់បានទទួលព័ត៌មានគ្រប់គ្រាន់អំពីម្ហូបអាហារ ដូចជាប្រភពដើម គ្រឿងផ្សំ តម្លៃ អាហារូបត្ថម្ភ និងចំនួនកាឡូរី របៀបប្រើប្រាស់ និងការរក្សាទុក។

(ឃ) ម្ហូបអាហារត្រូវបំពេញតាមលក្ខខណ្ឌអនាម័យ ការវេចខ្ចប់ និងការដាក់ស្លាកសញ្ញា។

(ង) ម្ហូបអាហារដែលត្រូវបានចាត់ថាជាប្រភេទមានហានិភ័យខ្ពស់ ត្រូវចុះបញ្ជិកាឱ្យបានត្រឹមត្រូវ។

(ច) ការស្តុកទុកឬទីតាំងស្តុកម្ហូបអាហារ ត្រូវបំពេញតាមលក្ខខណ្ឌសម្រាប់ការរក្សាសុវត្ថិភាព និងគុណភាពរបស់ម្ហូបអាហារ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយនូវរាល់ព័ត៌មានថ្មីៗអំពីលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ។

**មាត្រា៧ ..**

ការត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវធ្វើឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារនៅគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ តាមតួនាទីនិងភារកិច្ចរៀងៗខ្លួន៖

(ក) ផ្អែកលើលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដែលនឹងត្រូវកំណត់ស្របតាមមាត្រា៦ខាងលើ ហើយក្នុងករណីចាំបាច់ ត្រូវផ្អែកលើស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំអន្តរជាតិ ដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ។

(ខ) ផ្អែកលើការសិក្សាវាយតម្លៃហានិភ័យ ដោយឈរលើមូលដ្ឋាននៃភស្តុតាងវិទ្យាសាស្ត្រដែលមាននិងត្រូវបានអនុវត្តក្នុងរបៀបមួយដែលឯករាជ្យ សត្យានុម័ត និងមានតម្លាភាព។

(គ) មានសមាមាត្រចំពោះហានិភ័យនេះ។

(ឃ) មិនតម្រូវឱ្យមានលក្ខណៈតឹងរ៉ឹងជាងភាពចាំបាច់នៃការត្រួតពិនិត្យ។

(ង) មិនត្រូវបង្កើតឧបសគ្គដែលមិនចាំបាច់ដល់ដំណើរការពាណិជ្ជកម្ម ឧស្សាហកម្ម និងសេដ្ឋកិច្ច។

(ច) មិនឱ្យមានការរើសអើងរវាងផលិតផល ឬផលិតករក្នុងស្រុក ឬបរទេស ឬក្នុងចំណោមប្រទេសផ្សេងទៀតនៅពេលដែលមានលក្ខខណ្ឌដូចគ្នាឬប្រហាក់ប្រហែលគ្នា។

**មាត្រា៨ ..**

ក្នុងករណីដែលត្រូវឆ្លើយតបនឹងស្ថានភាពបន្ទាន់នៃសុវត្ថិភាពម្ហូបអាហារ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវចេញបទប្បញ្ញត្តិដាក់កំហិតបន្ថែមលើលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់នោះ។ ការដាក់កំហិតបន្ថែមនោះ ត្រូវមានរយៈពេលកំណត់ជាក់លាក់ និងត្រូវបានពិនិត្យឡើងវិញ ក្នុងកំលុងពេលកំណត់មួយ។ នៅពេលដែលលែងមានស្ថានភាពបន្ទាន់ហើយនោះ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវលុបចោលការដាក់កំហិតបន្ថែមលើលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារនោះវិញ តាមសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៩ ..**

រាល់អាជីវកម្មម្ហូបអាហារ ត្រូវមានលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ រាល់ការចេញលិខិតអនុញ្ញាតត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ។

រាល់បុគ្គលទាំងឡាយណា ដែលបានប្រកបអាជីវកម្មម្ហូបអាហារ ត្រូវស្ថិតនៅក្រោមនីតិរូបនៃរបបសារពើពន្ធ ដោយមានសិទ្ធិទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា១០ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវកំណត់ក្រុមនៃប្រភេទអាជីវកម្មម្ហូបអាហារ និងត្រូវបង្កើតលក្ខខណ្ឌតម្រូវផ្សេងៗគ្នាដោយផ្អែកលើ៖

(ក) ប្រភេទនៃទីកន្លែងអាជីវកម្ម។

(ខ) ប្រភេទនៃប្រតិបត្តិការអាជីវកម្ម។

(គ) ប្រភេទនៃម្ហូបអាហារ។

ការដាក់ឱ្យអនុវត្តនូវលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារខាងលើ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវរក្សាបញ្ជីនិងធ្វើបច្ចុប្បន្នភាពនៃប្រតិបត្តិករអាជីវកម្មម្ហូបអាហារទាំងអស់ ក្រោយពីបានផ្តល់/ទទួលលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១១ .-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារមានកាតព្វកិច្ចជាចម្បងដូចខាងក្រោម៖

- ត្រូវធានាថាម្ហូបអាហារមានសុវត្ថិភាព គុណភាព និងភាពសមស្របសម្រាប់មនុស្សបរិភោគ ស្របតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ
- ត្រូវដោះស្រាយបញ្ហាសុវត្ថិភាពម្ហូបអាហារនៅពេលដែលកើតមាននៅក្នុងអាជីវកម្មរបស់ខ្លួន
- ត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ
- ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ក្នុងការអនុវត្តវិធានការដើម្បីជៀសវាង ឬកាត់បន្ថយហានិភ័យដែលបានបង្កដោយផលិតផលនៃអាជីវកម្មម្ហូបអាហារដែលពាក់ព័ន្ធ ព្រមទាំងការអង្កេតដាន ការប្រមូលម្ហូបអាហារមកវិញ និងការដកហូតម្ហូបអាហារ។

**មាត្រា១២ .-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ ហើយត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ក្នុងការអនុវត្តវិធានការដើម្បីជៀសវាង ឬកាត់បន្ថយហានិភ័យដែលបានបង្កដោយផលិតផលនៃអាជីវកម្មម្ហូបអាហារដែលពាក់ព័ន្ធ ព្រមទាំងការអង្កេតដាន ការប្រមូលម្ហូបអាហារមកវិញ និងការដកហូតម្ហូបអាហារ។

**មាត្រា១៣ .-**

ផលិតករ អ្នកកែច្នៃ ឬអ្នកវេចខ្ចប់ម្ហូបអាហារដាក់លក់មួយ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ និងលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ផលិតករ អ្នកកែច្នៃ ឬអ្នកវេចខ្ចប់ម្ហូបអាហារមិនត្រូវ៖

(ក) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ពុំមានសុវត្ថិភាព។

(ខ) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយបន្លំម៉ាក ឬមិនមានដាក់កាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់ ឬដាក់ស្លាកសញ្ញាមិនអនុលោមតាមលក្ខខណ្ឌស្តីពីស្លាកសញ្ញាដូចមានចែងក្នុងស្តង់ដារកម្ពុជាស្តីពីការដាក់ស្លាកសញ្ញាម្ហូបអាហារវេចខ្ចប់។

(គ) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយមិនមានបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករនៃម្ហូបអាហារ។

(ឃ) ស្តុកទុក ឬធ្វើសហាត្ថករណ៍ ឬទុកដាក់ ដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

# ជំពូកទី៤
# ការធ្វើអធិការកិច្ចម្ហូបអាហារ

**មាត្រា២២ ..**

ការធ្វើអធិការកិច្ចម្ហូបអាហារ ត្រូវអនុវត្តដោយមន្ត្រីអធិការកិច្ចម្ហូបអាហាររបស់ក្រសួងពាណិជ្ជកម្មនិង/ឬដោយមន្ត្រីអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ទៅតាមដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្ម តាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ដើម្បីលើកកម្ពស់គុណភាពនិងសុវត្ថិភាពម្ហូបអាហារ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវ៖

(ក) បង្កើតប្រព័ន្ធអធិការកិច្ចម្ហូបអាហារ ដោយផ្អែកលើមូលដ្ឋាននៃការសិក្សាវាយតម្លៃហានិភ័យ។

(ខ) កំណត់ប្រព័ន្ធចំណាត់ថ្នាក់ហានិភ័យសម្រាប់អាជីវកម្មម្ហូបអាហារ និងកំណត់ប្រភេទអាជីវកម្មដាក់លាក់នៅក្រោមប្រព័ន្ធចំណាត់ថ្នាក់នោះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចម្ហូបអាហារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា២៣ ..**

មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចម្ហូបអាហារនៃក្រសួងពាណិជ្ជកម្ម ឬមន្ត្រីអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា២៤ ..**

មន្ត្រីអធិការកិច្ចម្ហូបអាហារដូចមានចែងក្នុងមាត្រា២២នៃច្បាប់នេះ ដែលត្រូវចុះបំពេញភារកិច្ចក្នុងបរិវេណនិងក្នុងទីតាំងធ្វើអាជីវកម្មម្ហូបអាហារ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងមានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង/ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២៥ ..**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវរក្សាព័ត៌មានដែលបានរកឃើញក្នុងកំលុងពេលនៃការធ្វើអធិការកិច្ចជាការសម្ងាត់ លើកលែងតែមានការអនុញ្ញាតពីប្រធានស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ឬតុលាការតម្រូវឱ្យលាតត្រដាងព័ត៌មាននោះ។

# ជំពូកទី៥
# ម្ហូបអាហារនាំចូល

**មាត្រា២៦ ..**

ការនាំចូលម្ហូបអាហារ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដូចមានចែងក្នុងច្បាប់នេះ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ការនាំចូលម្ហូបអាហារអាចតម្រូវឱ្យមានភ្ជាប់វិញ្ញាបនបត្រដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញ ស្របទៅតាមគោលការណ៍គ្រប់គ្រងហានិភ័យដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ប្រភេទនៃម្ហូបអាហារដែលជាកម្មវត្ថុសម្រាប់តម្រូវការឯកសារ និងលក្ខខណ្ឌនៃការនាំចូល ត្រូវកំណត់ដោយ

**មាត្រា៤១ .-**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិ បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលបានប្រព្រឹត្តសកម្មភាពណាមួយដូចខាងក្រោម៖

(ក) រឹបអូសម្ហូបអាហារដោយមូលហេតុណាមួយ ក្រៅពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់នេះ។

(ខ) លាតត្រដាងព័ត៌មានណាមួយ ដែលបានទទួលក្នុងពេលបំពេញភារកិច្ចរបស់ខ្លួនក្រោមច្បាប់នេះ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ឬត្រូវបានតម្រូវដោយតុលាការឱ្យលាតត្រដាងព័ត៌មានពាក់ព័ន្ធនោះ ឬមានការអនុញ្ញាតដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តជាធរមានដោយឡែក។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា៤២ .-**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាព និងភាពសមស្របនៃម្ហូបអាហារហើយដែលមិនផ្ទុយនឹងច្បាប់នេះ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា៤៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃពុធ ៩កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០២២

នស/រកម.០៦២២.០២៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

## ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.–**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២
## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១
### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.–**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ១៥.–**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១៦.-**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.-**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម :

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

### មាត្រា ១៩.-

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

### មាត្រា ២០.-

ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

### មាត្រា ២១.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត

-មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

### មាត្រា ២២.-

សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម :

-សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

-សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

**មាត្រា ២៣.–**

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួស ក្នុងរយៈពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៤.–**

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំលាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៥.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត “គ.ជ.ប” ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម :

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០) ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំលាយតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០) ថ្ងៃ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

### មាត្រា ២៦.-

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

### មាត្រា ២៧.-

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

### មាត្រា ២៨.-

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

### មាត្រា ២៩.-

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ ។

### មាត្រា ៣០.-

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ។

ROYAUME DU CAMBODGE – LE MINISTRE DU PALAIS ROYAL

សម្បត្តិរដ្ឋដែលបានផ្ទេរមកឱ្យខ្លួន ឬ ដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួនផ្សេងទៀតឱ្យមានប្រសិទ្ធភាព ។

នីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៧.-**

ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ការរំលោភអំណាចកើតឡើងនៅពេលដែលអ្នកជាប់ឆ្នោតណាម្នាក់ ឬ អ្នកដែលបានទទួលការតែងតាំងនៅក្នុងក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រដ្ឋ ឬ ក្នុងក្រុមប្រឹក្សាណាមួយ ឬ ជនណាម្នាក់ ដែលបានប្រព្រឹត្តអំពើដោយចេតនា ហើយដែលមិនអាចធ្វើយុត្តិកម្មបានដូចជា :

-ការប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈណាមួយ

-ការមិនបានប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនម្នាក់ទៀតដែលស្ថិតនៅក្រោមអំណាច ឬ ការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈ ។

**មាត្រា ៤៩.-**

ការរំលោភអំណាច រួមមានសកម្មភាពណាមួយ ដូចខាងក្រោម :

-ការរំលោភសិទ្ធិស្របច្បាប់ ឬ សិទ្ធិមនុស្សរបស់ជនណាម្នាក់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ។

### មាត្រា ៦៧.-

ក្នុងករណីមានសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាមានឧត្តមានុភាព ។

### មាត្រា ៦៨.-

អង្គប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងជាសាធារណៈ ។

ក្រុមប្រឹក្សាអាចប្រជុំជាសម្ងាត់បាន ។

កិច្ចដំណើរការនៃការប្រជុំជាសម្ងាត់ ត្រូវកំណត់ដោយសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

### មាត្រា ៦៩.-

អង្គប្រជុំរបស់ក្រុមប្រឹក្សាត្រូវអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីគំរូបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

### មាត្រា ៧០.-

អង្គប្រជុំសាមញ្ញលើកទី ១ របស់ក្រុមប្រឹក្សា ត្រូវប្រារព្ធឡើងមិនឱ្យហួសពីដប់ប្រាំ (១៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ។

### មាត្រា ៧១.-

ក្នុងកិច្ចប្រជុំលើកទី ២ របស់ខ្លួន ក្រុមប្រឹក្សាត្រូវចាត់វិធានការដើម្បីអនុម័តបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ខ្លួនតាមទម្រង់ជាដីកា ។

ក្រុមប្រឹក្សាអាចអនុម័តយកគំរូបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមការណែនាំរបស់ក្រសួងមហាផ្ទៃ ដោយមានការកែប្រែ ឬ ដោយមិនមានការកែប្រែ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៧២.-**

ក្រុមប្រឹក្សា ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ខ្លួន ។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ក្រុមប្រឹក្សា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ ។

**មាត្រា ៧៣.-**

សមាជិកក្រុមប្រឹក្សា មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន ។

គ្មានសមាជិកក្រុមប្រឹក្សាណាម្នាក់ត្រូវបានចាប់ខ្លួន ឬ ឃុំខ្លួន ឬ ប្រឈមនឹងសកម្មភាព ឬ ចំណាត់ការណាមួយដោយសារតែហេតុផលនៃការបញ្ចេញមតិ ឬ ការបោះឆ្នោតរបស់ខ្លួនក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាឡើយ ។

**មាត្រា ៧៤.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រជុំសាមញ្ញនៅក្នុងដែនដីរបស់ខ្លួនយ៉ាងហោចណាស់ចំនួនដប់ពីរ(១២)ដង ជារៀងរាល់ឆ្នាំ ។

អង្គប្រជុំសាមញ្ញក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រារព្ធឡើងមិនឱ្យមុនម្ភៃប្រាំ(២៥)ថ្ងៃ ឬ លើសពីសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំសាមញ្ញលើកមុនរបស់ក្រុមប្រឹក្សាបានឡើយ ។

**មាត្រា ៧៥.-**

ក្រុមប្រឹក្សា ត្រូវអនុម័តប្រតិទិននៃការប្រជុំសាមញ្ញរបស់ខ្លួន សម្រាប់រយៈពេលដប់ពីរ (១២)ខែ មិនឱ្យហួសពីអង្គប្រជុំសាមញ្ញលើកទី ២ និងសម្រាប់រយៈពេលជាបន្តបន្ទាប់ទៀតក្នុងរយៈពេលដប់ពីរ(១២)ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់ ។

**មាត្រា ៧៦.-**

ក្រុមប្រឹក្សា ត្រូវផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវប្រតិទិននៃការប្រជុំសាមញ្ញរបស់ខ្លួន ។

**មាត្រា ៧៧.–**

ក្រុមប្រឹក្សា អាចកោះប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬ ពិសេសណាមួយ ។

## ផ្នែកទី ៥
## ទង្វើមិនស្របច្បាប់ ដោយក្រុមប្រឹក្សា ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សា

**មាត្រា ៧៨.–**

សកម្មភាព ឬ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សា ឬ សមាជិកក្រុមប្រឹក្សា ឬ គណៈកម្មាធិការ ឬ គណៈអភិបាល ឬ អភិបាល ឬ បុគ្គលិក ដែលធ្វើឡើងហួសពីសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ឬ ហួសពីសិទ្ធិអំណាចរបស់សមាជិកក្រុមប្រឹក្សា ឬ របស់គណៈកម្មាធិការ ឬ របស់គណៈអភិបាល ឬ របស់អភិបាល ឬ របស់បុគ្គលិករបស់ក្រុមប្រឹក្សា គឺជាទង្វើមិនស្របច្បាប់ ។

**មាត្រា ៧៩.–**

សកម្មភាព ឬ សេចក្តីសម្រេចទាំងឡាយណាដែលខុសច្បាប់ សកម្មភាព ឬ សេចក្តីសម្រេចនោះ ពុំមានសុពលភាពឡើយ ។

**មាត្រា ៨០.–**

ការចំណាយទាំងឡាយណាដែលធ្វើឡើងដោយក្រុមប្រឹក្សា ឬ ក្នុងនាមក្រុមប្រឹក្សា ដើម្បីអនុវត្តសកម្មភាព ឬ សេចក្តីសម្រេចណាមួយដែលមិនស្របច្បាប់ គឺជាការចំណាយមិនស្របច្បាប់ ។

**មាត្រា ៨១.–**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និង គណៈអភិបាលអំពីសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់ណាមួយ ដែលធ្វើឡើងដោយក្រុមប្រឹក្សា ឬ សមាជិកក្រុមប្រឹក្សា ឬ គណៈកម្មាធិការ ឬ គណៈអភិបាល ឬ អភិ-

ROYAUME DU CAMBODGE LE MINISTRE du PALAIS ROYAL

**មាត្រា ១៣៩.–**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.–**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.–**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.–**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL
ព្រះរាជាណាចក្រកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨

៣រល.០៧០៥.៥៩៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
**ហត្ថលេខា**
**ស ខេង**

លេខៈ ៥៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៣៤៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .—**

ត្រូវបានប្តូរ ក្រុងកែប ទៅជា ខេត្តកែប ។

**មាត្រា ២ .—**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខេត្តកែប ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

Downloaded from http://www.khmerlaws.com

មាត្រា ៣ .—

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ .—

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្ត អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ .—

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នស.០៧១២.១៤០៧

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខ:១៧៨៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៨

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ជិនកេន

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី ៦
## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ៣០.-**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមនីតិវិធីដូចចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួន នៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុលដើម្បីអធិការកិច្ច យកគំរូតាង ឬពិនិត្យកត់ត្រា

ខ-កំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣១.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កឱ្យមានគ្រោះថ្នាក់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិចូលធ្វើអធិការកិច្ច នៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣២.-**

ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពតិមានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឱ្យមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៨
## អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត របស់ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង របស់ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ព្រមទាំងទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ក្នុងខេត្ត និងរដ្ឋបាលទាំងនេះជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

រដ្ឋបាលខេត្តដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត ។

រដ្ឋបាលក្រុងដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ។

រដ្ឋបាលស្រុកដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ។

**មាត្រា ៣.-**

ខេត្ត ក្រុង ស្រុក ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ។

**មាត្រា ៤.-**

ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងខេត្ត ត្រូវមានក្រុមប្រឹក្សារៀង១ខ្លួនជាតំណាង ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥.-**

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ទទួលសិទ្ធិអំណាចរបស់ខ្លួនដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលស្របនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

## ជំពូកទី២

## រដ្ឋបាលខេត្ត

### ផ្នែកទី១

### ក្រុមប្រឹក្សាខេត្ត

**មាត្រា ៦.-**

ក្រុមប្រឹក្សាខេត្តដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ

+ វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ

+ កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាខេត្តយល់ឃើញថា ចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្ដារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្ដារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ៣០.-**

នៅពេលបានទទួលរបាយការណ៍ឬព័ត៌មានអំពីការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលខេត្តត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលខេត្តត្រូវធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាខេត្តនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៣១.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា២៩ និងមាត្រា៣០ នៃអនុក្រឹត្យនេះ និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលខេត្តត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាខេត្តអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន។

អភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលខេត្ត លើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលខេត្តទទួលខុសត្រូវអំពីការសម្រេចនិងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលខេត្តត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាសនិងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលខេត្តអាចកោះប្រជុំតាមការចាំបាច់។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា ៣២.-**

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាខេត្ត ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។

**មាត្រា ៣៣.-**

គណៈអភិបាលខេត្ត ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលខេត្ត និងអភិបាលរងខេត្ត ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលខេត្ត អភិបាលរងខេត្ត និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ។

**មាត្រា ៣៤.-**

អភិបាលខេត្ត ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ។

អភិបាលខេត្ត អាចប្រគល់សិទ្ធិដល់អភិបាលរងខេត្តក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងខេត្តនីមួយៗ។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខេត្ត។

អភិបាលខេត្ត មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងខេត្តណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ និងមិនស្របតាមបែបបទ នីតិវិធី។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលខេត្តត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ។

**មាត្រា ៣៥.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខេត្ត អភិបាលខេត្តមានភារកិច្ច :

- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ឱ្យអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទីរ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ

- សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ អង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាខេត្ត។
- ពិនិត្យ វាយតម្លៃ ផ្ដល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា តាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុន ក្នុងការផ្ដល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខេត្ត។ ក្នុងករណីមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពណាមួយ អភិបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលដែលមិនគាំទ្រនោះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីពិនិត្យពិចារណា។ ក្នុងករណីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីឯកភាពតាមរបាយការណ៍របស់អភិបាលខេត្ត រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្ដូរបេក្ខភាពដែលបានស្នើឡើងឱ្យបានសមស្រប។ ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីស្រាវជ្រាវឃើញថា ហេតុផលដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលខេត្តពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលខេត្ត ដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ។ ក្នុងករណីមិនមានការឯកភាពរវាងអភិបាលខេត្ត ជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីទៅលើបេក្ខភាពដែលស្នើតែងតាំងនោះ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើសេចក្ដីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ សម្រេច។ អភិបាលខេត្តត្រូវរាយការណ៍ករណីនេះជូនក្រុមប្រឹក្សារបស់ខ្លួននិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីក្នុងមន្ទីរ អង្គភាព និងទីភ្នាក់ងារណាមួយ ឬការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយ អភិបាលខេត្តត្រូវធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះ ឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់។ ក្នុងករណីប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតីឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ អភិបាលខេត្តត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនៃមន្ទីរ អង្គភាព និងទីភ្នាក់ងារទាំងនោះ។ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ដើម្បីដោះស្រាយទៅតាមច្បាប់។

ក្នុងការសិក្សាខាងលើនេះ គ.ជ.អ.ប. ត្រូវធ្វើការពិគ្រោះយោបល់និងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំយុទ្ធសាស្ត្រ និងដំណាក់កាលសមស្របក្នុងដំណើរការធ្វើសមាហរណកម្មនេះ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ២១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ២១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ៥ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល លេខ ៤៤៦
ថ្ងៃទី ០៨-២-១២
បញ្ជូន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១ . សរាណន .

# សារាចរណែនាំ
# ស្តីពី
# ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក កាលពីថ្ងៃទី២៥និងទី២៦ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងទូបាគូតា ប្រទេសសេណេហ្គាល់ ដោយក្លឹបឆ្នេរស្អាតបំផុតលើពិភពលោក ដោយសារភាពសម្បូរបែបនៃជីវៈចម្រុះ ភាពប្រណីតនៃបរិស្ថានធម្មជាតិ តម្លៃអេកូឡូស៊ីសេដ្ឋកិច្ចសង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍។ ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងកំណើនប្រជាជននៅក្នុងតំបន់ឆ្នេរសមុទ្រ ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលទាមទារឲ្យមានការអភិវឌ្ឍផ្នែករូបវន្តសមស្រប ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា មានផែនការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាពនិងចីរភាព ដើម្បីចៀសវាងនិងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថានវប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រ។

រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវសារាចរនេះ ដើម្បីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តនូវគោលការណ៍គ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដែនគោក កោះ និងដែនទឹកដូចខាងក្រោម៖

## ១. ឆ្នេរសមុទ្រ

ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានាជាថ្ម ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០(សាមសិប)ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក។
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ)ម៉ែត្រចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

នៅលើឆ្នេរសមុទ្រ អាចអនុញ្ញាតឲ្យដាក់ឆត្រ កៅអី និងតុតូចៗតាមចំនួនសមស្រប ដែលអាចផ្លាស់ប្តូរទីតាំងបាន សម្រាប់គោលដៅសម្រាកលំហែកាយនិងត្រូវរៀបចំដាក់តួបឆ្មាំឆ្នេរសមុទ្រ ដោយបំពាក់សម្ភារៈនិងឧបករណ៍ចាំបាច់តាមតម្រូវការ ដើម្បីឃ្លាំមើលនិងការពារសុវត្ថិភាពជូនសាធារណជននិងអ្នកទេសចរ។

## ២- ដីចំណីឆ្នេរសមុទ្រនិងការប្រើប្រាស់

ដីចំណីឆ្នេរសមុទ្រ ជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតងនិងបណ្តាញទេសភាពឬសម្រាប់ដាំដើមឈើសម្គាល់ព្រំឆ្នេរនិងចំណីឆ្នេរដោយបន្តទៅជាប់នឹងផ្លូវសាធារណៈដែលស្ថិតក្នុងទិសខាងដីគោក។

### ២.១- ដីចំណីឆ្នេរសមុទ្រ

ដីចំណីឆ្នេរសមុទ្រ គឺជាផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។

ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់យ៉ាងតិច៥០(ហាសិប)ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

### ២.២- ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ

ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រមានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាមស្ថានភាពទីតាំងនីមួយៗ៖

ទី១- ដីចំណីឆ្នេរសមុទ្រដែលមានមនុស្សរស់នៅច្រើននិងមានលក្ខណៈជាទីប្រជុំជនឬមានសកម្មភាពទេសចរណ៍ ការប្រើប្រាស់ ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យសាងសង់ជាសំណង់តូបតូចៗសម្រាប់បម្រើដល់សេវាកម្មទេសចរណ៍នៅចន្លោះដើមឈើដែលមានចម្ងាយពីតូបមួយទៅតូបមួយទៀតយ៉ាងតិច១៥(ដប់ប្រាំ)ម៉ែត្រ ដើម្បីសម្រួលដល់ការឆ្លងកាត់របស់សាធារណជននិងអ្នកទេសចរ និងរក្សាគំហើញទៅលំហសមុទ្រ។ សំណង់តូបតូចៗនេះត្រូវរៀបចំឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនិងមានច្រកដើរចេញចូលច្បាស់លាស់ដើម្បីចៀសវាងផលប៉ះពាល់ដល់សួនច្បារនិងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យមានសំណង់ជានិមិត្តរូបផ្សេងៗ ជាលក្ខណៈរូបចម្លាក់ស្តូប ឬសិល្បៈសាធារណៈ
- អាចអនុញ្ញាតឲ្យមានចំណតយានយន្តទេសចរគ្រប់ប្រភេទចូលចតក្នុងបរិវេណដីចំណីឆ្នេរសមុទ្រ ដែលមិនប៉ះពាល់ដល់សួនច្បារ និងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យសាងសង់ជាបង្គន់អនាម័យសាធារណៈដែលមានលក្ខណៈសោភណភាព និងចំនួនសមស្រប សម្រាប់បម្រើដល់សាធារណជននិងអ្នកទេសចរ ដោយស្ថិតនៅតាមទីតាំងសមស្របនិងមិនប៉ះពាល់ដល់ទស្សនីយភាពតំបន់
- មិនអាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែពាណិជ្ជកម្ម លើកលែងតែកំពង់ផែដែលមានស្រាប់ និងទីតាំងដែលមានសក្តានុពលខ្លាំងនិងចាំបាច់សម្រាប់សាងសង់កំពង់ផែ។

- មិនអាចអនុញ្ញាតឲ្យមានសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នោះត្រូវសាងសង់ឡើងក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈនិងទេសចរណ៍ដូចជា៖
    - ច្រកចូលឬស្ពានសម្រាប់តភ្ជាប់ទៅកែកំពង់ផែ ដែលមានទូកទេសចរណ៍ឬទូកម៉ាស៊ីនតូចៗសម្រាប់ភ្ញៀវទេសចរឬសាធារណជនប្រើប្រាស់។ កំពង់ផែទាំងនេះត្រូវមានទីតាំងសមស្របនិងមិនរំខានដល់សកម្មភាពឆ្លងកាត់ឆ្នេរសមុទ្រ
    - សារមន្ទីរជីវៈចម្រុះ រុក្ខជាតិសមុទ្រ ត្រីសមុទ្រ(Aquariums) ដែលនៅផ្នែកខាងមុខសំណង់ស្ថាបត្យកម្មនេះអាចឲ្យភ្ញៀវទេសចរឬសាធារណជនអាចឆ្លងកាត់បាន
    - ទីតាំងផ្សេងទៀតដែលរាជរដ្ឋាភិបាលអនុញ្ញាត។

ទី២- ដីចំណីឆ្នេរសមុទ្រស្ថិតក្នុងតំបន់ដែលមិនមានមនុស្សរស់នៅច្រើននិងមិនមែនជាទីប្រជុំជន ការប្រើប្រាស់ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែ ពាណិជ្ជកម្ម ឬកំពង់ផែនេសាទ។ ចំពោះកំពង់ផែដែលមានស្រាប់ ត្រូវរៀបចំឲ្យមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹង។ ក្នុងករណីចាំបាច់ ត្រូវធ្វើការសិក្សាពីផលប៉ះពាល់បរិស្ថាននិងភាពសមស្របនៃទីតាំង ដើម្បីធានាសុវត្ថិភាពសុខុមាលភាពនិងការកាត់បន្ថយហានិភ័យផ្សេងៗ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាតំបន់ទេសចរណ៍លើទឹក កំពង់ផែទេសចរណ៍ ឬតំបន់កម្សាន្តថ្មីដោយមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារធនធានទឹក ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាភូមិទេសចរណ៍នៅក្នុងទីតាំងភូមិឋានថ្មីឬដែលមានស្រាប់ទៅតាមស្ថានភាពនិងសក្តានុពលជាក់ស្តែងនៃទីតាំងនីមួយៗ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យបានត្រឹមត្រូវ ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជា សំណង់រោងចក្រ ឧស្សាហកម្មរោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងពុលខ្ពស់ទៅក្នុងបរិយាកាសនិងបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង
- អាចអនុញ្ញាតឲ្យមានការអភិវឌ្ឍឬឲ្យមានសំណង់ផ្សេងទៀតស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

## ៣- ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ

ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រ ដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះនិងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្មក្នុងគោលដៅ

ថែរក្សា ការពារ និងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានចំណីផ្លូវទំហំយ៉ាងតិច១៥ (ដប់ប្រាំ)ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

## ៤- តំបន់រណបតាមបណ្តោយផ្លូវសាធារណៈ

តំបន់រណប គឺជាតំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រនិងផ្លូវស្របបន្ទាប់មួយទៀត ដែលស្ថិតក្នុងទិសខាងដីគោក។

ការអភិវឌ្ឍនិងការសាងសង់សំណង់នានាក្នុងតំបន់នេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់សេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត។

ដើម្បីលើកកម្ពស់សោភណភាពបរិស្ថានធម្មជាតិនិងសំណង់ ការអភិវឌ្ឍសំណង់អគារក្នុងតំបន់រណបនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាប សម្រាប់គ្រប់ប្រភេទសំណង់អគារ ដូចមានចែងក្នុងបទដ្ឋាននគរូបនីយកម្ម
- ត្រូវរៀបចំឲ្យមានសួនច្បារ ដាំស្មៅ ដាំដើមឈើ និងមានផ្លូវថ្មើរជើងនៅលើចិញ្ចើមផ្លូវ ស្របតាមបទដ្ឋានបច្ចេកទេស
- ត្រូវរៀបចំជាលំហសាធារណៈ សួនច្បារ សួនកម្សាន្ត ឬឧទ្យានសាធារណៈជាដើម ដើម្បីលើកកម្ពស់សោភណភាពតំបន់ឆ្នេរសមុទ្រ
- ត្រូវមានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសម្រាប់រាល់ការដាក់តាំងស្លាកសញ្ញាពាណិជ្ជកម្ម។

## ៥- ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ

ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រដែលតភ្ជាប់ទៅចំណុចប្រសព្វនឹងផ្លូវដែលជាប់នឹងដីចំណីឆ្នេរសមុទ្រត្រូវ៖

- រក្សាទុកចិញ្ចើមសងខាងយ៉ាងតិច៦(ប្រាំមួយ)ម៉ែត្រ ចំពោះកំណាត់ផ្លូវសាធារណៈនៅក្នុងតំបន់រណប ដើម្បីរៀបចំឲ្យមានសួនច្បារ ការដាំស្មៅ ការដាំដើមឈើព្រមទាំងផ្លូវថ្មើរជើងស្របតាមបទដ្ឋានបច្ចេកទេស
- រៀបចំឲ្យមានសួនច្បារ ការដាំស្មៅ និងការដាំដើមឈើអមសងខាងតាមស្ថានភាពជាក់ស្តែងនិងស្របតាមបទដ្ឋានបច្ចេកទេសចំពោះផ្លូវថ្មើរជើងដែលមានស្រាប់ឬបង្កើតថ្មី
- ត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើនបង្កើតជាបណ្តាញបៃតងភ្ជាប់ទៅនឹងដីចំណីឆ្នេរសមុទ្រ ចំពោះផ្ទៃដីឬលំហសាធារណៈដែលស្ថិតនៅជាប់ផ្លូវសាធារណៈដែលមានស្រាប់ឬបង្កើតថ្មី ដើម្បីលើកកម្ពស់សោភណភាពបរិស្ថាននិងជាការបើកច្រកខ្យល់ជំនោរសមុទ្រ។

- អនុវត្តតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត
- ត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ ដោយរៀបចំឱ្យមានអាងចម្រោះ ប្រព័ន្ធលូ និងប្រព័ន្ធគ្រប់គ្រងគុណភាពទឹក និងគ្រប់គ្រងកាកសំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស ចំពោះរាល់ការអភិវឌ្ឍ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃផលប៉ះពាល់បរិស្ថាន ឱ្យបានត្រឹមត្រូវម៉ត់ចត់ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជាសំណង់រោងចក្រ ឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងបំពុលខ្ពស់ទៅក្នុងបរិយាកាស និងកម្រិតបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង។

៩.២- រាល់ការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនិងកោះនិងការធ្វើសកម្មភាពសេដ្ឋកិច្ចនិងទេសចរណ៍ ត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

១០- សារាចរណែនាំនេះមិនមានផលប្រតិសកម្មទេ។

១១- សារាចរណែនាំនេះមិនពាក់ព័ន្ធទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ ទេ។

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ព្រមទាំងផែនការគ្រប់គ្រងការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រជាបន្ទាន់នូវរាល់ទីតាំងទាំងឡាយណាដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ដើម្បីសុំការសម្រេចពីស្ថាប័នមានសមត្ថកិច្ចនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនៃបណ្តាខេត្តតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តខ្លឹមសារនៃសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពនិងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ... ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធរូបភាពទី១៖ ផែនទីសំខាន់ៗនៃតំបន់ខេត្តកែប

ផែនទីរដ្ឋបាលខេត្ត



ផែនទីក្រុងកែប


ផែនទី ក្រុងកែប
អូរក្រសា
Ou Krasar
ព្រៃធំ
Prey Thum
ពងទឹក
Pong Tuek
កែប
Kaeb
អង្កោល
Angkaol

# ប្លង់គោលប្រើប្រាស់ដីក្រុងកែប ចក្ខុវិស័យឆ្នាំ២០៣០




# ផែនទីកន្លែងនេសាទសមាគមន៍អង្កោល



## ផែនទីកន្លែងនេសាទសហគមន៍កែប




## ផែនទីកន្លែងនេសាទសហគមន៍ភូមិថ្មី



## ផែនទីកន្លែងនេសាទសហគមន៍ភូមិកំពង់ត្រឡាច



## ផែនទីកន្លែងនេសាទសហគមន៍ភូមិអូរក្រសារ



# គម្រោងប្លង់រៀបចំកែលំអតំបន់ឆ្នេរខ្សាច់កម្សាន្តសាធារណៈ



# ឧបសម្ព័ន្ធរូបភាពទី២៖ ទីតាំងសំខាន់ៗនៅក្នុងខេត្តកែប




រូបតំណាងខេត្តកែប



សាលាខេត្តកែប



មន្ទីរទេសចរណ៍ខេត្តកែប




មន្ទីរបរិស្ថានខេត្ត




មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប




មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកែប

# ឧបសម្ព័ន្ធរូបភាពទី៣៖ តំបន់ទេសចរណ៍ខេត្តកែប



ឆ្នេរអង្កោល



ឧទ្យានជាតិកែប



កំពង់ផែកោះទន្សាយ



ស្រែអំបិល



ភ្នំវល្លិ៍



ឆ្នេរស្រីស



ផ្សារក្តាម



ឆ្នេរថ្មី



ថ្ងៃបាំងឆ័ត្រ